# ការគ្រប់គ្រងគុណភាព

# នៃកម្មវិធីអប់រំ

នៅ

## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

និង

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ASEAN University Network

ADB

# ការគ្រប់គ្រងគុណភាព

# នៃកម្មវិធីអប់រំ

# នៅ

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ASEAN University Network

ADB Asian Development Bank
FIGHTING POVERTY IN ASIA AND THE PACIFIC

**ការគ្រប់គ្រងគុណភាពនៃកម្មវិធីអប់រំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនិង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** រៀបចំបោះពុម្ពដោយ៖


ASEAN University Network (AUN)

17th Floor, Chaloem Rajakumari 60

Chamchuri 10 Building

Chulalongkorn University

Phayathai Road, Bangkok

10330 Thailand



© ASEAN University Network

រក្សាសិទ្ធិ

មិនអនុញ្ញាតឲ្យផ្នែកណាមួយនៃការបោះពុម្ពនេះ យកទៅបង្កើត រក្សាទុកក្នុងប្រព័ន្ធទាញទិន្នន័យ ឬចម្លង ក្នុងទម្រង់ណាមួយដោយវិធីផ្សេងៗ ជាលក្ខណៈអេឡិចត្រូនិច មេកានិច ថតចម្លង ចម្លងនិង/ឬវិធីផ្សេងៗ ដោយគ្មានការអនុញ្ញាតជាមុនពីនាយកប្រតិបត្តិនៃបណ្ដាញសាកលវិទ្យាល័យអាស៊ានបានឡើយ។



ទម្រង់លេខ១.០

Date of Publication: November 2016

## មាតិកា


| ជំពូក | ទំព័រ |
|---|---|
| សេចក្តីថ្លែងអំណរគុណ | iii |
| បុព្វកថា | iv |
| សេចក្តីផ្តើម | 1-14 |
| 1. លទ្ធផលសិក្សាដែលរំពឹងទុក | 15-22 |
| 2. កម្មវិធីលម្អិត | 23-28 |
| 3. រចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្មវិធី | 29-32 |
| 4. យុទ្ធវិធីបង្រៀន និងរៀន | 33-40 |
| 5. ការវាយតម្លៃនិស្សិត | 41-49 |
| 6. គុណភាពនៃបុគ្គលិកសិក្សា | 50-56 |
| 7. គុណភាពបុគ្គលិកគាំទ្រ | 57-59 |
| 8. គុណភាព និងការគាំទ្រនិស្សិត | 60-63 |
| 9. សម្ភារៈបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ | 64-66 |
| 10. ការបង្កើនគុណភាព | 67-70 |
| 11. ធាតុចេញ | 71-74 |

## សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំនេះរៀបចំរួមគ្នានិងសរសេរដោយលោក Johnson Ong Chee Bin អ្នកជំនាញខាងផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN-QA) ជាមួយក្រុមការងារចងក្រងឯកសារមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលមានឈ្មោះដូចខាងក្រោមៈ

## ក្រុមបង្កើតឯកសារ

### សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច

| | |
|---|---|
| Dr. Phalthy Hap | បណ្ឌិត ហាប់ ផល្ធី |
| Dr. Sophorn Soeun | បណ្ឌិតសឿន សោភ័ណ |
| Mr. Menghiek Chheang | លោក ឈាង ម៉េងហៀក |
| Dr. Duy Chandina | បណ្ឌិត ឌុយ ចាន់ឌីណា |
| Ms. Panhatey Yuok | លោកស្រី យក់ បញ្ញាតី |
| Mr. Kong Lay | លោក ឡាយ គង់ |
| Ms. Maneth Khim | លោកស្រី ឃឹម ម៉ាណែត |
| Mr. Chamroeun Suon | លោក សួន ចំរើន |
| Mr. Chantra Thong | លោក ថោង ចន្ទ្រា |
| Mr. Tileng Chi | លោក ជី ទីឡេង |

### សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

| | |
|---|---|
| Mr. Chorvy Vong | លោក វង់ ឆវី |
| Mr. Moeun Saut | លោក សូត្រ មឿន |
| Mr. Udomsambath Phal | លោក ផល ឧត្តមសម្បត្តិ |
| Mr. Sothea Kok | លោក កុក សុធា |
| Mr. Sovoan Nhoung | លោក ញូង សុវ័ន្ត |
| Dr.. Monirith Ly | បណ្ឌិត លី មុនីរិទ្ធ |
| Dr. Hok Roth | បណ្ឌិត រ័ត្ន ហុក |

# បុព្វកថាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

*"សៀវភៅណែនាំស្តីពីការគ្រប់គ្រងគុណភាពកម្រិតកម្មវិធីអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច"* បានរៀបចំឡើងដោយផ្អែកលើ សៀវភៅណែនាំវាយតម្លៃកម្រិតកម្មវិធីរបស់បណ្តាញសាកលវិទ្យាល័យ អាស៊ាន(AUN-QA)។ សៀវភៅនេះគឺជាឯកសារសំខាន់ សម្រាប់ជំរុញការគ្រប់គ្រងគុណភាពកម្រិតកម្មវិធីអប់រំរបស់ឧត្តមសិក្សាក្នុងប្រទេសកម្ពុជា។ ឯកសារនេះ ជាលទ្ធផលនៃកិច្ចសហការ និងការពិគ្រោះពិភាក្សា ជាមួយអ្នកជំនាញខាងផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN-QA) លោក Johnson Ong Chee Bin និងអ្នកតំណាងផ្នែកធានាគុណភាពរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីធានាថានិស្សិតកម្រិតឧត្តមសិក្សាក្នុងប្រទេសកម្ពុជាទទួលបានឱកាសអប់រំដែលប្រកបដោយគុណភាពខ្ពស់។ការអនុលោមតាមការណែនាំទាំងនេះគឺមានសក្តានុពលក្នុងការពង្រឹងសេវាអប់រំឲ្យកាន់តែប្រសើរ និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សដើម្បីផ្តល់ឱកាសការងារក្នុងទីផ្សារការងារទាំងក្នុងស្រុកនិងតំបន់។

សៀវភៅណែនាំនេះមានគោលបំណងជំរុញឲ្យមានការអនុវត្តល្អៗក្នុងការគ្រប់គ្រងគុណភាពតាមសហគមន៍ឧត្តមសិក្សាក្នុងប្រទេសកម្ពុជា និងជួយជាគំនិតបង្កើតវប្បធម៌គុណភាពនៅតាមស្ថាប័ននានា ដើម្បីឈានទៅរកប្រព័ន្ធធានាគុណភាពរួមមួយដែលគួរឲ្យទុកចិត្ត។

តាងនាមឲ្យក្រុមការងាររៀបចំចងក្រងឯកសារមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ខ្ញុំសូមថ្លែងអំណរគុណដល់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)ដែលបានផ្តល់ការគាំទ្រខាងផ្នែកហិរញ្ញវត្ថុនិងគណៈកម្មការផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន(AUN-QA)ដែលបានប្រមូលផ្តុំក្រុមការងារក្នុងការរៀបចំសៀវភៅនេះឡើង។ ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងាររបស់ខ្ញុំ ដែលប្រឹងប្រែងធ្វើឲ្យសៀវភៅនេះលេចចេញជារូបរាងឡើង។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមរៀបចំឯកសារដ៏មានតម្លៃនេះ។ យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងក្លាយជាប្រយោជន៍យ៉ាងសំខាន់ដល់អ្នកដែលបានអាន និងប្រើប្រាស់សៀវភៅណែនាំនេះ។

ខ្ញុំមានសេចក្តីសប្បាយរីករាយយ៉ាងខ្លាំង ក្នុងការទទួលយកការបោះពុម្ពផ្សាយនេះមកអនុវត្ត នៅក្នុងមជ្ឈមណ្ឌលធានាគុណភាពរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១៦

**បណ្ឌិត ជេត ជាលី**
**សាកលវិទ្យាធិការ**
**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

# បុព្វកថាពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ការធានាគុណភាពដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងធនធានមនុស្សនៅគ្រឹះស្ថានឧត្តមសិក្សា។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានក្លាយជាសមាជិកនៃបណ្ដាញសាកលវិទ្យាល័យអាស៊ាន (AUN) តាំងពីឆ្នាំ២០០៩ បាន និងកំពុងចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់បណ្ដាញសាកលវិទ្យាល័យអាស៊ាន និងបានទទួលអត្ថប្រយោជន៍ពីការចែករំលែកនៃការអនុវត្តដ៏ល្អៗពីសាកលវិទ្យាល័យជាសមាជិកផ្សេងៗទៀត។

ផ្លែផ្កាដែលកើតឡើងពីសហប្រតិបត្តិការរវាងបណ្ដាញសាកលវិទ្យាល័យអាស៊ាន និងធនាគារអភិវឌ្ឍន៍អាស៊ីតាំងពីឆ្នាំ២០១៤ បានផ្ដល់លទ្ធផលនៅក្នុងការអភិវឌ្ឍ "**សៀវភៅណែនាំស្ដីពីការគ្រប់គ្រងគុណភាពកម្រិតកម្មវិធីអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**"។ តាមរយៈការប្រជុំគម្រោងរៀបចំឯកសារនៃបណ្ដាញសាកលវិទ្យាល័យអាស៊ាន និងធនាគារអភិវឌ្ឍន៍អាស៊ីនៅខែកក្កដា ឆ្នាំ២០១៤ និងខែកញ្ញា ឆ្នាំ២០១៥កន្លងមក ក្រុមការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយមានជំនួយពីលោក Johson Ong Chee Bin បានរួមចំណែកយ៉ាងសកម្មក្នុងរៀបចំឯកសារនៃការអនុវត្តការធានាគុណភាពនៅក្នុងសៀវភៅនេះ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងបម្រើជាឯកសារយោងដ៏មានប្រយោជន៍ និងជំរុញឲ្យសាកលវិទ្យាល័យផ្សេងៗទៀតនៅកម្ពុជា ខិតខំលើកកម្ពស់ក្នុងការធានាគុណភាពនៃឧត្តមសិក្សា និងចូលរួមចំណែកជាវិជ្ជមានក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រទេស។ ខ្ញុំជឿជាក់យ៉ាងពិតប្រាកដថា ការគ្រប់គ្រងគុណភាពនឹងធ្វើឲ្យសាកលវិទ្យាល័យកាន់តែខ្លាំងឡើងៗ និងបំពេញតម្រូវការទីផ្សារការងារនាថ្ងៃអនាគត ដែលកំពុងតែរីកដុះដាលកាន់តែច្រើនឡើងៗ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រដល់លោក Johnson Ong Chee Bin ដែលជាអ្នកជំនាញការនៃបណ្ដាញសាកលវិទ្យាល័យអាស៊ាន លេខាធិការដ្ឋាននៃបណ្ដាញសាកលវិទ្យាល័យអាស៊ាន ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងក្រុមការងារចងក្រងឯកសាររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងការខិតខំបង្កើតឲ្យមានសៀវភៅដ៏មានសារៈប្រយោជន៍នេះ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦

**បណ្ឌិត លុយ ចណ្ណា**

**សាកលវិទ្យាធិការ**

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## បុព្វកថាពីបណ្តាញសាកលវិទ្យាល័យអាស៊ាន

ផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN-QA) គឺជាប្រព័ន្ធធានាគុណភាពឧត្តមសិក្សា និងការអនុវត្តរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN)។ ផ្នែកនេះមានគោលការណ៍ប្រតិបត្តិប្រកបដោយប្រសិទ្ធភាព គឺផ្តល់អានុភាពឲ្យសាកលវិទ្យាល័យនានា និងបុគ្គលិកគ្រប់គ្រងរបស់សាកលវិទ្យាល័យចេះបង្កើត អភិវឌ្ឍ និងបន្តធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធធានាគុណភាពរបស់ខ្លួនតាមរយៈការបង្កើតឯកសារ ការពង្រឹងសមត្ថភាព និងការវាយតម្លៃគុណភាព។

សៀវភៅណែនាំនេះគឺជាផ្លែផ្កានៃកិច្ចសហការរវាងបណ្តាញសាកលវិទ្យាល័យអាស៊ាន និងការចូលរួមរបស់បណ្តាសាកលវិទ្យាល័យនៃប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា (CLM) ក្រោមមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ការគាំទ្រខាងផ្នែកហិរញ្ញវត្ថុ សម្រាប់សកម្មភាពនានានៃផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន ដែលពាក់ព័ន្ធជាមួយប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ចាប់តាំងពីឆ្នាំ២០១២ ក្រោមប្រធានបទ "សមាហរណកម្មការអប់រំកម្រិតឧត្តមសិក្សាក្នុងអនុតំបន់ទន្លេមេគង្គ និងកសាងបណ្តាញពង្រឹងសមត្ថភាពរបស់គម្រោងប្រព័ន្ធធានាគុណភាពរបស់សាកលវិទ្យាល័យ"។

សៀវភៅណែនាំនេះមានគោលបំណងជួយសាកលវិទ្យាល័យនៃប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក្នុងការអនុវត្តការងារធានាគុណភាពកម្រិតកម្មវិធីនៃបណ្តាញសាកលវិទ្យាល័យ អាស៊ាន។ សៀវភៅណែនាំនេះរៀបចំចងក្រងលក្ខណវិនិច្ឆ័យនៃផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន និងគំនិតសំខាន់ៗ ព្រមទាំងការអនុវត្តផ្សេងនៃផ្នែកធានា គុណភាពតាមរយៈការចូលរួមរបស់សាកលវិទ្យាល័យនៃប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ យើងសង្ឃឹមថាសាកលវិទ្យាល័យផ្សេងៗនឹងអាចរៀនសូត្រពីសាកលវិទ្យាល័យដែលបានចូល រួមកសាងសៀវភៅនោះ និងអាចក្លាយជាអ្នកផ្តល់ "ការអប់រំប្រកបដោយគុណភាព" ដោយ អនុវត្តការគ្រប់គ្រងគុណភាពដ៏មានប្រសិទ្ធភាពសម្រាប់កម្រិតកម្មវិធីរបស់ខ្លួន។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ អ្នកជំនាញខាងផ្នែកធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន លោក Johnson Ong Chee Bin និងក្រុមការងារពីសាកលវិទ្យាល័យ

ភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានរួមចំណែកក្នុងការបង្កើតសៀវភៅណែនាំនេះ។

**សាស្ត្រាចារ្យរងបណ្ឌិត ណាន់តាណា ហ្គាស្យាសេនី**
**នាយកប្រតិបត្តិ**
**បណ្ដាញសាកលវិទ្យាល័យអាស៊ាន**

# សេចក្តីផ្តើម

## ១.គោលបំណង

សៀវភៅ "ណែនាំគោលសម្រាប់ការគ្រប់គ្រងកម្មវិធីអប់រំនានានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ" គឺរៀបចំជាផ្នែកនៃដំណាក់កាលទី៣របស់គម្រោង AUN-ADB ស្តីពីការពង្រឹងសមត្ថភាពលើប្រព័ន្ធធានាគុណភាពសម្រាប់សាកលវិទ្យាល័យសំដៅលើកកម្ពស់គុណភាពអប់រំនៅឧត្តមសិក្សាក្នុងបណ្តាប្រទេសដូចជា កម្ពុជា ឡាវ និងភូមា។

គោលបំណងនៃគម្រោងចងក្រងឯកសារនេះគឺ៖

- លើកកម្ពស់និងពង្រឹងមូលដ្ឋានប្រព័ន្ធគ្រប់គ្រងគុណភាពនៅកម្រិតកម្មវិធីដោយផ្អែកលើលទ្ធផលនៃគម្រោងវាយតម្លៃ ASEAN-QA តាមគ្រឹះស្ថាន
- បង្កើតប្រព័ន្ធឯកសារសម្រាប់ប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានស្រាប់នៅកម្រិតកម្មវិធីដោយផ្អែក AUN-QA តាមគ្រឹះស្ថាន
- ផ្តល់ជាឯកសារយោងរួមមួយសម្រាប់ប្រព័ន្ធគ្រប់គ្រងគុណភាព ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យតាមដាននិងកែលម្អ និង
- ផ្តល់ជាប្រភពរួមមួយសម្រាប់ប្រព័ន្ធគ្រប់គ្រងគុណភាព ការបណ្តុះបណ្តាល ការទំនាក់ទំនង ការរៀបចំស្តង់ដានិងពិនិត្យឡើងវិញ

សៀវភៅ "ណែនាំគោលច្បាប់ដើម"គឺសរសេរជាភាសាអង់គ្លេសដោយប្រើប្រាស់ទម្រង់គំរូទូទៅ ហើយត្រូវបានបកប្រែនិងកែសម្រួលដោយមន្រ្តីផ្នែកធានាគុណភាពដែលបានបណ្តុះបណ្តាលមកពីសាកលវិទ្យាល័យនានាក្នុងបណ្តាកម្ពុជា ឡាវ និងភូមា។ប្រព័ន្ធគ្រប់គ្រងគុណភាពដែលចែងក្នុងសៀវភៅ "ណែនាំគោល" នេះ យកតាមគំរូបោះពុម្ពទី៣របស់ AUN-QA ក្នុងកម្រិតកម្មវិធី។ សៀវភៅ "ណែនាំគោល" នេះរៀបចំជាបីផ្នែកដូចមានបកស្រាយក្នុងរូបភាពទី១៖

**ផ្នែកទី១**
**លក្ខខណ្ឌរបស់ AUN-QA**

**ផ្នែកទី២**
**ការបរិយាយគោលគំនិតសំខាន់ៗ**

**ផ្នែកទី៣**
**ការប្រតិបត្តិជាក់ស្តែង (តាមសាកលវិទ្យាល័យនានា)**

**រូបភាពទី១៖ការរៀបចំសៀវភៅណែនាំ**

## ២.សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច**បានបង្កើតឡើងនៅឆ្នាំ១៩៤៩ ជាវិទ្យាស្ថានជាតិនីតិសាស្រ្តនិងសេដ្ឋកិច្ច ហើយបន្ទាប់មកមានការកែប្រែឈ្មោះជាច្រើនលើកច្រើនសារ ទៅតាមតម្រូវការសង្គមនិងបំរែបំបួលរបបនយោបាយ។ គួតត់សម្គាល់ថាក្នុងឆ្នាំ២០០៣ វិទ្យាស្ថាននេះបានប្រែឈ្មោះថា**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ហើយបានប្រែក្លាយជាគ្រឹះស្ថានរដ្ឋបាលសាធារណៈនៅថ្ងៃទី២៧កក្កដា ២០០៧។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច**បានប្រឹងប្រែងរួមចំណែកអភិវឌ្ឍសង្គមដោយបានបង្កើតធនធានមនុស្សដែលមានសក្តានុពលដើម្បីបំរើសង្គម។ ចាប់ពីឆ្នាំ១៩៨២ដល់ខែកុម្ភៈ២០១៥សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានបណ្តុះបណ្តាលធនធានមនុស្សបម្រើការរដ្ឋនិងឯកជនចំនួន៣៥០៩៥នាក់។

ការអភិវឌ្ឍក្នុងតំបន់បានបង្ហាញសក្តីភាពបំរែបម្រួលក្នុងផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា បរិស្ថាន សង្គមនិងសេដ្ឋកិច្ច ដែលតម្រូវឱ្យគ្រឹះស្ថានឧត្តមសិក្សា ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់និងយកចិត្តទុកដាក់លើគុណភាពអប់រំ ប្រសិទ្ធិភាព ឧត្តមភាព ចរិយាធម៌និងសីលធម៌។ សមាហរណកម្មអាស៊ាន ២០១៥ បានបង្កើនការប្រកួតប្រជែងទីផ្សារពលកម្មដែលឱ្យធនធានមនុស្សមានសមត្ថភាពប្រកួតប្រជែង។ រួមចំណែកអភិវឌ្ឍសង្គមដោយបានបង្កើតធនធានមនុស្សដែលមានសក្តានុពលដើម្បីបំរើសង្គម។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ចមានគោលបំណងប្រក្លាយខ្លួនជាសាកលវិទ្យាល័យឈានមុខដែលទទួលស្គាល់ទាំងក្នុងស្រុកនិងលើឆាកអន្តរជាតិលើការបណ្តុះបណ្តាលប្រកបដោយគុណភាព នវានុវត្តន៍ ស្រាវជ្រាវនិងការបោះពុម្ព។ ធនធានមនុស្សបម្រើការរដ្ឋនិងឯកជនចំនួន៣៥០៩៥នាក់។តារាងបង្ហាញពីរចនាសម្ព័ន្ធមជ្ឈមណ្ឌលធានាគុណភាពរបស់តារាងបង្ហាញពីរចនាសម្ព័ន្ធមជ្ឈមណ្ឌលធានាគុណភាពបង្ហាញក្នុងរូបតាងទី២ខាងក្រោមៈ

## ៣. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ(ស.ភ.ភ.៣)

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** បានចាប់ផ្តើមបើកទ្វារជាលើកដំបូងបង្អស់តាមព្រះរាជក្រមលេខ៣៦៧ ន.ស ចុះ**ថ្ងៃទី១៣ ខែមករា គ.ស១៩៦០**[1] ដែលមានឈ្មោះថា**សាកលវិទ្យាល័យខេមរៈភូមិន្ទ** (Universite Royale Khmere) គឺជាសមិទ្ធផលនៃសម័យសង្គមរាស្ត្រនិយម (១៩៥៥ ដល់ ១៨ មិនា១៩៧០)។ គ្រានោះ សាកលវិទ្យាល័យនេះបានប្រមូលផ្តុំមហាវិទ្យាល័យ៦ ដូចមានជាអាទ៍៖

១.មហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច[2]
២.មហាវិទ្យាល័យវេជ្ជវិទ្យាឱសថកម្ម និងវិទ្យាសាស្ត្រណាបវេជ្ជវិទ្យា[3]
៣.មហាវិទ្យាល័យពាណិជ្ជសាស្ត្រ
៤.មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស[4]
៥.មហាវិទ្យាល័យអក្សរសាស្ត្រ និងសាស្ត្រមនុស្សសាស្ត្រ [5]
៦.វិទ្យាស្ថានគរុកោលស្យ[6] ជាតិ។

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** បានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនជាបន្តបន្ទាប់ទៅតាមរបត់នយោបាយនិងបម្រែបម្រួលក្នុងសង្គមកម្ពុជា។ យោងតាមព្រះរាជក្រមលេខ២២៤ ប.រ ចុះថ្ងៃទី១៨ ខែមករា គ.ស ១៩៦៥[7] **សាកលវិទ្យាល័យខេមរៈភូមិន្ទ** រហូតដល់សម័យសាធារណរដ្ឋខ្មែរក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ដល់ ១៩៧៥ សាកលវិទ្យាល័យ នេះបានប្រែឈ្មោះម្តងទៀតជា **សាកលវិទ្យាល័យភ្នំពេញ** ដោយមានបញ្ចូលសាលាគរុវិជ្ជាជាន់ខ្ពស់បន្ថែមមួយទៀត ហើយមហាវិទ្យាល័យចំណុះមានរហូតដល់ ០៨៖

[1] *យោងតាមឯកសាររាជកិច្ចប្រទេសកម្ពុជាចុះថ្ងៃទី២០មករា១៩៦៥មានតម្កល់ទុកនៅ បណ្ណសារដ្ឋានជាតិ*

[2] *បានផ្តើមចេញពីវិទ្យាស្ថានជាតិសិក្សាច្បាប់តុលាការ នយោបាយ និងសេដ្ឋកិច្ច ដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៤៧ ត្រូវបានពង្រឹងដោយក្រឹត្យលេខ២០១-ន.ស ចុះថ្ងៃទី១៥-៥-១៩៥៣។ ឆ្នាំ១៩៥៧ វិទ្យាល័យជាតិសិក្សាច្បាប់តុលាការនយោបាយ និងសេដ្ឋកិច្ចនេះត្រូវបានផ្លាស់ប្តូរទៅជាមហាវិទ្យាល័យច្បាប់។*

[3] *ពីមុនជាសាលាមន្ត្រីសុខាភិបាលដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៤៦ សម្រាប់បង្រៀនត្រឹមថ្នាក់ក្រោមវេជ្ជបណ្ឌិត ។ ប៉ុន្តែក្រោយបើយោងតាមក្រឹត្យលេខ៥១៣-ន.ស ចុះថ្ងៃ១២-១០-១៩៥៣គឺជាផ្នែកសិល្បៈទន្តសាស្ត្រ។*

[4] *បានបង្កើតតាំងពីឆ្នាំ១៩៥៩ និងពង្រឹងដោយ ព្រះរាជក្រឹត្យឆ្នាំ១៩៦១ ។*

[5] *បានបង្កើតតាំងពីឆ្នាំ១៩៥៩*

[6] *បានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ៤៣៨ ន.ស ចុះថ្ងៃទី ១០-៧-១៩៥៩ ដែលបានដូរឈ្មោះពីសាលាគរុវិជ្ជា ក្រោយមកបានប្តូរឈ្មោះទៅជា មហាវិទ្យាល័យគរុកោសល្យ។*

[7] *បានឡាយព្រះហស្តលេខាដោយសម្តេចនរោត្តមសីហនុ*

១. មហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
២. មហាវិទ្យាល័យវេជ្ជវិទ្យា និងវិទ្យាសាស្ត្របរវេជ្ជវិទ្យា
៣. មហាវិទ្យាល័យវិទ្យាសាស្ត្រ
៤. មហាវិទ្យាល័យអក្សរសាស្ត្រ និងវិទ្យាសាស្ត្រមនុស្សជាតិ
៥. មហាវិទ្យាល័យ ឱសថកម្ម
៦. មហាវិទ្យាល័យ គរុកោលស្ស
៧. មហាវិទ្យាល័យ វិទ្យាសាស្ត្រពាណិជ្ជកម្ម
៨. វិទ្យាស្ថានភាសា

ចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦មករា១៩៧៩ មហាវិនាសកម្មដែលបានបង្កឡើងដោយរបបប្រល័យពូជសាសន៍ខ្មែរក្រហមបានប្រែក្លាយសាកលវិទ្យាល័យនេះឱ្យទៅជាទីរហោឋានហើយបានបិទទ្វារទាំងស្រុង។

នៅថ្ងៃទី១៣ឧសភា១៩៨០ ក្រសួងអប់រំបានបើកដំណើរការសាលាគរុវិជ្ជាជាន់ខ្ពស់ ដែលជាគ្រឹះស្ថានកម្រិតឧត្តមសិក្សាមុនគេបង្អស់ប៉ុន្តែបង្រៀនជាភាសាបារាំង។បន្ទាប់មកសាលាភាសាក៏ត្រូវបានបង្កើតឡើងសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនភាសាវៀតណាមនិងភាសារុស្ស៊ី។គ្រឹះស្ថានទាំងពីរមហាវិទ្យាល័យនេះ ផ្តោតលើការបណ្តុះបណ្តាលគ្រូបង្រៀនជាចំបង ដើម្បីរួមចំណែកកសាងវិស័យអប់រំនៅកម្ពុជា។

យោងតាមអនុក្រឹត្យលេខ០៨អន.ក្រដែលចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ១៩៨៨បានសម្រេចបង្កើតសាកលវិទ្យាល័យរដ្ឋដោយផ្អែកលើមូលដ្ឋានសាលាគរុវិជ្ជាជាន់ខ្ពស់និងសាលាភាសាដោយដាក់ឈ្មោះថា**សាកលវិទ្យាល័យភ្នំពេញ**។ ក្រោយមក**សាកលវិទ្យាល័យភ្នំពេញ** បានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនជាចុងក្រោយមកជា**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ដោយយោងតាមអនុក្រឹត្យលេខ៣១អនក្រ.បក ដែលចុះថ្ងៃទី២១ ខែ មិថុនាឆ្នាំ១៩៩៦ ក្នុងគោលបំណងប្រែក្លាយជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខនៅកម្ពុជា ដោយផ្តោតលើឧត្តមភាពនៃការរៀន និងបង្រៀន និងជំរុញឱ្យមានការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍប្រទេសនិងលើកម្ពស់សង្គមកម្ពុជា។

តារាងបង្ហាញពីរចនាសម្ព័ន្ធមជ្ឈមណ្ឌលធានាគុណភាពក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

**រូបភាពទី៣៖ រចនាសម្ព័ន្ធមជ្ឈមណ្ឌលធានាគុណភាព**




### ៤. គំរូការណែនាំគុណភាពរបស់ AUN-QA ក្នុងកម្រិតកម្មវិធី

AUN ទទួលស្គាល់ពីសារៈសំខាន់នៃគុណភាពក្នុងកម្រិតឧត្តមសិក្សា និងតម្រូវការចាំបាច់អភិវឌ្ឍប្រព័ន្ធធានាគុណភាពទាំងមូល ដើម្បីលើកកម្ពស់ស្តង់ដាការសិក្សានិងការអប់រំ ការស្រាវជ្រាវ និងសេវាកម្មរបស់សាកលវិទ្យាល័យនានាក្នុងអាស៊ាន។ គំរូការណែនាំគុណភាពរបស់ AUN-QA ក្នុងកម្រិតកម្មវិធី រួមមានយុទ្ធសាស្ត្រ លក្ខណៈប្រព័ន្ធ និងយុទ្ធវិធីដោះស្រាយនានា ដែលស្របតាមក្របខណ្ឌធានាគុណភាពទាំងក្នុងតំបន់និងអន្តរជាតិ (**រូបភាពទី៤**)។




**រូបភាពទី៤៖គំរូការណែនាំគុណភាពរបស់ AUN-QA សម្រាប់ឧត្តមសិក្សា**

គំរូការណែនាំគុណភាពរបស់ AUN-QA ក្នុងកម្រិតកម្មវិធី (ទម្រង់គំរូទី៣) រៀបចំផ្អែកលើតម្រូវការរបស់ផ្នែកពាក់ព័ន្ធ(រូបទី៥)។ តម្រូវការទាំងនេះ បង្កើតបានជាលទ្ធផលសិក្សារំពឹងទុកដែលឆ្លើយតបតាមកម្មវិធី(ខ្ទង់ទី១)។ ក្នុងរូបភាពនេះគឺមាន៤ជួរ ក្នុងជួរកណ្តាលនិងជួរទី១នៃគំរូនេះបង្ហាញថាតើលទ្ធផលសិក្សារំពឹងទុកបំពេញបកស្រាយក្នុងកម្មវិធីសិក្សាមួយបែបណា ហើយបង្ហាញថាត្រូវវាយតម្លៃបែបម៉េច រៀននិងបង្រៀនយ៉ាងម៉េចទើបអាចសម្រេចបានលទ្ធផលសិក្សារំពឹងទុកទាំងអស់នោះ។

ជួរទី២ ចាត់ទុកថាជា″ធាតុចូល″ ក្នុងដំណើរការប្រតិបត្តិ ដែលរាប់បញ្ចូលទាំងសាស្ត្រាចារ្យ បុគ្គលិកគាំទ្រ គុណភាពនិស្សិតនិងការការគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈរូបវន្ត។

ជួរទី៣ បង្ហាញពីការកើនឡើងនៃគុណភាពរបស់កម្មវិធីសិក្សាដែលគ្របដណ្តប់លើការរៀបចំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា ការរៀននិងការបង្រៀន ការវាយតម្លៃនិស្សិត គុណភាពសេវាកម្មគាំទ្រនិងសម្ភារៈរូបវន្ត ព្រមទាំងមតិត្រឡប់របស់ផ្នែកពាក់ព័ន្ធ។

ជួរទី៤ ផ្តោតទៅលើធាតុចេញនៃកម្មវិធីសិក្សាដែលរាប់បញ្ចូលអត្រាប្រឡងចេញនិងអត្រាបោះបង់ចោលការសិក្សា រយៈពេលបញ្ចប់កាសិក្សាជាមធ្យម លទ្ធភាពស្វែងរកការងាររបស់និស្សិត សកម្មភាពស្រាវជ្រាវ និងការពេញចិត្តរបស់ផ្នែកពាក់ព័ន្ធ។

ខ្ទង់ចុងក្រោយបង្ហាញជោគជ័យនៃលទ្ធផលរំពឹងទុក និងកម្មវិធី។

គំរូនេះបញ្ចប់ដោយការបំពេញឱ្យសេចក្តីត្រូវការរបស់ផ្នែកពាក់ព័ន្ធនិងបន្តការកែលម្អរបស់ប្រព័ន្ធធានាគុណភាព ហើយត្រូវស្របតាមខ្នាតមាត្រដ្ឋានដើម្បីស្វែងរកការប្រតិបត្តិដែលល្អបំផុត។




Figure 5 – AUN-QA Model for Programme Level (3rd Version)
**រូបភាពទី៥៖**គំរូការណែនាំគុណភាពរបស់ AUN-QA ក្នុងកម្រិតកម្មវិធី (ទម្រង់គំរូទី៣)

ទម្រង់ទី៣នៃគំរូការណែនាំគុណភាពរបស់ AUN-QA ក្នុងកម្រិតកម្មវិធីបង្កើតឡើងដោយមានលក្ខណៈវិនិច្ឆ័យចំនួន១១៖

១.លទ្ធផលសិក្សារំពឹងទុក

២.កម្មវិធីលម្អិត

៣.រចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្មវិធី

៤.យុទ្ធវិធីបង្រៀន និងរៀន

៥.ការវាយតម្លៃនិស្សិត

៦.គុណភាពនៃបុគ្គលិកសិក្សា

៧.គុណភាពបុគ្គលិកគាំទ្រ

៨.គុណភាព និងការគាំទ្រនិស្សិត

៩.សម្ភារៈបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធ

១០.ការលើកកម្ពស់គុណភាព

១១.ធាតុចេញ

ក្នុងជំពូកបន្តបន្ទាប់គឺរាល់លក្ខខណ្ឌរបស់លក្ខណៈវិនិច្ឆ័យ AUN-QA បានបញ្ចូលទៅក្នុងប្រអប់។ ដើម្បីសម្រួលការអនុវត្តនិងការវាយតម្លៃនៃលក្ខណៈវិនិច្ឆ័យនីមួយៗ បញ្ជីសេចក្តីអំណះអំណាងនៃលក្ខណៈវិនិច្ឆ័យនីមួយៗ ត្រូវបានពន្យល់ជាលក្ខណៈវិនិច្ឆ័យរងដែលដាក់ចូលក្នុងបញ្ជីផ្ទៀងផ្ទាត់។ តួលេខដែលនៅក្នុងរង្វង់ក្រចក [ ] ក្នុងផ្នែកលក្ខណៈវិនិច្ឆ័យរងបង្ហាញពីសេចក្តីអំណះអំណាងដែលត្រូវគ្នាក្នុងប្រអប់ A។ បញ្ជីផ្ទៀងផ្ទាត់ពេញលេញនៃលក្ខណៈវិនិច្ឆ័យ AUN-QA ក្នុងកម្រិតកម្មវិធីគឺបានចងក្រងជាឯកសារក្នុឧបសម្ព័ន្ធទី១។

ការវាយតម្លៃការធានាគុណផ្ទៃក្នុងកំណត់ការដាក់ពិន្ទុលើកម្រិតខ្នាតពិន្ទុ៧ (ផ្អែកលើ AUN-QA)។ ខ្នាតនេះផ្តល់ឲ្យសាកលវិទ្យាល័យ និងអ្នកវាយតម្លៃគុណភាពនូវឧបករណ៍សម្រាប់ដាក់ពិន្ទុលើសេចក្តីសម្រេចនានា និងមើលឃើញថាការប្រតិបត្តិទាំងនោះមានការវិវត្តយ៉ាងណាក្នុងកម្រិតពិន្ទុពី១ដល់៧ ។ កម្រិតខ្នាតពិន្ទុ៧បង្ហាញនៅក្នុងតារាងខាងក្រោមៈ

| កម្រិតពិន្ទុ | ការពិពណ៌នា |
|---|---|
| 1 | **មិនគ្រប់គ្រាន់ទាំងស្រុង**<br>បទពិសោធន៍ការ ធានាគុណភាពដើម្បីបំពេញលក្ខណវិនិច្ឆ័យគឺមិនគ្រប់គ្រាន់។ មិនមានផែនការ ឯកសារ ភស្តុតាង ឬលទ្ធផលបង្ហាញ។ ការធ្វើឲ្យប្រសើរឡើងភ្លាមៗត្រូវបានចាត់វិធានការ។ |
| 2 | **មិនគ្រប់គ្រាន់ និងត្រូវការការធ្វើឲ្យប្រសើរឡើង**<br>បទពិសោធន៍ការធានគុណភាពដើម្បីបំពេញ លក្ខណវិនិច្ឆ័យស្ថិតនៅក្នុងដំណាក់ការធ្វើផែនការ ឬមិនគ្រប់គ្រាន់ដែលការធ្វើឲ្យប្រសើរ ឡើងត្រូវការចាំបាច់។ មានឯកសារ ឬភស្តុតាងបន្តិចបន្តួច។ ការអនុវត្តនៃបទពិសោធន៍ ការធានាគុណភាពបង្ហាញលទ្ធផលតិចតួច ឬខ្សោយ។ |
| 3 | **មិនគ្រប់គ្រាន់ ប៉ុន្តែការធ្វើឲ្យប្រសើរបន្តិចទៀតនឹងធ្វើឲ្យទៅជាគ្រប់គ្រាន់**<br>បទពិសោធន៍ការធានាគុណភាពដើម្បីលក្ខណវិនិច្ឆ័យត្រូវបានកំណត់ និងអនុវត្ត ប៉ុន្តែការធ្វើឲ្យប្រសើរបន្តិចទៀតត្រូវការដើម្បីបំពេញលក្ខណវិនិច្ឆ័យនោះ។ ឯកសារអាច រកបាន ប៉ុន្តែមិនមានភស្តុតាងច្បាស់លាស់ដើម្បីគាំទ្រថាឯកសារទាំងនោះត្រូវបានប្រើប្រាស់ ពេញលេញ។ ការអនុវត្តនៃបទពិសោធន៍ការធានាគុណភាពបង្ហាញពីលទ្ធផលខ្លះ ឬ លទ្ធផលមិនមានសង្គតិភាព។ |
| 4 | **គ្រប់គ្រាន់ដូចរំពឹងទុក**<br>បទពិសោធន៍ការធានាគុណភាពដើម្បីបំពេញលក្ខណវិនិច្ឆ័យគឺគ្រប់គ្រាន់ ហើយភស្តុ |

| | |
|---|---|
| | តាង បង្ហាញថាលក្ខណវិនិច្ឆ័យនោះត្រូវបានអនុវត្តពេញលេញ។ ការអនុវត្តនៃបទពិសោធន៍ការ ធានាគុណភាពបង្ហាញពីលទ្ធផលមានសង្គតិភាពដូចរំពឹងទុក។ |
| 5 | **ប្រសើរជាងការរំពឹងទុក**<br>បទពិសោធន៍ការធានាគុណភាពដើម្បីបំពេញលក្ខណវិនិច្ឆ័យគឺប្រសើរជាងការរំពឹងទុក។ ភស្តុតាងបង្ហាញថាលក្ខណវិនិច្ឆ័យត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធផល។ ការអនុវត្តនៃ បទពិសោធន៍ការធានាគុណភាពបង្ហាញពីលទ្ធផលល្អ និងនិន្នាការធ្វើឲ្យប្រសើរឡើងមាន លក្ខណៈវិជ្ជមាន។ |
| 6 | **ឧទាហរណ៍នៃគំរូ**<br>បទពិសោធន៍ការធានាគុណភាពដើម្បីបំពេញលក្ខណវិនិច្ឆ័យត្រូវបានចាត់ទុកជា ឧទាហរណ៍នៃគំរូនៅក្នុងវិស័យនេះ។ ភស្តុតាងបង្ហាញថាលក្ខណវិនិច្ឆ័យនេះត្រូវបាន អនុវត្តយ៉ាងមានប្រសិទ្ធផល។ ការអនុវត្តនៃបទពិសោធន៍ការធានាគុណភាពបង្ហាញពី លទ្ធផលដ៏ល្អ និងនិន្នាការធ្វើឲ្យប្រសើរឡើងមានលក្ខណៈវិជ្ជមាន។ |
| 7 | **ល្អឥតខ្ចោះ (ឧទាហរណ៍នៃចំណាត់ថ្នាក់ពិភពលោក ឬគំរូឈានមុខគេបំផុត)**<br>បទពិសោធន៍ការធានាគុណភាពដើម្បីបំពេញលក្ខណវិនិច្ឆ័យត្រូវបានចាត់ទុកថាល្អឥតខ្ចោះ ឬជាឧទាហរណ៍នៃចំណាត់ថ្នាក់ពិភពលោកនៅក្នុងវិស័យនេះ។ ភស្តុតាងបង្ហាញថា លក្ខណវិនិច្ឆ័យត្រូវបានអនុវត្តប្រកបដោយនិវានុវត្ត។ ការអនុវត្តបទពិសោធន៍ការធានា គុណភាពបង្ហាញពីលទ្ធផលល្អឥតខ្ចោះ និងនិន្នាការធ្វើឲ្យប្រសើរឡើងមានលក្ខណៈ ឈានមុខគេ។ |

សម្គាល់៖ នៅក្នុងការកំណត់កម្រិតពិន្ទុទៅនឹងលក្ខណវិនិច្ឆ័យរង គួរប្រើចំនួនគត់។ លទ្ធផលសរុបនៃ ការវាយតម្លៃគួរត្រូវបានគណនាផ្អែកលើមធ្យមភាគនព្វន្ធនៃលក្ខណវិនិច្ឆ័យទាំង១១ ដោយមាន ក្បៀស ១ខ្ទង់។

## បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការវាយតម្លៃគុណភាពឧត្តមសិក្សាកម្រិតកម្មវិធី

| 1 | លទ្ធផលសិក្សាដែលរំពឹងទុក | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 1.1 | លទ្ធផលសិក្សាដែលរំពឹងទុកត្រូវបានបង្ហាញច្បាស់លាស់និងត្រូវបានបកស្រាយក្នុងកម្មវិធីបណ្តុះបណ្តាល[1,2] | | | | | | | |
| 1.2 | លទ្ធផលសិក្សាដែលរំពឹងទុកគ្របដណ្តប់ទាំងលើចំណេះដឹងរួមនិងជំនាញឯកទេស[ឧ.ដែលអាចផ្ទេរ]នៃលទ្ធផលសិក្សាចុងក្រោយ [3] | | | | | | | |
| 1.3 | លទ្ធផលសិក្សាដែលរំពឹងទុកឆ្លើយតបនឹងតម្រូវការច្បាស់លាស់របស់អ្នកពាក់ព័ន្ធនានា [4] | | | | | | | |
| **Overall Opinion** យោបល់រួម | | | | | | | | |
| 2 | កម្មវិធីលម្អិត | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 2.1 | ព័ត៌មាននៅក្នុងចំណុចលម្អិតនៃកម្មវិធីគឺទូលំទូលាយ និង ទាន់សម័យ [1, 2] | | | | | | | |
| 2.2 | ព័ត៌មានលម្អិតនៅក្នុងមុខវិជ្ជាគឺទូលំទូលាយ និងទាន់សម័យ [1, 2] | | | | | | | |
| 2.3 | ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជាត្រូវបានធ្វើឲ្យមានទំនាក់ ទំនងនិងឲ្យបានដល់ភាគីពាក់ព័ន្ធ | | | | | | | |
| យោបល់រួម | | | | | | | | |
| 3 | រចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្មវិធី | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 3.1 | កម្មវិធីសិក្សារៀបចំតម្រង់ទិសស្របតាមលទ្ធផលរំពឹងទុក [1] | | | | | | | |
| 3.2 | មុខវិជ្ជានីមួយៗរួមចំណែកធ្វើឲ្យសម្រេចលទ្ធផលសិក្សាដែលរំពឹងទុកបានច្បាស់លាស់ [2] | | | | | | | |
| 3.3 | កម្មវិធីសិក្សាបង្កើតឡើងសមហេតុផល តាមលំដាប់លំដោយ ហើយត្រូវបានច្របាច់បញ្ចូលគ្នានិងទាន់សម័យ [3, 4, 5, 6] | | | | | | | |
| យោបល់រួម | | | | | | | | |
| 4 | យុទ្ធវិធីបង្រៀន និងរៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 4.1 | ទស្សនវិជ្ជាអប់រំត្រូវបានផ្សារភ្ជាប់ទៅគ្រប់ភាគីពាក់ព័ន្ធ [1] | | | | | | | |
| 4.2 | សកម្មភាពបង្រៀន និងរៀនត្រូវបានធ្វើឲ្យស្របទៅ នឹងការសម្រេចបាននៃលទ្ធផលសិក្សារំពឹងទុក [2, 3, 4, 5] | | | | | | | |
| 4.3 | សកម្មភាពបង្រៀន និងរៀនលើកកម្ពស់ការសិក្សាពេញមួយជីវិត [6] | | | | | | | |
| យោបល់រួម | | | | | | | | |
| 5 | ការវាយតម្លៃនិស្សិត | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 5.1 | ការវាយតម្លៃនិស្សិតត្រូវជាប្រយោជន៍សមស្របតាមជោគជ័យនៃលទ្ធផលសិក្សារំពឹងទុក[1, 2] | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **5.2** | ការវាយតម្លៃនិស្សិតត្រូវតែផ្តល់ឲ្យនិស្សិតបានយល់ដឹងពី ការកំណត់ពេលវេលា វិធីសាស្រ្ត បទប្បញ្ញត្តិ ទម្ងន់ខ្លឹមសារវិញ្ញាសា និងកម្រិតពិន្ទុទៅតាមការបរិយាយនិទ្ទេសបទឲ្យបានច្បាស់លាស់ [4, 5] | | | | | | | |
| **5.3** | វិធីសាស្រ្តវាយតម្លៃនានាត្រូវមានបរិយាយនិទ្ទេសបទនៃការវាយតម្លៃ ទម្រង់ផ្តល់ពិន្ទុ ដើម្បីធានាសុពលភាព មានទំនុកចិត្ត និងយុត្តិធម៌ដល់ការវាយតម្លៃនិស្សិត [6, 7] | | | | | | | |
| **5.4** | ផលទទួលបានពីការវាយតម្លៃគឺជាឱកាសជួយកែសម្រួលដល់ការសិក្សា[3] | | | | | | | |
| **5.5** | Students have ready access to appeal procedure [8]<br>និស្សិតមានឱកាសរៀបចំនីតិវិធីបណ្តឹងតវ៉ា[8] | | | | | | | |
| **យោបល់រួម** | | | | | | | | |
| **6** | **គុណភាពនៃបុគ្គលិកសិក្សា** | **1** | **2** | **3** | **4** | **5** | **6** | **7** |
| **6.1** | ការរៀបចំផែនការបុគ្គលិកសិក្សា(ពិចារណាទៅលើការស្នងតំណែង ការដំឡើងឋានៈ ការប្រគល់ការងារឲ្យធ្វើជាថ្មី ការ បញ្ចប់ការងារ និងការចូលនិវត្ត) ត្រូវបានអនុវត្តដើម្បីបំពេញ តម្រូវការសម្រាប់ការអប់រំ ការស្រាវជ្រាវ និងសេវា [1] | | | | | | | |
| **6.2** | អត្រាបុគ្គលិកនិងនិស្សិត និងទំហំការងារត្រូវបានវាស់ និង ពិនិត្យតាមដាន ដើម្បីធ្វើឲ្យប្រសើរឡើងគុណភាពនៃការអប់រំ ការស្រាវជ្រាវ និងសេវា [2] | | | | | | | |
| **6.3** | លក្ខណវិនិច្ឆ័យជ្រើសរើសរួមបញ្ចូលក្រមសីលធម៌ និងសេរី ភាពនៃការសិក្សាសម្រាប់ការតែងតាំង ការបង្គាប់ការ និង ការដំឡើងឋានៈ ត្រូវបានកំណត់ និងធ្វើឲ្យមានទំនាក់ទំនង [4, 5, 6, 7] | | | | | | | |
| **6.4** | សមត្ថភាពបុគ្គលិកសិក្សាត្រូវបានបញ្ជាក់ និងវាយតម្លៃ [3] | | | | | | | |
| **6.5** | តម្រូវការនៃការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក សិក្សា ត្រូវបានបញ្ជាក់ ហើយសកម្មភាពទាំងឡាយត្រូវបាន អនុវត្តដើម្បីបំពេញតម្រូវការទាំងអស់នោះ | | | | | | | |
| **6.6** | ការគ្រប់គ្រងការអនុវត្ត ដែលរួមបញ្ចូលការផ្តល់រង្វាន់ និងការទទួលស្គាល់ត្រូវបាន អនុវត្តដើម្បីលើកជំរុញ និងគាំទ្រការអប់រំ ការស្រាវជ្រាវ និងសេវា [9] | | | | | | | |
| **6.7** | ប្រភេទ និងបរិមាណនៃសកម្មភាពស្រាវជ្រាវដោយបុគ្គលិក សិក្សាត្រូវបានបង្កើតឡើង ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ ដោយយកករណីរបស់គេពិនិត្យ សម្រាប់ធ្វើឲ្យប្រសើរឡើង [10] | | | | | | | |
| **យោបល់រួម** | | | | | | | | |

| 7 | គុណភាពបុគ្គលិកគាំទ្រ | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 7.1 | បង្កើតផែនការសម្រាប់បុគ្គលិកគាំទ្រ(នៅតាមបណ្ណាល័យ បន្ទប់ពិសោធន៍ សម្ភារៈបរិក្ខាព័ត៌មានវិទ្យានិងសេវានិស្សិត) ដើម្បីបំពេញឲ្យតម្រូវការសម្រាប់ការអប់រំ ការស្រាវជ្រាវនិងសេវានានា[1] | | | | | | | |
| 7.2 | លក្ខខណ្ឌជ្រើសរើសសម្រាប់ការតែងតាំង ការប្រគល់ការងារ និងការតម្លើងឋានៈត្រូវមានការកំណត់និងចរចារ[2] | | | | | | | |
| 7.3 | សមត្ថភាពរបស់បុគ្គលិកគាំទ្រត្រូវបាបញ្ជាក់និងវាយតម្លៃ[3] | | | | | | | |
| 7.4 | តម្រូវការបណ្ដុះបណ្ដាលនិងអភិវឌ្ឍន៍របស់បុគ្គលិកគាំទ្រត្រូវបានបញ្ជាក់និងសកម្មភាពនានាត្រូវបានអនុវត្តដើម្បីបំពេញតម្រូវការទាំងនោះ[4] | | | | | | | |
| 7.5 | ស្នាដៃគ្រប់គ្រងរួមមានរង្វាន់និងការទទួលស្គាល់ត្រូវបានអនុវត្តដើម្បីលើកទឹកចិត្តនិងគាំទ្រការអប់រំ ការស្រាវជ្រាវ និងសេវានានា | | | | | | | |
| យោបល់រួម | | | | | | | | |
| 8 | គុណភាព និងការគាំទ្រនិស្សិត | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8.1 | គោលនយោបាយជំនាន់និស្សិត និងលក្ខខណ្ឌចូលរៀនត្រូវ បានកំណត់ ធ្វើឲ្យមានទំនាក់ទំនង បោះពុម្ពផ្សាយ និងទាន់ សម័យ [1] | | | | | | | |
| 8.2 | វិធី និងលក្ខខណ្ឌជ្រើសរើសនិស្សិតត្រូវបានកំណត់ និងវាយ តម្លៃ [2] | | | | | | | |
| 8.3 | មានប្រព័ន្ធពិនិត្យតាមដានគ្រប់គ្រាន់សម្រាប់ការរីកចម្រើន របស់និស្សិត ការអនុវត្តការសិក្សា និងទំហំការងារ [3] | | | | | | | |
| 8.4 | ដំបូន្មានសិក្សា សកម្មភាពកម្មវិធីសិក្សារួមគ្នា ការប្រកួត ប្រជែងនិស្សិត និងសេវាគាំទ្រនិស្សិតផ្សេងទៀត អាចមាន ដើម្បីធ្វើឲ្យប្រសើរឡើងការរៀន និងភាពមានការងារធ្វើ [4] | | | | | | | |
| 8.5 | បរិស្ថានរូបវន្ត សង្គម និងចិត្តសាស្ត្រគឺអំណោយផលចំពោះ ការអប់រំ និងការស្រាវជ្រាវ ព្រមទាំងសុខុមាលភាពផ្ទាល់ខ្លួន [5] | | | | | | | |
| យោបល់រួម | | | | | | | | |
| 9 | សម្ភារៈបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| 9.1 | ឧបករណ៍ និងសម្ភារៈបរិក្ខាបង្រៀន និងរៀន (សហសាល សិក្សាបន្ទប់សិក្សា បន្ទប់រៀបចំគម្រោង។ល។) គ្រប់គ្រាន់ និង ត្រូវបានធ្វើទំនើបកម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [1] | | | | | | | |
| 9.2 | បណ្ណាល័យ និងធនធានរបស់វាគ្រប់គ្រាន់ និងត្រូវបានធ្វើ ទំនើបកម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [3, 4] | | | | | | | |
| 9.3 | បន្ទប់ពិសោធន៍ និងឧបករណ៍គ្រប់គ្រាន់ និងត្រូវបានធ្វើ ទំនើបកម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [1. 2] | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **9.4** | សម្ភារៈបរិក្ខាបច្ចេកវិទ្យាព័ត៌មានដែលរួមមានហេដ្ឋារចនា សម្ព័ន្ធ សិក្សាអេឡិចត្រូនិកគ្រប់គ្រាន់ និងត្រូវបានធ្វើទំនើប កម្មដើម្បីគាំទ្រ ការអប់រំ និងការស្រាវជ្រាវ [1, 5, 6] | | | | | | | |
| **9.5** | ស្តង់ដាបរិស្ថាន សុខភាព និងសុវត្ថិភាព ព្រមទាំងការអាច ទទួល បានពីស្តង់ដាទាំងនេះសម្រាប់អ្នកដែលមានតម្រូវការ ពិសេសត្រូវ បានកំណត់ និងអនុវត្ត [7] | | | | | | | |
| **យោបល់រួម** | | | | | | | | |
| **10** | **ការបង្កើនគុណភាព** | **1** | **2** | **3** | **4** | **5** | **6** | **7** |
| **10.1** | យោបល់ត្រឡប់ និងតម្រូវការរបស់ភាគីពាក់ព័ន្ធបម្រើជា ធាតុចូល ចំពោះការអភិវឌ្ឍ និងការបង្កើតកម្មវិធីសិក្សា [1] | | | | | | | |
| **10.2** | ដំណើរការអភិវឌ្ឍ និងបង្កើតកម្មវិធីសិក្សាត្រូវបានបង្កើត ឡើង និង ជាកម្មវត្ថុនៃការវាយតម្លៃ និងបង្កើនគុណភាព [2] | | | | | | | |
| **10.3** | ដំណើរការនៃការបង្រៀន និងរៀន និងការវាយតម្លៃនិស្សិត ត្រូវបាន ពិនិត្យឡើងវិញ និងវាយតម្លៃជាបន្តដើម្បីធានាភាព ស្របគ្នា និង ភាពសំខាន់របស់វា [3] | | | | | | | |
| **10.4** | ធាតុចូលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីបង្កើនការបង្រៀន និង ការរៀន [4] | | | | | | | |
| **10.5** | គុណភាពនៃសម្ភារៈបរិក្ខា និងសេវាគាំទ្រ (នៅបណ្ណាល័យ មន្ទីរ ពិសោធ សម្ភារៈបរិក្ខាព័ត៌មានវិទ្យា និងសេវានិស្សិត) ត្រូវជាកម្មវត្ថុ នៃការវាយតម្លៃ និងការបង្កើនគុណភាព [5] | | | | | | | |
| **10.6** | យន្តការទទួលយោបល់ត្រឡប់របស់ភាគីពាក់ព័ន្ធមានជា ប្រព័ន្ធ និងជាកម្មវត្ថុនៃការវាយតម្លៃ និងការបង្កើនគុណភាព [6] | | | | | | | |
| **យោបល់រួម** | | | | | | | | |
| **11** | **ធាតុចេញ** | **1** | **2** | **3** | **4** | **5** | **6** | **7** |
| **11.1** | អត្រាប្រឡងជាប់ និងអត្រាបោះបង់ចោលការសិក្សាត្រូវ បានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ ការធ្វើឲ្យប្រសើរ ឡើង [1] | | | | | | | |
| **11.2** | ពេលវេលាជាមធ្យមក្នុងការបញ្ចប់ការសិក្សាត្រូវបានបង្កើត ពិនិត្យ តាមដាន និងប្រៀបធៀបជាគោលសម្រាប់ការធ្វើឲ្យ ប្រសើរឡើង [1] | | | | | | | |
| **11.3** | ភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សាត្រូវបាន បង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ការ ធ្វើឲ្យប្រសើរ ឡើង [1] | | | | | | | |
| **11.4** | ប្រភេទ និងបរិមាណសកម្មភាពស្រាវជ្រាវដោយនិស្សិតត្រូវ បាន | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | បង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ ការធ្វើឲ្យប្រសើរឡើង [2] | | | | | | | | |
| **11.5** | កម្រិតពេញចិត្តរបស់ភាគីពាក់ព័ន្ធត្រូវបានបង្កើត ពិនិត្យតាម ដាន និងប្រៀបធៀបជាគោលសម្រាប់ការធ្វើឲ្យប្រសើរឡើង [3] | | | | | | | | |
| **យោបល់រួម** | | | | | | | | | |

**សម្គាល់៖** នៅក្នុងការកំណត់កម្រិតពិន្ទុទៅនឹងលក្ខណវិនិច្ឆ័យរង គួរប្រើចំនួនគត់។ លទ្ធផលសរុបនៃ ការវាយតម្លៃគួរត្រូវបានគណនាផ្អែកលើមធ្យមភាគនព្វន្ធនៃលក្ខណវិនិច្ឆ័យទាំង១១ ដោយមានក្បៀស ១ខ្ទង់។

## *១. លក្ខណវិនិច្ឆ័យ១ ៖ លទ្ធផលសិក្សារំពឹងទុក*

*១. ការរៀបចំបង្កើតលទ្ធផលសិក្សារំពឹងទុកត្រូវពិចារណានិងឆ្លុះបញ្ចាំងពីចក្ខុវិស័យ និងបេសកកម្មរបស់គ្រឹះស្ថាន។ ចក្ខុវិស័យ និងបេសកកម្មនេះត្រូវតែច្បាស់លាស់ដែលបុគ្គលិកនិងនិស្សិតគ្រប់ៗគ្នាបានដឹងឮ។*

*២. កម្មវិធីបង្ហាញលទ្ធផលសិក្សារំពឹងទុករបស់និស្សិត។ មុខវិជ្ជានិងមេរៀននីមួយៗគួររៀបចំឲ្យបានច្បាស់លាស់ដើម្បីសម្រេចបានលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជានិងមេរៀននោះដែលស្របតាមលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធី។*

*៣. កម្មវិធីគឺត្រូវរៀបចំឲ្យគ្របដណ្តប់លើលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជាជំនាញឯកទេសដែលទាក់ទងទៅនឹងចំណេះដឹងនិងជំនាញនៃមុខវិជ្ជាត្រូវរៀន និងលទ្ធផលសិក្សានៃចំណេះដឹងរួម (ជួនកាលគេហៅថាផ្ទេរជំនាញ) ដែលទាក់ទងទៅនឹងនៃមុខវិជ្ជានានា ឧទាហរណ៍ មុខវិជ្ជាទំនាក់ទំនងផ្ទាល់មាត់និងសរសេរ មេរៀនដោះស្រាយបញ្ហា ព័ត៌មានវិទ្យា និងជំនាញធ្វើការជាក្រុម។ល។*

*៤. កម្មវិធីបង្កើតលទ្ធផលសិក្សារំពឹងទុកច្បាស់លាស់ដែលឆ្លុះបញ្ចាំងពីតម្រូវការនិងភាពចាំបាច់សំខាន់ៗរបស់ភាគីពាក់ព័ន្ធនានា។*

### ២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ១

| No. | លទ្ធផលសិក្សាដែលរំពឹងទុក | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 1.1 | លទ្ធផលសិក្សាដែលរំពឹងទុកត្រូវបានបង្ហាញច្បាស់លាស់និងត្រូវបានបកស្រាយក្នុងកម្មវិធីបណ្តុះបណ្តាល[1,2] | | | | | | | |
| 1.2 | លទ្ធផលសិក្សាដែលរំពឹងទុកគ្របដណ្តប់ទាំងលើចំណេះដឹងរួមនិងជំនាញឯកទេស[ឧ.ដែលអាចផ្ទេរ]នៃលទ្ធផលសិក្សាចុងក្រោយ [3] | | | | | | | |
| 1.3 | លទ្ធផលសិក្សាដែលរំពឹងទុកឆ្លើយតបនឹងតម្រូវការច្បាស់លាស់របស់អ្នកពាក់ព័ន្ធនានា [4] | | | | | | | |
| **យោបល់រួម** | | | | | | | | |

### ការពន្យល់

- ការអប់រំផ្អែកលើលទ្ធផលអាចពិពណ៌នាទៅតាមវិធីដែលកម្មវិធីសិក្សាបានកំណត់ រៀបចំណែនាំផ្អែកទៅលើអ្វីៗទាំងអស់ដែលអ្នកសិក្សាអាចរៀននិងបង្ហាញដោយជោគជ័យនៅពេលដែលពួកគេបានបញ្ចប់ការសិក្សាកម្មវិធី។ ការសំដៅទៅលើការអប់រំផ្អែកលើលទ្ធផលគឺជាលទ្ធផលនៃការរៀនសូត្រ ខណ:ដែលចំណេះដឹង ជំនាញ និងអាកប្បកិរិយា រួមទាំងទម្លាប់ក្នុងចិត្តដែល

អ្នកសិក្សារំពឹងថាត្រូវរៀនសូត្រនោះបានបង្ហាញច្បាស់លាស់ដូចមានក្នុងលទ្ធផលសិក្សារំពឹងទុក។

- លទ្ធផលសិក្សារំពឹងទុកដែលបានរៀបចំឡើងតាមតម្រូវការរបស់ភាគីពាក់ព័ន្ធនានាបង្កើតបានជាចំណុចចាប់ផ្តើមនៃការរៀបចំកម្មវិធី។លទ្ធផលសិក្សាផ្តោតលើជោគជ័យរបស់អ្នកសិក្សាច្រើនជាងបំណងរបស់គ្រូដែលជាញឹកញាប់គ្រាន់តែសរសេរជាគោលបំណង គោលដៅ ឬជាវត្ថុបំណងនៃកម្មវិធី។
- លទ្ធផលសិក្សាចុងក្រោយគួរត្រូវសរសេរទៅតាមវិធីដែលការរៀនសូត្របង្ហាញចេញជាលទ្ធផលដែលអាចមើលឃើញនិងវាស់វែងបាន ហើយលទ្ធផលនោះអាចស្តែងចេញនិងត្រូវបានវាយ តម្លៃ។

## សំណួរវិនិច្ឆ័យ

- តើការសិក្សាកម្មវិធីមួយមានគោលបំណងជាអ្វី?
- តើកម្មវិធីមានលទ្ធផលសិក្សារំពឹងទុកជាអ្វី?
- តើវិធីបង្កើតលទ្ធផលសិក្សារំពឹងរៀបចំឡើងយ៉ាងម៉េច?
- តើការបង្កើតលទ្ធផលសិក្សាចុងក្រោយបានឆ្លុះបញ្ចាំងពីចក្ខុវិស័យនិងបេសកកម្មរបស់សាកលវិទ្យាល័យ មហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ដែរឬទេ ?
- តើតម្រូវការទីផ្សារការងារទាមទារនូវលក្ខខណ្ឌជាក់លាក់សម្រាប់និស្សិតបញ្ចប់ការសិក្សាដែរឬទេ?
- តើខ្លឹមសាររបស់កម្មវិធីមានទំហំប៉ុណ្ណាទើបឆ្លើយតបនឹងតម្រូវការទីផ្សារការងារ?
- តើមានកំណត់ទម្រង់អំពីតម្រូវការរបស់ការងារដែរឬទេ?
- តើលទ្ធផលសិក្សាចុងក្រោយបានផ្សព្វផ្សាយទៅដល់និស្សិតនិងបុគ្គលិកដោយវិធីណា?
- តើលទ្ធផលសិក្សាចុងក្រោយអាចវាស់វែងបាននិងសម្រេចបានដែរឬទេ?តាមវិធីណា?
- តើលទ្ធផលសិក្សាចុងក្រោយអាចសម្រេចបានក្នុងទំហំប៉ុណ្ណា?
- តើលទ្ធផលសិក្សាចុងក្រោយត្រូវបានពិនិត្យឡើងវិញញឹកញាប់ដែរឬទេ?
- តើលទ្ធផលសិក្សាចុងក្រោយបានផ្សារភ្ជាប់ទៅនឹងតម្រូវការជាក់ស្តែងរបស់និស្សិតបញ្ចប់ការសិក្សាយ៉ាងដូចម្តេច? (ឧទា. ចំណេះដឹង ជំនាញ និងអាកប្បកិរិយា រួមទាំងទម្លាប់ក្នុងចិត្ត)

## ប្រភពនៃភស្តុតាង/ឯកសារចាំបាច់

ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជា

• សលាកបត្រព័ត៌មានផ្សេងៗទាក់ទងនឹងមុខវិជ្ជា

• តារាងម៉ាទ្រីសអំពីជំនាញ

• ធាតុចូលរបស់ភាគីពាក់ព័ន្ធ
• គេហទំព័ររបស់សាកលវិទ្យាល័យ និងមហាវិទ្យាល័យ
• កំណត់ហេតុ និងឯកសារនានានៃការពិនិត្យឡើងវិញលើកម្មវិធីសិក្សា
• របាយការណ៍នានាស្តីពីការទទួលស្គាល់គុណភាពអប់រំ និងការប្រៀបធៀបជាគោល

## ៣. ការសិក្សាផ្អែកលើលទ្ធផល (OBE)

តាមបណ្ដាញជោគជ័យកម្រិតខ្ពស់(១៩៩២) កំណត់ន័យការសិក្សាផ្អែកលើលទ្ធផលថា ″ការកំណត់ ការរៀបចំ ការផ្ដោតលើគោលដៅ និងការតម្រង់ទិសទៅរកផ្នែកនានារបស់កម្មវិធីស្ដីពីមេរៀនផ្សេងៗ ដែលយើងចង់ឱ្យអ្នកសិក្សាបង្ហាញជោគជ័យនៅពេលគេបានបញ្ចប់កម្មវិធី″។

ការសិក្សាផ្អែកលើលទ្ធផលសំដៅលើ:

- លទ្ធផលសិក្សាដែលគេរំពឹងថាអ្នកសិក្សារៀនចេះ
- ការរៀបចំកម្មវិធីសិក្សាត្រឡប់ដែលសំដៅលើការរៀបចំផ្ដោតលើកម្មវិធីសិក្សានិងបទពិសោធន៍រៀនសូត្រដើម្បីជួយអ្នកសិក្សាឱ្យសម្រេចលទ្ធផលសិក្សារំពឹងទុក
- ការវាយតម្លៃនិស្សិតត្រូវបានរៀបចំដើម្បីវាស់លទ្ធផលសិក្សារំពឹងទុករបស់អ្នកសិក្សា
- ការតម្រង់ទិសទៅរកលទ្ធផលសិក្សារំពឹងទុក កម្មវិធីសិក្សា វិធីសាស្ត្ររៀននិងបង្រៀន និងការវាយតម្លៃនិស្សិត

## ៤. តារាងវិភាគកម្រិតយល់ដឹងតាមលោក Bloom




| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| កម្រិត | កិរិយាស័ព្ទសកម្ម | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
| **កម្រិតចងចាំ**<br>ប្រមូល ឬរំលឹកឡើងវិញពីចំណេះដឹងពាក់ព័ន្ធពីការចងចាំ រយៈពេលវែងដែលបានរៀនពីមុន | កំណត់អត្តន័យ<br><br>ពិពណ៌នា<br><br>កំណត់អត្តសញ្ញាណ<br>ដាក់ស្លាកសម្គាល់<br>តម្រៀប | ការបង្រៀនដោយលើកឧទាហរណ៍<br>ពន្យល់<br>ការឧទ្ទេស<br>សំណួរតម្រង់ទិស<br><br>ការសម្តែងបង្ហាញ | សំណួរពហុជ្រើសរើស<br>សំណួរ ចម្លើយខ្លីៗ<br>សំណួរសរសេរ<br>តេស្តការសម្តែង<br>ផ្គុំនិងផ្គូរផ្គង<br>ធ្វើបទបង្ហាញ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| កម្រិត | កិរិយាស័ព្ទសកម្ម | វិធីសាស្រ្តបង្រៀន | វិធីសាស្រ្តវាយតម្លៃ |
| | ផ្គូរផ្គង<br>ដាក់ឈ្មោះ<br>រៀបចំគ្រោង<br>រំឭក<br>ចំណាំ<br><br>បង្កើតឡើងវិញ<br>ជ្រើសរើស<br>បញ្ជាក់<br><br>កំណត់ទីតាំង | ការហ្វឹកហាត់ និង អនុវត្តន៍<br>ការសម្តែងតួ<br><br>ការធ្វើជាគំរូ<br>ល្បែងជំនួយការចងចាំ<br>ល្បែងផ្គុំ/ស្រាយបញ្ហា<br>លប់ និងបំពេញឡើងវិញ | (ឧ. ការសូត្រ និង សង្ខេប)<br><br>ផ្គុំពាក្យ/រូបភាព/ខ្លឹមសារ |
| **កម្រិតយល់ដឹង**<br>បង្កើតន័យតាមរយៈ: ការបង្រៀនរួមជាមួយលំហាត់ផ្ទាល់មាត់ ការសរសេរ និងទំនាក់ទំនងក្រាហ្វិក | បង្ហាញ<br>ការពារ<br>ប្រៀបធៀប<br>ប៉ាន់ប្រមាណ<br>ពន្យល់<br>ធ្វើចំណាត់ថ្នាក់<br>សន្និដ្ឋាន<br>បកស្រាយ<br><br>ពន្យល់ន័យដើម<br>ព្យាករឬទាយ<br>ការសរសេរឡើងវិញ<br>សង្ខេប<br>បកប្រែ | ការឧទ្ទេស<br>ការបង្រៀនដោយមានឧទាហរណ៍<br>បញ្ជាក់<br>ការសម្តែងតួឬ ការដើរតួ<br>ល្បែង<br>ការពិភាក្សា<br>ការបំផុសគំនិត, ពង្រាងគំនិត<br>ការបង្កើតគំនិត<br>ដៅគំនិត ពង្រាយមែកធាងគំនិត គំរូ, ម៉ូដែល | សំណួរពហុជ្រើសរើស<br>សំណួរចម្លើយខ្លីៗ<br>ការធ្វើបទបង្ហាញ<br>តេស្តការសម្តែងតែងសេចក្តី<br><br>ការពន្យល់ន័យដើម<br>ការរៀបចំប័ណ្ណឬបដា |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្ត្របង្រៀន** | **វិធីសាស្ត្រវាយតម្លៃ** |
| **កម្រិតអនុវត្តន៍**<br>អនុវត្ត ឬប្រើសេចក្តីណែនាំទៅតាមកាលៈទេសៈឬស្ថានភាពជាក់ស្តែងណាមួយ | អនុវត្ត<br>រៀបចំ ចាត់ចែង<br>សម្តែង ធ្វើវិនាដកម្ម<br>ដោះស្រាយបញ្ហា<br>បង្កើត<br>បង្ហាញ ឬសម្តែង<br>ស្វែងរក<br>កនាំ<br>កែសម្រួល<br>ប្រតិបត្តិ<br>ព្យាករឬទាយ<br>រៀបចំ ត្រៀម បម្រុង<br>ផលិត/បង្កើត<br>ភ្ជាប់ទំនាក់ទំនង/និទាន<br>បង្ហាញ ដាក់តាំង<br>ជ្រើសរើស | ការបង្ហាញ<br>ដំណោះស្រាយបញ្ហា<br>ទស្សនកិច្ចសិក្សា<br>ការពិសោធន៍<br>ការបង្ហាញនិងអធិប្បាយ<br>ការផ្គុំនិងផ្គូរផ្គង<br>ការដើរតួរ ឬការសម្តែងតួ<br>ការសិក្សាអង្គហេតុ<br>ការរៀបគម្រោង<br>កិច្ចការអនុវត្តន៍ | តម្រៀបឡើងវិញ<br>ផ្គុំនិងផ្គូរផ្គង<br>ផ្គូរផ្គង<br>គម្រោង<br>បទបង្ហាញ<br>បដាបង្ហាញ<br>កម្មសិក្សា/ការងារទីវាល<br>កិច្ចការអនុវត្តន៍<br>សិក្សាអង្គហេតុ |
| **កម្រិតវិភាគ**<br>បែងចែកចំណេះដឹងទៅតាមផ្នែកគោលនិងកំណត់ទំនាក់ | វិភាគ<br>វាយលម្អិត ឬវិភាគលម្អិត<br>ប្រៀបធៀប<br>ជ្រើសរើស<br>បដិមតិ | សិក្សាអង្គហេតុ<br>គម្រោងស្រាវជ្រាវជាក្រុម<br>កិច្ចការអនុវត្តន៍<br>ការពិសោធន៍ | តែងសេចក្តី<br>ប័ណ្ណប្រកាសឬបដាបង្ហាញ<br>សំណេររបាយការណ៍<br>បទបង្ហាញ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្ត្របង្រៀន** | **វិធីសាស្ត្រវាយតម្លៃ** |
| ទំនងរចនាសម្ព័ន្ធ ឬ គោលបំណងជារួម | បំបែក<br>ចំណាត់ថ្នាក់ | ការងារទីវាល<br>ការសិក្សាដោយផ្អែកលើបញ្ហា<br>ការពិភាក្សាដេញដោល<br>Researchការសិក្សាស្រាវជ្រាវ<br>Concept formulation<br>ការបង្កើតទស្សនៈ | កម្រងឯកសារ<br>គម្រោងស្រាវជ្រាវ<br>តេស្តអនុវត្តសម្តែង<br>ការសិក្សាស្រាវជ្រាវ<br>សិក្សាអង្គហេតុ<br>ការរិះគន់<br>ការវិភាគលើភាពខ្លាំង ខ្សោយ កាលានុវត្តភាព និងហានិភ័យ (SWOT) |
| **កម្រិតវាយតម្លៃ**<br>ធ្វើការវាយតម្លៃដោយផ្អែកលើលក្ខណៈ: វិនិច្ឆ័យនិងនិយាមបទដ្ឋាន | ចាត់ថ្នាក់<br>វាយតម្លៃ<br><br>ពិនិត្យតាមដាន<br>ត្រួតពិនិត្យ<br>តេស្ត<br>វិនិច្ឆ័យ | វិធីសាស្ត្រស្រាវជ្រាវតាមបែបសាកសួរ ឬរុករក<br>វិភាគបញ្ហា<br>ការពិភាក្សាដេញដោល<br>ការធ្វើពិសោធន៍<br>គម្រោងស្រាវជ្រាវ<br>កម្មសិក្សា<br>បង្រៀនដៃគូ<br>ការវិភាគលើភាពខ្លាំង ខ្សោយ កាលានុវត្តភាព និងហានិភ័យ<br>(SWOT) | ការបង្ហាញស្រាវជ្រាវ និងសំណេររបាយការណ៍<br>តេស្តសំណេរ<br>ការពិភាក្សាដេញដោល<br>កាត់ក្តីសាកល្បងឬសវនាការប្រឌិត<br>តែងសេចក្តី<br>លទ្ធផលពិសោធន៍<br>គម្រោងស្រាវជ្រាវ<br>តេស្តលើសមត្ថភាពការងារ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្រ្តបង្រៀន** | **វិធីសាស្រ្តវាយតម្លៃ** |
| **កម្រិតបង្កើតនិងច្នៃ** ដាក់បញ្ចូលសមាសភាពរួមគ្នាដើម្បីបង្កើតបណ្តាញឬតួនាទីទាំងមូល ឬ រៀបចំសមាសភាពឡើងវិញឲ្យទៅជាគំរូឬរចនាសម្ព័ន្ធថ្មី ។ | បង្កើត<br>ធ្វើផែនការ<br>និពន្ធ<br>អភិវឌ្ឍ<br>ច្នៃនិងបង្កើតថ្មី<br>ច្នៃប្រឌិត<br>រៀបចំ<br>ស្ថាបនា<br>ផលិត<br>ចងក្រង<br>ធ្វើគម្រោង, គូរគម្រោង<br>បង្កើតគំនិតថ្មី | -ដំណោះស្រាយបញ្ហា<br>សិក្សាអង្គហេតុ<br>គម្រោងស្រាវជ្រាវ<br>កម្មសិក្សាជាក់ស្តែង<br>ការសិក្សាតាមពិសោធន៍<br>ទស្សនកិច្ចសិក្សា<br>- បង្កើតគំរូ | ធ្វើបទបង្ហាញ<br>តែងសេចក្តី<br>ព្រឹត្តិប័ត្រ<br>ការសរសេរ របាយការណ៍ស្រាវជ្រាវ<br>បឋមរូប ឬការបង្កើតគំរូ<br>ការសម្តែង<br>ការតែងនិពន្ធ (រឿង ចម្រៀង កំណាព្យ...)<br><br>ការសិក្សាស្រាវជ្រាវ<br>គម្រោងស្រាវជ្រាវ |

*១. លក្ខណវិនិច្ឆ័យ២៖ ចំណុចលម្អិតនៃកម្មវិធី*

*១. ស្ថាប័នត្រូវបានផ្តល់អនុសាសន៍ឲ្យបោះពុម្ពផ្សាយ និងធ្វើឲ្យមានទំនាក់ទំនងរវាងចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជាសម្រាប់កម្មវិធីដែលស្ថាប័នបណ្តុះបណ្តាល និងផ្តល់ព័ត៌មានលម្អិតអំពីកម្មវិធីដើម្បីជួយឲ្យភាគីពាក់ព័ន្ធជ្រើសរើសនូវជម្រើសដែលគេផ្តល់ជូនណាមួយអំពីកម្មវិធីនោះ។*

*២. ចំណុចលម្អិតនៃកម្មវិធីដែលរួមបញ្ចូលចំណុចលម្អិតនៃមុខវិជ្ជាពិពណ៌នាអំពីលទ្ធផលសិក្សារំពឹងទុកពាក់ព័ន្ធនឹងចំណេះដឹងជំនាញ និងឥរិយាបថ។ ចំណុចលម្អិតនៃមុខវិជ្ជាទាំងនេះជួយ និស្សិតឲ្យយល់អំពីវិធីបង្រៀន និងរៀនដែលធ្វើឲ្យលទ្ធផលសិក្សាអាចសម្រេចបានវិធីវាយតម្លៃដែលធ្វើឲ្យលទ្ធផលសម្រេចបានអាចនឹងត្រូវបានគេបង្ហាញឲ្យឃើញ និងទំនាក់ទំនងនៃកម្មវិធី និងធាតុផ្សំនៃការសិក្សា។*

២. បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ២

| No. | កម្មវិធីលម្អិត | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 2.1 | ព័ត៌មាននៅក្នុងចំណុចលម្អិតនៃកម្មវិធីគឺទូលំទូលាយ និងទាន់សម័យ [1, 2] | | | | | | | |
| 2.2 | ព័ត៌មានលម្អិតនៅក្នុងមុខវិជ្ជាគឺទូលំទូលាយ និងទាន់សម័យ [1, 2] | | | | | | | |
| 2.3 | ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជាត្រូវបានធ្វើឲ្យមានទំនាក់ទំនង និងឲ្យបានដល់ភាគីពាក់ព័ន្ធ | | | | | | | |
| **យោបល់រួម** | | | | | | | | |

**ការពន្យល់**

ចំណុចលម្អិតនៃកម្មវិធីគឺជាបណ្តុះនៃឯកសារដែលពិពណ៌នាអំពីកម្មវិធីសិក្សាដែលបណ្តុះបណ្តាលដោយសាកលវិទ្យាល័យ។ ចំណុចលម្អិតនៃកម្មវិធីតែងតែរួមបញ្ចូលចំណុចខាងក្រោម៖

- ការសង្ខេបនៃគោលបំណង និងលទ្ធផល ចង់បាន
- គម្រោងរចនាសម្ព័ន្ធនៃមុខវិជ្ជា
- ម៉ាទ្រីសបង្ហាញអំពីរបៀបដែលលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធីត្រូវបានសម្រេចតាមរយៈមុខវិជ្ជា និង
- បណ្តុំចំណុចលម្អិតនៃមុខវិជ្ជា

*ចំណុចលម្អិតនៃកម្មវិធីបម្រើ៖*

- ជាប្រភពនៃព័ត៌មានសម្រាប់និស្សិតដើម្បីស្វែងយល់អំពីកម្មវិធី
- ជាប្រភពនៃព័ត៌មានសម្រាប់និយោជក ជាពិសេសអំពីចំណេះដឹង និង ជំនាញដែលអាចផ្ទេរបានដែលត្រូវបានអភិវឌ្ឍដោយកម្មវិធី

- អង្គភាពវិជ្ជាជីវៈ និងស្ថាប័នដែលកំណត់ដោយច្បាប់ដែលទទួលស្គាល់គុណភាពអប់រំកម្មវិធីឧត្តមសិក្សា ដែលអាចនាំចូលទៅក្នុងវិជ្ជាជីវៈ ឬមុខរបរផ្សេងទៀត។ ចំណុចលម្អិតនៃកម្មវិធីគួរបញ្ជាក់ ពីទិដ្ឋភាព ទាំងនោះរបស់កម្មវិធីដែលត្រូវបានកំណត់ដើម្បីបំពេញលក្ខខណ្ឌនៃអង្គភាពពាក់ព័ន្ធ
- ក្រុមរបស់ស្ថាប័ន និងក្រុមបង្រៀនដើម្បីលើកកម្ពស់ការពិភាក្សា និងការឆ្លុះបញ្ចាំងនៅលើកម្មវិធីកំពុងមាន និងកម្មវិធីថ្មីៗ ព្រម ទាំងដើម្បីធ្វើឲ្យប្រាកដថា មានការយល់រួមគ្នាអំពីលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី។ ចំណុចលម្អិតនៃ កម្មវិធីគួរតែធ្វើឲ្យស្ថាប័នពេញចិត្តខ្លួនឯងថាអ្នកកំណត់កម្មវិធីយល់ច្បាស់ អំពីលទ្ធផលសិក្សារំពឹងទុក ហើយលទ្ធផលរំពឹងទុកនេះត្រូវបានសម្រេច និងបង្ហាញ។ ចំណុចលម្អិតនៃកម្មវិធីអាចបម្រើជាចំណុច យោងសម្រាប់ការត្រួតពិនិត្យផ្ទៃក្នុង និងការពិនិត្យតាមដាននៃការអនុវត្តកម្មវិធី។
- ជាប្រភពនៃព័ត៌មានសម្រាប់អ្នកត្រួតពិនិត្យសិក្សា និងអ្នកត្រួតពិនិត្យពីខាងក្រៅដែលត្រូវការយល់គោលបំណង និងលទ្ធផល ចង់បានរបស់កម្មវិធី និង
- ជាមូលដ្ឋានសម្រាប់ទទួលយោបល់ត្រឡប់ពីនិស្សិត ឬនិស្សិតបញ្ចប់ការសិក្សាថ្មីៗទៅលើអ្វីដែលពួក គេបានយល់អំពីឱកាសសិក្សាដើម្បីឲ្យបានជោគជ័យ នៅក្នុងការលើកកម្ពស់លទ្ធផលដែលចង់បាន។

*ព័ត៌មាននឹងត្រូវ ដាក់បញ្ចូលនៅក្នុងចំណុចលម្អិតនៃកម្មវិធីមានដូចខាងក្រោម៖*

- អង្គភាព/ស្ថាប័នផ្តល់សញ្ញាបត្រ
- ស្ថាប័នបណ្តុះបណ្តាល (ប្រសិនបើខុសគ្នា)
- សេចក្តីលម្អិតនៃការទទួលស្គាល់ គុណភាពដោយអង្គភាពវិជ្ជាជីវៈ ឬអង្គភាពច្បាប់
- ឈ្មោះនៃសញ្ញាបត្រចុងក្រោយ
- ចំណងជើងកម្មវិធី
- លទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី
- លក្ខខណ្ឌ ឬលក្ខណវិនិច្ឆ័យចុះឈ្មោះ ចំពោះកម្មវិធី
- ប្រយោគអំពីការផ្ទៀងផ្ទាត់ដោយយកមុខវិជ្ជាពាក់ព័ន្ធ របស់គេមកពិនិត្យ និងឯកសារយោងពីខាងក្នុង និងខាងក្រៅដែលត្រូវបានប្រើដើម្បីផ្តល់ព័ត៌មាន លទ្ធផលរំពឹងទុករបស់កម្មវិធី
- រចនាសម្ព័ន្ធកម្មវិធី និងលក្ខខណ្ឌដែលរួមបញ្ចូលកម្រិត មុខវិជ្ជា ក្រេឌីត។ល។
- កាលបរិច្ឆេទដែលនៅក្នុងនោះ ចំណុចលម្អិតនៃកម្មវិធីត្រូវបានសរសេរ ឬកែសម្រួល

*ព័ត៌មាននឹងត្រូវ ដាក់បញ្ចូលក្នុងចំណុចលម្អិតនៃមុខវិជ្ជាមានដូចខាងក្រោម៖*

- ចំណងជើងមុខវិជ្ជា
- តម្រូវការនៃមុខវិជ្ជា ដូចជាតម្រូវការចុះឈ្មោះចូលរៀនមុខវិជ្ជាជាមុន ក្រេឌីត។ល។
- លទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជាទាក់ទងនឹងចំណេះដឹង ជំនាញ និងឥរិយាបថ

- វិធីបង្រៀន រៀន និងវាយតម្លៃដើម្បីធ្វើឲ្យលទ្ធផលរំពឹងទុកនឹងត្រូវបានសម្រេច និងត្រូវបានបង្ហាញ
- រពិពណ៌នាមុខវិជ្ជា និងប្លង់មុខវិជ្ជា ឬកម្មវិធីមុខវិជ្ជាលម្អិត
- សេចក្តីលម្អិតនៃការវាយតម្លៃនិស្សិត
- កាលបរិច្ឆេទដែលចំណុចលម្អិត នៃមុខវិជ្ជាត្រូវបានសរសេរ ឬកែសម្រួល

## សំណួរវិនិច្ឆ័យ

- តើលទ្ធផលសិក្សារំពឹងទុកត្រូវបានសរសេរពន្យល់នៅក្នុងកម្មវិធី និងមុខវិជ្ជារបស់កម្មវិធីនោះដែរឬទេ?
- តើព័ត៌មានអ្វីខ្លះ ដែលត្រូវបានតម្កល់ទុកជាឯកសារនៅក្នុងកម្មវិធី និងនៅក្នុងចំណុចលម្អិតនៃមុខវិជ្ជា?
- តើចំណុចលម្អិតនៃមុខវិជ្ជាមាន ស្តង់ដាដូចគ្នានៅក្នុងកម្មវិធីទាំងមូលដែរឬទេ?
- តើចំណុចលម្អិតនៃកម្មវិធីត្រូវបានបោះពុម្ពផ្សាយ និងធ្វើឲ្យអាចរកបានចំពោះភាគីពាក់ព័ន្ធដែរឬទេ?
- តើអ្វីទៅជានីតិវិធី សម្រាប់ការពិនិត្យឡើងវិញនូវចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជា?

## ប្រភពនៃភស្តុតាង/ឯកសារចាំបាច់

- ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជា
- សលាកបត្រព័ត៌មានផ្សេងៗទាក់ទងនឹងមុខវិជ្ជា
- តារាងម៉ាទ្រីសអំពីជំនាញ
- ធាតុចូលរបស់ភាគីពាក់ព័ន្ធ
- គេហទំព័ររបស់សាកលវិទ្យាល័យ និងមហាវិទ្យាល័យ
- កំណត់ហេតុនៃការកែលំអឡើងវិញនូវកម្មវិធីសិក្សា និងឯកសារពាក់ព័ន្ធ
- របាយការណ៍អំពីការទទួលស្គាល់គុណភាព និងការផ្ទៀងផ្ទាត់ដោយយកសាកលវិទ្យាល័យផ្សេងមកពិនិត្យ

## ៣. តើកម្មវិធីសិក្សាលម្អិតគឺជាអ្វី?

កម្មវិធីសិក្សាលម្អិតគឺជាកម្រងឯកសារនានាដែលអធិប្បាយកម្មវិធីសិក្សាបណ្តុះបណ្តាលដោយសាកលវិទ្យាល័យ។ កម្មវិធីសិក្សាលម្អិតជាធម្មតាពាក់ព័ន្ធនឹងចំណុចខាងក្រោម៖

- គោលបំណងកម្មវិធីសង្ខេបនិងលទ្ធផលដែលចង់បាន
- គម្រោងទម្រង់មុខវិជ្ជា

- តារាងម៉ាទ្រីសដែលបង្ហាញរបៀបទទួលជោគជ័យរវាងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីតាមរយៈមុខវិជ្ជានានា និង
- កម្រងមុខវិជ្ជាលម្អិតផ្សេងៗ

## ៤. គោលបំណងនៃកម្មវិធីសិក្សាលម្អិត

កម្មវិធីសិក្សាលម្អិតជួយដល់អនាគតនិស្សិតនិងនយោជកដើម្បីធ្វើការជ្រើសរើសដែលបានជូនដំណឹងអំពីកម្មវិធីនិងប្រើជាមធ្យោបាយទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងអ្នកពាក់ព័ន្ធដូចបានបង្ហាញក្នុងរូបភាព២.១




រូបភាព២.១៖គោលបំណងនៃកម្មវិធីសិក្សាលម្អិត

កម្មវិធីសិក្សាលម្អិតប្រើប្រាស់ក្នុងគោលបំណងខាងក្រោម៖

- ជាព័ត៌មានសម្រាប់នយោជកស្តីពីសមត្ថភាពឬចំណេះដឹង ជំនាញនិងឥរិយាបថរបស់និស្សិត
- ជាព័ត៌មានសម្រាប់ស្ថាប័នអាជីពនិងនីតិបញ្ញត្តិដែលទទួលស្គាល់កម្មវិធីអប់រំឧត្តមសិក្សាអំពីលក្ខខណ្ឌជ្រើសចូល ឬទទួលស្គាល់ក្នុងអាជីព ឬជាអាជីពដែលមានច្បាប់ទម្លាប់ត្រឹមត្រូវ។

- ជាព័ត៌មានសម្រាប់បុគ្គលិកសាស្ត្រាចារ្យក្នុងគោលបំណងពិនិត្យឡើងវិញ ការពិភាក្សានិងឆ្លុះបញ្ចាំងលើកម្មវិធីដែលមានស្រាប់និងថ្មីៗ ហើយដើម្បីធានាថាមានការយល់ដឹងរួមស្តីពីលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី
- ជាព័ត៌មានសម្រាប់អ្នកពិនិត្យកម្មវិធីអប់រំនិងអ្នកត្រួតពិនិត្យពីខាងក្រៅដែលត្រូវការយល់ដឹងពីគោលបំណងនិងលទ្ធផលរំពឹងទុកនានារបស់កម្មវិធី
- ជាមូលដ្ឋានសម្រាប់ទទួលយកយោបល់ត្រឡប់ពីអតីតនិស្សិតនិងនិស្សិតបច្ចុប្បន្នស្តីពីជោគជ័យនៃលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធី

## ៥. លក្ខខណ្ឌតម្រូវនៃកម្មវិធីសិក្សាលម្អិត

ព័ត៌មានដែលរួមបញ្ចូលក្នុងកម្មវិធីសិក្សាលម្អិតត្រូវបានរៀបដូចខាងក្រោម៖

- ស្ថាប័នផ្តល់សញ្ញាបត្រ/ការទទួលស្គាល់
- គ្រឹះស្ថានបង្រៀន(ប្រសិនខុសគ្នា)
- ព័ត៌មានលម្អិតស្តីពីការទទួលស្គាល់គុណភាពដោយអង្គភាពអាជីពឬស្ថាប័នបញ្ញត្តិច្បាប់
- ឈ្មោះសញ្ញាបត្រចុងក្រោយ
- ចំណងជើងកម្មវិធី
- លទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី
- លក្ខខណ្ឌឬលក្ខណវិនិច្ឆ័យចូលរៀនឬកម្មវិធីសិក្សា
- កម្រិតមាត្រដ្ឋានទាក់ទងមុខវិជ្ជានិងចំណុចយោងនានាទាំងក្នុងទាំងក្រៅដែលប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានស្តីពីលទ្ធផលកម្មវិធី
- រចនាសម្ព័ន្ធកម្មវិធីនិងលក្ខណវិនិច្ឆ័យរួមទាំងកម្រិត មុខវិជ្ជា ក្រេឌីត។ល។
- កាលបរិច្ឆេទដែលកម្មវិធីសិក្សាលម្អិតត្រូវបានសរសេរឬពិនិត្យឡើងវិញ

ព័ត៌មានដែលរួមបញ្ចូលក្នុងមុខវិជ្ជាលម្អិតត្រូវបានរៀបដូចខាងក្រោម៖

- ចំណងជើងមុខវិជ្ជា
- លក្ខខណ្ឌឬលក្ខណវិនិច្ឆ័យចូលរៀនមុខវិជ្ជាដូចជាតម្រូវឱ្យសិក្សាមុខវិជ្ជាគោលមុនចុះឈ្មោះសម្រាប់មុខវិជ្ជា ក្រេឌីត។ល។
- លទ្ធផលសិក្សារំពឹងទុករបស់មុខវិជ្ជាដែលសំដៅលើចំណេះដឹង ជំនាញ និងឥរិយាបថ
- វិធីសាស្ត្របង្រៀន ការរៀននិងការវាយតម្លៃដើម្បីធ្វើឱ្យលទ្ធផលសិក្សាបានសម្រេចនិងបានបង្ហាញ

- ការអធិប្បាយមុខវិជ្ជានិងគម្រោងមុខវិជ្ជា ឬប្លង់មេរៀនលម្អិត
- ព័ត៌មានលម្អិតស្តីពីការវាយតម្លៃនិស្សិត
- កាលបរិច្ឆេទដែលមុខវិជ្ជាលម្អិតត្រូវបានសរសេរឬពិនិត្យឡើងវិញ

## *១. លក្ខណវិនិច្ឆ័យ៣៖ រចនាសម្ព័ន្ធ និងខ្លឹមសារកម្មវិធី*

*១. កម្មវិធីសិក្សា វិធីសាស្ត្របង្រៀននិងរៀន និងការវាយតម្លៃនិស្សិតត្រូវបានរៀបចំឡើងសំដៅទៅសម្រេចលទ្ធផលសិក្សារំពឹងទុកនានា។*

*២. កម្មវិធីសិក្សាគឺត្រូវរៀបចំឡើងដើម្បីសំដៅទៅរកលទ្ធផលសិក្សារំពឹងទុក ដោយមុខវិជ្ជានីមួយៗចូលរួមធ្វើឲ្យសម្រេចនូវលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីច្បាស់លាស់។*

*៣. កម្មវិធីសិក្សាគឺត្រូវរៀបចំដោយផ្អែកលើខ្លឹមសារមុខវិជ្ជាដែលបង្កើតសមហេតុផល តាមលំដាប់លំដោយ ហើយត្រូវបានច្របាច់បញ្ចូលគ្នា។*

*៤. រចនាសម្ព័ន្ធកម្មវិធីសិក្សាបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងនិងការវិវត្តនៃមុខវិជ្ជាមូលដ្ឋាន មុខវិជ្ជាកម្រិតមធ្យម និងមុខវិជ្ជាឯកទេសផ្សេងៗ។*

*៥.កម្មវិធីសិក្សាគឺត្រូវបង្កើតដោយផ្អែកលើភាពប្រែប្រួលសមល្មមឲ្យនិស្សិតឈានទៅរកមុខវិជ្ជាជំនាញ និងភ្ជាប់ទៅរកការអភិវឌ្ឍន៍ក្នុងមុខវិជ្ជានិងការផ្លាស់ប្តូរថ្មីៗ។*

*៦. កម្មវិធីសិក្សាគឺត្រូវបានពិនិត្យឡើងវិញជារៀយៗ ដើម្បីធានាថាកម្មវិធីសិក្សានោះនៅជាតម្រូវការចាំបាច់និងទាន់សម័យនៅឡើយ។*

**ការពន្យល់**

កម្មវិធីសិក្សាគួរត្រូវបានបង្កើតដើម្បីឲ្យវិធីសាស្ត្របង្រៀននិងរៀន និងការវាយតម្លៃនិស្សិតគាំទ្រដល់ការសម្រេចបាននៃលទ្ធផលសិក្សារំពឹងទុកនានា។ ដំណើរការនេះមានឈ្មោះថា "**ការតម្រង់ទៅរកប្រយោជន៍**"។ "**ទៅរកប្រយោជន៍**" សំដៅលើការយល់ដឹងដែលនិស្សិតបង្កើតអត្ថន័យតាមរយៈសកម្មភាពសិក្សាដែលពាក់ព័ន្ធ។ ចំណែកឯ "**ការតម្រង់**" សំដៅទៅលើស្ថានភាពមួយដែលនៅពេលសកម្មភាពបង្រៀននិងរៀន និងការវាយតម្លៃនិស្សិតតម្រង់ទៅសម្រេចលទ្ធផលសិក្សារំពឹងទុកនានា។

**ការតម្រង់ទិសរកប្រយោជន៍នៃមុខវិជ្ជាណាមួយគឺទាក់ទងនឹង៖**

- ការកំណត់លទ្ធផលសិក្សារំពឹងទុកទាំងឡាយណាដែលអាចវាស់វែងបាន
- ការជ្រើសរើសវិធីសាស្ត្របង្រៀននិងរៀនដែលអាចធានាថាលទ្ធផលសិក្សារំពឹងទុក ត្រូវបានសម្រេច និង
- ការវាយតម្លៃពីវិធីដែលនិស្សិតបានសម្រេចលទ្ធផលសិក្សារំពឹងទុកដូចបានកំណត់។

២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៣

| No. | រចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្មវិធី | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 3.1 | កម្មវិធីសិក្សារៀបចំតម្រង់ទិសស្របតាមលទ្ធផលរំពឹងទុក [1] | | | | | | | |
| 3.2 | មុខវិជ្ជានីមួយៗរួមចំណែកធ្វើឲ្យសម្រេចលទ្ធផលសិក្សាដែលរំពឹងទុកបានច្បាស់លាស់ [2] | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 3.3 | កម្មវិធីសិក្សាបង្កើតឡើងសមហេតុផល តាមលំដាប់លំដោយ ហើយត្រូវបានច្របាច់បញ្ចូលគ្នានិងទាន់សម័យ [3, 4, 5, 6] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## សំណួរវិនិច្ឆ័យ

- តើខ្លឹមសារនៃកម្មវិធីបានឆ្លុះបញ្ចាំងឲ្យឃើញពីលទ្ធផលរំពឹងទុកដែរឬទេ?
- តើមុខវិជ្ជាក្នុងកម្មវិធីបានរៀបចំទៅតាមលំដាប់លំដោយនិងមានទំនាក់ទំនងរលូននៃមុខវិជ្ជាគ្រឹះនិងមុខវិជ្ជាឯកទេស ដែលអាចឲ្យគេមើលឃើញក្នុងកម្មវិធីសិក្សាទាំងមូលបែបណា?
- តើមានតុល្យភាពសមស្របរវាងមុខវិជ្ជាទូទៅ និងឯកទេសដែរឬទេ?
- តើខ្លឹមសាររបស់កម្មវិធីទាន់សម័យដែរឬទេ?
- ហេតុអ្វីបានជាត្រូវជ្រើសរើសរចនាសម្ព័ន្ធកម្មវិធីនេះ?
- តើរចនាសម្ព័ន្ធនៃកម្មវិធីអប់រំត្រូវបានផ្លាស់ប្តូរដែរឬទេក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ? ប្រសិនបើមានការផ្លាស់ប្តូរ តើមកពីមូលហេតុអ្វី?
- តើកម្មវិធីជួយជំរុញដល់កម្មវិធីនានា ការចល័តនិស្សិតនិង/ឬការអប់រំឆ្លងដែនដែរទេ?
- តើទំនាក់ទំនងរវាងមុខវិជ្ជាគ្រឹះ មុខវិជ្ជាមធ្យមនិងជំនាញ នៅក្នុងផ្នែកចាំបាច់ និងផ្នែកដែលមានជំរើសល្មមសមហេតុផលដែរឬទេ?
- តើកម្មវិធីមានរយៈពេលប៉ុន្មាន?
- តើរយៈពេលនិងលំដាប់លំដោយមុខវិជ្ជានីមួយៗមានប៉ុន្មាន?តើសមរម្យដែរទេ?
- តើគេប្រើប្រាស់គោលធៀបអ្វីក្នុងការបង្កើតកម្មវិធី និងមុខវិជ្ជានានា?
- តើវិធីសាស្រ្តបង្រៀននិងរៀន និងការវាយតម្លៃនិស្សិតត្រូវជ្រើសរើសយ៉ាងដូចម្តេងដើម្បីឲ្យស្របជាមួយលទ្ធផលសិក្សាដែលរំពឹងទុក។

## ប្រភពនៃភស្តុតាង/ឯកសារចាំបាច់

ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជា

- សលាកបត្រព័ត៌មាន បណ្ណព័ត៌មាន ឬព្រឹត្តិបត្រព័ត៌មាន ផ្សេងៗទាក់ទងនឹងមុខវិជ្ជា
- ផែនទីសម្រាប់កម្មវិធីសិក្សា
- តារាងម៉ាទ្រីសអំពីជំនាញ
- ធាតុចូលនិងមតិផ្តល់ត្រឡប់វិញរបស់ភាគីពាក់ព័ន្ធ
- គេហទំព័ររបស់សាកលវិទ្យាល័យ និងមហាវិទ្យាល័យ
- កំណត់ហេតុ និងឯកសារនានានៃការពិនិត្យឡើងវិញលើកម្មវិធីសិក្សា

- របាយការណ៍នានាស្តីពីការទទួលស្គាល់គុណភាពនិងការប្រៀបធៀបជាគោល

**៣.ការរៀបចំនិងអភិវឌ្ឍកម្មវិធី**

ការរៀបចំនិងអភិវឌ្ឍកម្មវិធីជាធម្មតាចាប់ផ្តើមជាមួយការវិភាគតម្រូវការ។ ការប្រមូលព័ត៌មានអំពីតម្រូវការរបស់អ្នកពាក់ព័ន្ធនិងទីផ្សារ និងស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យនិងប្រភពធនធានគឺជាជំហានទីមួយយ៉ាងសំខាន់នៃដំណើរការវិភាគតម្រូវការក្នុងការកំណត់ភាពចាំបាច់សម្រាប់ពិនិត្យឡើងវិញលើកម្មវិធីដែលមានស្រាប់ ឬកម្មវិធីថ្មី។ ដំណើរការរៀបចំនិងអភិវឌ្ឍកម្មវិធីដោយប្រើក្របខណ្ឌរៀបចំកម្មវិធីសិក្សាត្រឡប់ថយក្រោយដូចបានបង្ហាញក្នុងរូបភាព៣.១




រូបភាព៣.១៖ក្របខណ្ឌរៀបចំកម្មវិធីសិក្សាត្រឡប់ថយក្រោយ

សំណួរពាក់ព័ន្ធដើម្បីសួរនៅដំណាក់កាលវិភាគតម្រូវការរួមមាន៖

- តើមានអ្វីចន្លោះក្នុងកម្មវិធីសិក្សានៃកម្មវិធីដែលមានស្រាប់?
- តើអ្នកពាក់ព័ន្ធ ដូចជា និយោជក ស្ថាប័នអាជីព ក្រសួងនិងភ្នាក់ងាររដ្ឋនានា ភ្នាក់ងារទទួលស្គាល់គុណភាពអប់រំនិងសង្គមជាទូទៅមានតម្រូវការអ្វីខ្លះ?
- តើចំណុចខ្វះចន្លោះនិងតម្រូវការនានាអាចបំពេញបានទេដោយពិនិត្យមើលកម្មវិធីដែលមានស្រាប់ឡើងវិញ ឬរៀបចំអភិវឌ្ឍន៍កម្មវិធីសិក្សាថ្មី?

- តើកម្មវិធីស៊ីសង្វាក់គ្នាជាមួយបេសកកម្មនិងគោលដៅរបស់សាកលវិទ្យាល័យដែរទេ?
- តើមានក្រុមជំនាញផ្នែកអប់រំនៅសាកលវិទ្យាល័យដើម្បីគាំទ្រដល់កម្មវិធីទេ?
- តើមានធនធាននិងរចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីគាំទ្រដល់កម្មវិធីទេ?

បន្ទាប់តម្រូវការបានកំណត់ គួររៀបចំសរសេរហេតុផលសមស្របសម្រាប់អភិវឌ្ឍន៍កម្មវិធី។ ហេតុផលសមស្របមានអធិប្បាយពីគោលបំណងអប់រំទូទៅ និងប្រើប្រាស់ជាការណែនាំក្នុងការរៀបចំប្លង់មេរៀនហើយស៊ីសង្វាក់នឹងមុខវិជ្ជានានា។ហេតុផលសមស្របនេះត្រូវចាត់បញ្ចូលក្នុងការបង្កើនទុន ឬសមត្ថភាពនិស្សិតដែលអាចប្តូរផ្លាស់ជាលទ្ធផលសិក្សារំពឹងទុកដោយប្រើប្រាស់តារាងវគ្គសាស្ត្រអប់រំដូចបានបកស្រាយក្នុងរូបភាព៣.២ ខាងក្រោម៖

| Stakeholders | Needs | Graduate Attributes | Expected Learning Outcomes | Proposed Modules/ Courses |
|---|---|---|---|---|
| **University** (Institution, faculty, department, faculty members) *What the university wants to teach?* | | | | |
| **Learners** (Current students and Alumni) *What the students want to learn?* | | | | |
| **Society** (Employers, government agencies, professional bodies) *What the society expects the graduate to have?* | | | | |

រូបភាព៣.២៖បំណាកស្រាយតម្រូវការអ្នកពាក់ព័ន្ធក្នុងកម្មវិធីសិក្សា

## *១. លក្ខណវិនិច្ឆ័យ៤៖ យុទ្ធវិធីបង្រៀន និងរៀន*

*១. យុទ្ធវិធីបង្រៀន និងរៀនត្រូវបានអនុវត្តជារឿយៗតាមរយៈទស្សនវិជ្ជាអប់រំរបស់សាកលវិទ្យាល័យ។ ទស្សនវិជ្ជាអប់រំ អាចត្រូវបានកំណត់ជាបណ្តុំនៃជំនឿដែលជះឥទ្ធិពលទៅលើអ្វីដែលនិស្សិតគួរត្រូវបានបង្រៀន និងអំពីរបៀបដែលបង្រៀននិស្សិត។ វាកំណត់គោលបំណងនៃការអប់រំ តួនាទីរបស់ គ្រូបង្រៀន និងនិស្សិត ព្រមទាំងអ្វីដែលត្រូវបានបានបង្រៀន និងបង្រៀនតាមវិធីណា។*

*២. ការរៀនសូត្រដែលមានគុណភាព ត្រូវបានគេយល់ថាជាបង្កើតចំណេះយ៉ាងសកម្មដោយនិស្សិត ហើយមិនមែនជាអ្វីដែលគ្រាន់តែត្រូវបានផ្ទេរដោយគ្រូបង្រៀននោះទេ។ វាជាយុទ្ធវិធីរៀនស៊ីជម្រៅដែលស្វែងរកការបង្កើតចំណេះ និងសម្រេចបាននូវការយល់ដឹង។*

*៣. ការរៀនសូត្រដែលមានគុណភាពក៏អាស្រ័យយ៉ាងខ្លាំងទៅលើយុទ្ធវិធីដែលអ្នករៀនទទួលយកនៅពេលរៀន។ ក្នុងន័យនេះ វាក៏អាស្រ័យទៅលើគំនិតសិក្សាដែលអ្នករៀនប្រកាន់យក អំពីអ្វីដែល អ្នករៀនដឹងអំពីការរៀនរបស់ខ្លួន និងយុទ្ធសាស្ត្រដែលអ្នករៀនជ្រើសរើសប្រើប្រាស់។*

*៤. ការរៀនសូត្រដែលមានគុណភាពរួមបញ្ចូលគោលការណ៍នៃការរៀន។ និស្សិតរៀនបានល្អបំផុតនៅក្នុងបរិយាកាសសិក្សាដែលមានភាពរីករាយ មានការគាំទ្រ និងមានកិច្ចសហការណ៍។*

*៥. នៅក្នុងការលើកកម្ពស់ការទទួលខុស ត្រូវក្នុងការរៀន គ្រូបង្រៀនគួរតែ៖*

- *បង្កើតបរិយាកាសបង្រៀន-រៀនដែលជួយឲ្យ និស្សិតម្នាក់ៗចូលរួមក្នុងដំណើរការរៀនសូត្រប្រកបដោយការទទួលខុសត្រូវ និង*
- *ផ្តល់កម្មវិធីសិក្សាដែលអាចបត់បែនបាន និងធ្វើឲ្យអ្នកសិក្សាអាចបង្កើត ជម្រើសដែលមានអត្ថន័យពាក់ព័ន្ធនឹងខ្លឹមសារនៃមុខវិជ្ជា លំនាំនៃកម្មវិធី យុទ្ធវិធីនៃការវាយតម្លៃ ទម្រង់ផ្សេងៗ និងរយៈពេលនៃការសិក្សា។*

*៦. យុទ្ធវិធីនៃការបង្រៀន និងរៀនគួរលើកកម្ពស់ការរៀនសូត្រ ការរៀនពីរបៀបរៀន និងរបៀបធ្វើឲ្យនិស្សិតមានការប្តេជ្ញានៅក្នុងការសិក្សាពេញមួយជីវិត (ឧទា. ការប្តេជ្ញាចិត្តទៅលើការត្រិះរិះពិចារណា ជំនាញវិភាគព័ត៌មាន ឆន្ទៈពិសោធគំនិតនិងការអនុវត្តថ្មីៗ។ល។)។*

## ២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៤

| No. | យុទ្ធវិធីបង្រៀន និងរៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 4.1 | ទស្សនវិជ្ជាអប់រំត្រូវបានផ្សារភ្ជាប់ទៅគ្រប់ភាគីពាក់ព័ន្ធ [1] | | | | | | | |
| 4.2 | សកម្មភាពបង្រៀន និងរៀនត្រូវបានធ្វើឲ្យស្របទៅ នឹងការសម្រេចបាននៃលទ្ធផលសិក្សារំពឹងទុក [2, 3, 4, 5] | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **4.3** | សកម្មភាពបង្រៀន និងរៀនលើកកម្ពស់ការសិក្សាពេញមួយជីវិត [6] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

អនុលោមតាមគោល បំណងសំខាន់នៃឧត្តមសិក្សាក្នុងការជំរុញឲ្យមានការអប់រំរួមគ្នារបស់និស្សិត ការរៀនសូត្រប្រកបដោយ គុណភាពបណ្តាលឲ្យនិស្សិតទទួលបានជំនាញដូចខាងក្រោម៖

- សមត្ថភាពស្វែងរកចំណេះដឹងសម្រាប់ ខ្លួនឯង។ អ្នកសិក្សាមានជំនាញស្រាវជ្រាវ និងលទ្ធភាពវិភាគនិងសំយោគសម្ភារៈដែលគេប្រមូលបាន។ អ្នកសិក្សាស្វែងយល់ពីយុទ្ធសាស្រ្តរៀនផ្សេងៗគ្នា និងអាចជ្រើសរើសយុទ្ធសាស្រ្តដែលសមស្របបំផុត សម្រាប់អនុវត្តដោយខ្លួនឯង។
- សមត្ថភាពរក្សា ចំណេះដឹងបានយូរ។ យុទ្ធវិធីរៀនដែលសង្កត់ធ្ងន់ទៅលើការបង្កើតចំណេះដឹងជាជាងការចងចាំ អង្គហេតុតែប៉ុណ្ណោះ។
- សមត្ថភាពយល់ពីទំនាក់ទំនងរវាង ចំណេះដឹងចាស់ និងចំណេះដឹងថ្មី។ ការរៀនសូត្រដែលមានគុណភាពតែងតែព្យាយាមផ្តល់នូវព័ត៌មាន ពីប្រភពផ្សេងៗជាមួយគ្នា។
- សមត្ថភាពបង្កើតចំណេះដឹងថ្មី។ ការរៀនសូត្រដែលមាន គុណភាពស្វែងរកអ្វីដែលអ្នកដទៃបានរៀន និងបានតម្កល់ទុកជាឯកសារដែលយល់ដឹងពីទំនាក់ទំនង រវាងចំណេះដឹងនោះ និងបទពិសោធន៍ផ្ទាល់ខ្លួន ព្រមទាំងការរៀនសូត្រមុនៗដើម្បីអភិវឌ្ឍនូវការយល់ ដឹងថ្មីៗទៀត។
- សមត្ថភាពអនុវត្តនូវចំណេះដឹងអ្វី មួយដើម្បីដោះស្រាយបញ្ហា។
- សមត្ថភាពធ្វើឲ្យមានទំនាក់ ទំនងពីចំណេះដឹងអ្វីមួយទៅចំណេះដឹងផ្សេងទៀត។ អ្នករៀនសូត្រដែលមានគុណភាព បង្កើតនិងផ្តល់គំនិត និងសកម្មភាពឯករាជ្យស្ថិតក្នុងវិធីមួយតាមលំដាប់លំដោយ និងច្បាស់លាស់។
- មហិច្ឆតាចង់ដឹង បន្ថែម។ អ្នករៀនសូត្រដែលមានគុណភាពគឺជាអ្នករៀនពេញមួយជីវិត។

*លក្ខខណ្ឌចាំបាច់សម្រាប់ការរៀនសូត្រដែលមាន គុណភាពគឺ៖*

- ការរៀនសូត្រដែលមានគុណភាពកើតឡើងនៅពេលអ្នករៀនបាន ត្រៀមខ្លួនរួចជាស្រេច នៅក្នុងលក្ខខណ្ឌពុទ្ធិ និងអារម្មណ៍ ដើម្បីបំពេញតម្រូវការនៃកិច្ចការរៀនសូត្រ។
- ការរៀនសូត្រដែលមានគុណ-ភាពកើតឡើងនៅពេលអ្នករៀនមានហេតុផលសម្រាប់ការរៀនរបស់ខ្លួន
- ការរៀនសូត្រដែលមានគុណភាពកើតឡើងនៅពេលអ្នករៀនភ្ជាប់ចំណេះដឹងដែលមានទៅនឹងចំណេះដឹងថ្មី
- ការរៀនសូត្រដែលមាន គុណភាពកើតឡើងនៅពេលអ្នករៀនសកម្មនៅក្នុងដំណើរការរៀនសូត្រ

- ការរៀនសូត្រដែលមានគុណភាពកើតឡើងនៅពេលបរិយាកាសសិក្សាផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ អ្នករៀន។

គ្មានវិធីបង្រៀន និងរៀន តែមួយដែលមានសុពលភាពសម្រាប់គ្រប់ស្ថានភាពទាំងអស់នោះឡើយ។ គំនិតត្រូវតែបានផ្តល់ឲ្យ ចំពោះយុទ្ធវិធីបង្រៀន និងរៀននៅពីក្រោយកម្មវិធីសិក្សា។

## សំណួរវិនិច្ឆ័យ

- តើមានទស្សនវិជ្ជាអប់រំ ត្រូវបានចែករំលែកដល់បុគ្គលិកទាំងអស់ដែរឬទេ?
- តើភាពចម្រុះនៃ បរិស្ថានសិក្សាត្រូវបានលើកកម្ពស់ដោយរួមបញ្ចូលកម្មវិធីផ្លាស់ប្តូរដែរឬទេ?
- តើការបង្រៀនត្រូវបានផ្តល់ដោយដេប៉ាតឺ ម៉ង់ផ្សេងទៀតពេញចិត្តដែរឬទេ?
- តើ វិធីបង្រៀន និងរៀនត្រូវបានប្រើប្រាស់ស្របនឹងលទ្ធផលសិក្សារំពឹងទុកដែរឬទេ?
- តើបច្ចេកវិទ្យាត្រូវបានប្រើប្រាស់នៅក្នុងការ បង្រៀន និងរៀនដែរឬទេ?
- តើយុទ្ធវិធីនៃ ការបង្រៀន និងរៀនត្រូវបានវាយតម្លៃយ៉ាងដូចម្តេច? តើវិធីបង្រៀន និងរៀនដែលបានជ្រើសរើស ត្រូវគ្នានឹងលទ្ធផលសិក្សារបស់មុខវិជ្ជាដែរឬទេ? តើមានភាពផ្សេងៗគ្រប់គ្រាន់ទេនៅក្នុងវិធីបង្រៀន និងរៀនទាំងនោះ?
- តើមានឧបសគ្គផ្សេងៗ ទៀតទេដែលរារាំងវិធីបង្រៀន និងរៀនដែលចង់បានមិនឲ្យប្រើកើត (ឧ. ចំនួននិស្សិត ហេដ្ឋារចនា សម្ព័ន្ធ ជំនាញបង្រៀន។ល។)?

*ប្រសិនបើការស្រាវជ្រាវជាកម្មភាពស្នូលសម្រាប់ សាកលវិទ្យាល័យ៖*

- តើនៅពេលណាដែល និស្សិតមកទាក់ទងពាក់ព័ន្ធនឹងការងារស្រាវជ្រាវរបស់ខ្លួននៅពេលដំបូង?
- តើ អន្តរទំនាក់ទំនងរវាងការអប់រំ និងការស្រាវជ្រាវត្រូវបានបង្ហាញយ៉ាងដូចម្តេចនៅក្នុងកម្មវិធី?
- តើលទ្ធផលស្រាវជ្រាវត្រូវបានអនុវត្តយ៉ាងដូច ម្តេចនៅក្នុងកម្មវិធី?

*ប្រសិនបើការងារអនុវត្ត និង/ឬសេវាសហគមន៍ជាទិដ្ឋភាពជាក់លាក់នៃយុទ្ធវិធីបង្រៀន និងរៀន៖*

- តើការងារអនុវត្តជាផ្នែកមួយ ចាំបាច់ ឬជាជម្រើសមួយនៃកម្មវិធី?
- តើសកម្មភាពនេះត្រូវបានផ្តល់ឲ្យ ប៉ុន្មានក្រេឌីត?
- តើកម្រិតនៃការងារ អនុវត្ត និង/ឬសេវាសហគមន៍ពេញចិត្តដែរឬទេ?
- តើផលប្រយោជន៍អ្វីខ្លះដែលសហគមន៍ទទួលបានពីសេវាដែលផ្តល់ដោយកម្មវិធី?
- តើផលប្រយោជន៍អ្វី ខ្លះ ដែលនិយោជក និងនិស្សិតទទួលបានពីការងារអនុវត្ត?
- តើមានឧបសគ្គអ្វី ខ្លះទេ នៅក្នុងការងារអនុវត្ត? បើមាន តើអ្វីដែលបង្កើតឲ្យមានឧបសគ្គទាំងនោះ?
- តើនិស្សិតត្រូវបានណែនាំយ៉ាងដូចម្តេច?

- តើការវាយតម្លៃត្រូវបានធ្វើយ៉ាងដូចម្តេច?

**ប្រភពនៃភស្តុតាង/ឯកសារចាំបាច់**

- ទស្សនវិជ្ជាអប់រំ
- ភស្តុតាងនៃការសិក្សាតាមរយៈការបញ្ចេញសកម្មភាពដូចជា គម្រោង ការងារអនុវត្ត កិច្ចការស្រាវជ្រាវ ការងារពាក់ព័ន្ធនឹងសហគ្រាស។ល។
- យោបល់ត្រឡប់ពីនិស្សិត
- ការរៀនតាមរយៈប្រព័ន្ធអេឡិចត្រូនិក (Online)
- ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជា
- របាយការណ៍ពីការចុះកម្មសិក្សា
- ការចូលរួមពីសហគមន៍
- អនុស្សារណៈយោគយល់



| Revised Bloom’s Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្ត្របង្រៀន** | **វិធីសាស្ត្រវាយតម្លៃ** |
| **កម្រិតចងចាំ**<br>ប្រមូល ឬរំលឹកឡើងវិញពីចំណេះដឹងពាក់ព័ន្ធពីការចងចាំ រយៈពេលវែងដែលបានរៀនពីមុន | កំណត់អត្តន័យ<br>ពិពណ៌នា<br>កំណត់អត្តសញ្ញាណ<br>ដាក់ស្លាកសម្គាល់<br>តម្រៀប<br>ផ្គូរផ្គង<br>ដាក់ឈ្មោះ<br>រៀបចំគ្រោង<br>រំឭក<br>ចំណាំ<br>បង្កើតឡើងវិញ<br>ជ្រើសរើស<br>បញ្ជាក់<br>កំណត់ទីតាំង | ការបង្រៀនដោយលើកឧទាហរណ៍<br>ពន្យល់<br>ការឧទ្ទេស<br>សំណួរតម្រង់ទិស<br>ការសម្តែងបង្ហាញ<br>ការហ្វឹកហាត់ និងអនុវត្តន៍<br>ការសម្តែងតួ<br>ការធ្វើជាគំរូ<br>ល្បែងជំនួយការចងចាំ<br>ល្បែងផ្គុំ/ស្រាយបញ្ហា<br>លប់ និងបំពេញឡើងវិញ | សំណួរពហុជ្រើសរើស<br>សំណួរ ចម្លើយខ្លីៗ<br>សំណួរសរសេរ<br>តេស្តការសម្តែង<br>ផ្គុំនិងផ្គូរផ្គង<br>ធ្វើបទបង្ហាញ<br>(ឧ. ការសូត្រ និងសង្ខេប)<br>ផ្គុំពាក្យ/រូបភាព/ខ្លឹមសារ |
| **កម្រិតយល់ដឹង**<br>បង្កើតន័យតាមរយៈការបង្រៀនរួមជាមួយលំហាត់ផ្ទាល់មាត់ ការសរសេរ និងទំនាក់ទំនងក្រាហ្វិក | បង្ហាញ<br>ការពារ<br>ប្រៀបធៀប<br>ប៉ាន់ប្រមាណ<br>ពន្យល់<br>ធ្វើចំណាត់ថ្នាក់<br>សន្និដ្ឋាន | ការឧទ្ទេស<br>ការបង្រៀនដោយមានឧទាហរណ៍<br>បញ្ជាក់<br>ការសម្តែងតួឬ ការដើរតួ<br>ល្បែង | សំណួរពហុជ្រើសរើស<br>សំណួរចម្លើយខ្លីៗ<br>ការធ្វើបទបង្ហាញ<br>តេស្តការសម្តែង<br>តែងសេចក្តី<br>ការពន្យល់ន័យដើម<br>ការរៀបចំប័ណ្ណឬបដា |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| កម្រិត | កិរិយាស័ព្ទសកម្ម | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
| | បកស្រាយ<br>ពន្យល់ន័យដើម<br>ព្យាករឬទាយ<br>ការសរសេរឡើងវិញ<br>សង្ខេប<br>បកប្រែ | ការពិភាក្សា<br>ការបំផុសគំនិត,<br>ពង្រាងគំនិត<br>ការបង្កើតគំនិត<br>ដៅគំនិត ពង្រាយ<br>មែកធាងគំនិត គំរូ,<br>ម៉ូដែល | |
| **កម្រិតអនុវត្តន៍**<br>អនុវត្ត ឬប្រើសេចក្តីណែនាំទៅតាមកាលៈទេសៈឬស្ថានភាពជាក់ស្តែងណាមួយ | អនុវត្ត<br>រៀបចំ ចាត់ចែង<br>សម្តែង ធ្វើវិនាដកម្ម<br>ដោះស្រាយបញ្ហា<br>បង្កើត<br>បង្ហាញ ឬសម្តែង<br>ស្វែងរក<br>កនាំ<br>កែសម្រួល<br>ប្រតិបត្តិ<br>ព្យាករឬទាយ<br>រៀបចំ ត្រៀម បម្រុង<br>ផលិត/បង្កើត<br>ភ្ជាប់ទំនាក់ទំនង/និទាន | ការបង្ហាញ<br>ដំណោះស្រាយបញ្ហា<br>ទស្សនកិច្ចសិក្សា<br>ការពិសោធន៍<br>ការបង្ហាញនិងអធិប្បាយ<br>ការផ្គុំនិងផ្គូរផ្គង<br>ការដើរតួរ ឬការសម្តែងតួ<br>ការសិក្សាអង្គហេតុ<br>ការរៀបគម្រោង<br>កិច្ចការអនុវត្តន៍ | តម្រៀបឡើងវិញ<br>ផ្គុំនិងផ្គូរផ្គង<br>ផ្គូរផ្គង<br>គម្រោង<br>បទបង្ហាញ<br>បដាបង្ហាញ<br>កម្មសិក្សា/ការងារទីវាល<br>កិច្ចការអនុវត្តន៍<br>សិក្សាអង្គហេតុ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្ត្របង្រៀន** | **វិធីសាស្ត្រវាយតម្លៃ** |
| | បង្ហាញ ដាក់តាំង<br>ជ្រើសរើស | | |
| **កម្រិតវិភាគ**<br>បែងចែកចំណេះដឹងទៅតាមផ្នែកគោល និងកំណត់ទំនាក់ទំនងរចនាសម្ព័ន្ធ ឬគោលបំណងជារួម | វិភាគ<br>រាយលម្អិត ឬវិភាគលម្អិត<br>ប្រៀបធៀប<br>ជ្រើសរើស<br>បដិមតិ<br>បំបែក<br>ចំណាត់ថ្នាក់ | សិក្សាអង្គហេតុ<br>គម្រោងស្រាវជ្រាវជាក្រុម<br><br>កិច្ចការអនុវត្តន៍<br>ការពិសោធន៍<br><br>ការងារទីវាល<br>ការសិក្សាដោយផ្អែកលើបញ្ហា<br>ការពិភាក្សាដេញដោល<br>Researchការសិក្សាស្រាវជ្រាវ<br>Concept formulation<br>ការបង្កើតទស្សនៈ | តែងសេចក្តី<br>ប័ណ្ណប្រកាសឬបដាបង្ហាញ<br>សំណេររបាយការណ៍<br><br>បទបង្ហាញ<br>កម្រងឯកសារ<br>គម្រោងស្រាវជ្រាវ<br>តេស្តអនុវត្តសម្តែង<br>ការសិក្សាស្រាវជ្រាវ<br>សិក្សាអង្គហេតុ<br>ការរិះគន់<br>ការវិភាគលើភាពខ្លាំងខ្សោយ កាលានុវត្តភាព និងហានិភ័យ (SWOT) |
| **កម្រិតវាយតម្លៃ**<br>ធ្វើការវាយតម្លៃដោយផ្អែកលើលក្ខ | ចាត់ថ្នាក់<br>វាយតម្លៃ<br><br>ពិនិត្យតាមដាន | វិធីសាស្ត្រស្រាវជ្រាវតាមបែបសាកសួរ ឬរុករក<br>វិភាគបញ្ហា | ការបង្ហាញស្រាវជ្រាវ និងសំណេររបាយការណ៍<br>តេស្តសំណេរ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្ត្របង្រៀន** | **វិធីសាស្ត្រវាយតម្លៃ** |
| ណៈ វិនិច្ឆ័យនិងនិយាមបទដ្ឋាន | ត្រួតពិនិត្យ<br>តេស្ត<br>វិនិច្ឆ័យ | ការពិភាក្សាដេញដោល<br>ការធ្វើពិសោធន៍<br>គម្រោងស្រាវជ្រាវ<br>កម្មសិក្សា<br>បង្រៀនដៃគូ<br>ការវិភាគលើភាពខ្លាំង ខ្សោយ កាលានុវត្តភាព និងហានិភ័យ<br>(SWOT) | ការពិភាក្សាដេញដោលកាត់ក្តីសាកល្បងឬសវនាការប្រឌិត<br>តែងសេចក្តី<br>លទ្ធផលពិសោធន៍<br>គម្រោងស្រាវជ្រាវ<br>តេស្តលើសមត្ថភាពការងារ |
| **កម្រិតបង្កើតនិងច្នៃ**<br>ដាក់បញ្ចូលសមាសភាពរួមគ្នាដើម្បីបង្កើតបណ្តាញឬតួនាទីទាំងមូល ឬ រៀបចំសមាសភាពឡើងវិញឲ្យទៅជាគំរូឬរចនាសម្ព័ន្ធថ្មី ។ | បង្កើត<br>ធ្វើផែនការ<br>និពន្ធ<br>អភិវឌ្ឍ<br>ច្នៃនិងបង្កើតថ្មី<br>ច្នៃប្រឌិត<br>រៀបចំ<br>ស្ថាបនា<br>ផលិត<br>ចងក្រង<br>ធ្វើគម្រោង, គូរគម្រោង<br>បង្កើតគំនិតថ្មី | -ដំណោះស្រាយបញ្ហា<br>សិក្សាអង្គហេតុ<br>គម្រោងស្រាវជ្រាវ<br>កម្មសិក្សាជាក់ស្តែង<br>ការសិក្សាតាមពិសោធន៍<br>ទស្សនកិច្ចសិក្សា<br>- បង្កើតគំរូ | ធ្វើបទបង្ហាញ<br>តែងសេចក្តី<br>ព្រឹត្តិប័ត្រ<br>ការសរសេរ របាយការណ៍ស្រាវជ្រាវ<br>បឋមរូប ឬការបង្កើតគំរូ<br>ការសម្តែង<br>ការតែងនិពន្ធ (រឿង ចម្រៀង កំណាព្យ...)<br><br>ការសិក្សាស្រាវជ្រាវ<br>គម្រោងស្រាវជ្រាវ |

*១. លក្ខណវិនិច្ឆ័យ៥៖ ការវាយតម្លៃនិស្សិត*

*១.ការវាយតម្លៃនិស្សិតគ្របដណ្តប់លើ*

- *ការចូលរៀនរបស់និស្សិតថ្មី*
- *ការវាយតម្លៃបន្តអំឡុងពេលសិក្សាមុខវិជ្ជា*
- *ប្រឡងចុងក្រោយ/ប្រឡងចេញមុនពេលបញ្ចប់ការសិក្សា*

*២. ក្នុងការគាំទ្រដល់ការតម្រង់ទៅរកប្រយោជន៍ វិធីសាស្ត្រវាយតម្លៃផ្សេងៗ គួរត្រូវអនុម័តឲ្យស្របទៅនឹងលទ្ធផលសិក្សារំពឹងទុក។ គេគួរវាស់វែងការសម្រេចបាននៃលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីនិងមុខវិជ្ជានានា។*

*៣. វិធីសាស្ត្រនៃការវាយតម្លៃមួយចំនួនត្រូវបានប្រើក្នុងលក្ខណៈជាផែនការដើម្បីបម្រើឲ្យគោលបំណងនៃការវិនិច្ឆ័យ ការវាយតម្លៃក្នុងពេលសិក្សា*

*និងការវាយតម្លៃចុងក្រោយពេលសិក្សា។*

*៤. ការវាយតម្លៃនិស្សិតដែលរួមមានការកំណត់ពេលវេលា វិធីសាស្ត្រ បទប្បញ្ញត្តិ ទម្ងន់ខ្លឹមសារវិញ្ញាសាការបរិយាយនិទ្ទេសបទ និងការកម្រិតពិន្ទុគួរតែច្បាស់លាស់និងផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ។*

*៥. ស្តង់ដានានាដែលប្រើប្រាស់ក្នុងទម្រង់ការវាយតម្លៃគឺត្រូវច្បាស់លាស់និងមានសង្គតិភាពគ្រប់កម្មវិធី។*

*៦. នីតិវិធី និងវិធីសាស្ត្រនានាត្រូវបានប្រើប្រាស់ដើម្បីធានាថាការវាយតម្លៃនិស្សិតគឺមានសុពលភាព អាចជឿទុកចិត្តបាន និងត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវ។*

*៧. ភាពជឿទុកចិត្តបាន និងសុពលភាពនៃវិធីសាស្ត្រវាយតម្លៃគួរត្រូវចងក្រងជាឯកសារ និងវាយតម្លៃជាទៀងទាត់ ហើយវិធីសាស្ត្រវាយតម្លៃថ្មីៗ ត្រូវបានអភិវឌ្ឍ និងអនុវត្តសាកល្បង។*

*៨. និស្សិតងាយស្រួលចូលរួមទៅនឹងនីតិវិធីធ្វើបណ្តឹងតវ៉ាសមហេតុសមផល។*

**២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៥**

| No. | ការវាយតម្លៃនិស្សិត | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 5.1 | ការវាយតម្លៃនិស្សិតត្រូវជាប្រយោជន៍សមស្របតាមជោគជ័យនៃលទ្ធផលសិក្សារំពឹងទុក[1, 2] | | | | | | | |
| 5.2 | ការវាយតម្លៃនិស្សិតត្រូវតែផ្តល់ឲ្យនិស្សិតបានយល់ដឹងពី ការកំណត់ពេលវេលា វិធីសាស្ត្រ បទប្បញ្ញត្តិ ទម្ងន់ខ្លឹមសារវិញ្ញាសា និងកម្រិតពិន្ទុទៅតាមការបរិយាយនិទ្ទេសបទឲ្យបានច្បាស់លាស់ [4, 5] | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 5.3 | វិធីសាស្ត្រវាយតម្លៃនានាត្រូវមានបរិយាយនិទ្ទេសបទនៃការវាយតម្លៃ ទម្រង់ផ្តល់ពិន្ទុ ដើម្បីធានាសុពលភាព មានទំនុកចិត្ត និងយុត្តិធម៌ដល់ការវាយតម្លៃនិស្សិត [6, 7] | | | | | | | |
| 5.4 | ផលទទួលបានពីការវាយតម្លៃគឺជាឱកាសជួយកែសម្រួលដល់ការសិក្សា[3] | | | | | | | |
| 5.5 | និស្សិតមានឱកាសរៀបចំនីតិវិធីបណ្តឹងតវ៉ា[8] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

ការវាយតម្លៃនិស្សិតគឺជាធាតុមួយដ៏សំខាន់បំផុតនៃការអប់រំកម្រិតឧត្តមសិក្សា។ រាល់លទ្ធផលចុងក្រោយនៃការវាយតម្លៃមានឥទ្ធិពលធំធេងទៅលើអាជីពនាពេលអនាគតរបស់និស្សិត។ ដូច្នេះវាជាការសំខាន់ណាស់ ដែលការវាយតម្លៃត្រូវអនុវត្តតាមវិជ្ជាជីវៈគ្រប់ពេល និងត្រូវយកមកពិចារណារលើចំណេះដឹងឲ្យបានទូលំទូលាយទៅលើដំណើរការនៃការធ្វើតេស្តសាកល្បង និងការប្រឡងផ្សេងៗ។ ការវាយតម្លៃក៏បានផ្តល់នូវព័ត៌មានដ៏មានតម្លៃសម្រាបស្ថាប័ន អំពីប្រសិទ្ធភាពក្នុងការគាំទ្រដល់ការបង្រៀន និង អ្នកសិក្សា។ នីតិវិធីវាយតម្លៃនិស្សិតត្រូវគេរំពឹងថា៖

- ត្រូវបានរៀបចំឡើងដើម្បីវាស់វែងលើសមិទ្ធផលនៃលទ្ធផលសិក្សារំពឹងទុក ។
- គឺស្របទៅនឹងគោលបំណង ថាតើការវិនិច្ឆ័យ ការវាយតម្លៃក្នុងពេលសិក្សា ឬការវាយតម្លៃចុងក្រោយ ត្រូវមានលក្ខណវិនិច្ឆ័យក្នុងការផ្តល់ពិន្ទុច្បាស់លាស់ និងអាចប្រើប្រាស់បាន។
- ត្រូវបានប្រើប្រាស់ដោយអ្នកដែលយល់ដឹងនូវតួនាទីនៃការវាយតម្លៃ តាមការរីកចម្រើនរបស់និស្សិតដើម្បីឆ្ពោះទៅរកការទទួលបាននូវចំណេះដឹង និងជំនាញដែលទាក់ទងទៅនឹងគុណវុឌ្ឍិដែលបានគ្រោងទុក ដែលមិនពឹងផ្អែកទាំងស្រុងទៅលើការវាយតម្លៃ របស់បុគ្គលត្រួតពិនិត្យតែម្នាក់នោះទេ។

- យកចិត្តទុកដាក់ទៅលើផលវិបាកនានាដែលអាចកើតមានឡើងក្នុងបទបញ្ញត្តិនៃការប្រឡង
- មានបទប្បញ្ញត្តិច្បាស់លាស់ក្នុងការគ្រប់គ្រងអវត្តមាននិស្សិត និស្សិតមានជំងឺ និងការបន្ធូរបន្ថយក្នុងកាលៈទេសៈផ្សេងៗទៀត។
- ធានាថាការវាយតម្លៃត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយផ្អែកទៅលើ និតិវិធីដែលបានកំណត់ដោយគ្រឹះស្ថាន។
- ជាប្រធានបទដើម្បីបញ្ជាក់ឡើងវិញលើការងាររដ្ឋបាលក្នុងការធានាឲ្យបាននូវប្រសិទ្ធភាពនៃនីតិវិធី

- ជូនដំណឹងដល់និស្សិតអំពីការវាយតម្លៃដែលប្រើបាស់សម្រាប់កម្មវិធី អ្វីដែលជាការប្រឡង ឬជាវិធីសាស្ត្រនៃការវាយតម្លៃផ្សេងៗ ដែលជាប្រធានបទសម្រាប់អ្វីដែលក្លាយជាការរំពឹងទុកនៃលទ្ធផល និងលក្ខណវិនិច្ឆ័យដែលនឹងត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃក្នុងការបង្ហាញសមត្ថភាពរបស់ពួកគេ។

## សំណួរវិនិច្ឆ័យ

- តើការវាយតម្លៃបានធ្វើចំពោះនិស្សិតថ្មីដែលទើបចុះឈ្មោះចូលរៀនដែរឬទេ?
- តើការវាយតម្លៃចេញបានធ្វើចំពោះនិស្សិតដែលបញ្ចប់ការសិក្សាដែរឬទេ?
- តើការវាយតម្លៃនិងរាល់ការប្រឡងមានទំហំគ្របដណ្តប់ខ្លឹមសារមុខវិជ្ជានិងកម្មវិធីសិក្សាប៉ុណ្ណា?តើការវាយតម្លៃនិងរាល់ការប្រឡងមានទំហំគ្របដណ្តប់វត្ថុបំណងទាំងអស់នៃមុខវិជ្ជានិងកម្មវិធីសិក្សាទាំងមូលយ៉ាងណា?
- តើការវាយតម្លៃមានផ្តោតលើសមត្ថភាពដែរឬទេ?
- តើការវាយតម្លៃបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នាដែរឬទេ?តើវិធីសាស្ត្រទាំងនោះមានអ្វីខ្លះ?
- តើមានលក្ខណវិនិច្ឆ័យសម្រាប់ការប្រឡងធ្លាក់/ជាប់ច្បាស់លាស់ដែរឬទេ?
- បទប្បញ្ញត្តិសម្រាប់ការប្រឡង/ការវាយតម្លៃច្បាស់លាស់ដែរឬទេ?
- តើមានការការពារនៅហ្នឹងកន្លែងដើម្បីធានាឲ្យបាននូវវត្ថុបំណងនៃការវាយតម្លៃដែរឬទេ?
- តើនិស្សិតពេញចិត្តនឹងនីតិវិធីទាំងនោះដែរឬទេ? តើមានបណ្តឹងតវ៉ាពីនិស្សិតដែរឬទេ?
- តើមានបញ្ញតិច្បាស់លាស់សម្រាប់ការវាយតម្លៃឡើងវិញដែរឬទេ? តើនិស្សិតពេញចិត្តចំពោះវិធានការទាំងនោះដែរឬទេ?

ទម្រង់ពិសេសនៃការវាយតម្លៃនិស្សិតគឺជាគម្រោងចុងក្រោយ(សារណា និក្ខេបបទឬជាគម្រោង)។កិច្ចការនេះទាមទារឲ្យនិស្សិតបង្ហាញនូវចំណេះដឹង ជំនាញ និងសមត្ថភាព ដើម្បីបញ្ចេញចំណេះដឹងក្នុងស្ថានភាពថ្មី។

- តើមានបទប្បញ្ញត្តិច្បាស់លាល់សម្រាប់គម្រោងចុងក្រោយដែរឬទេ?
- តើមានបង្កើតលក្ខខណ្ឌអ្វីមួយសម្រាប់វាយតម្លៃគម្រោងចុងក្រោយដែរឬទេ?
- តើការត្រៀមបង្កើតគម្រោងចុងក្រោយពាក់ព័ន្ធ(ក្នុងន័យដូចជាខ្លឹមសារ វិធីសាស្ត្រ និងជំនាញ) អ្វីខ្លះ?
- តើមានកម្រិតនៃការពេញចិត្តសម្រាប់គម្រោងចុងក្រោយដែរឬទេ?
- តើមានឧបសគ្គកើតឡើងលើការបង្កើតគម្រោងចុងក្រោយដែរឬទេ?ប្រសិនមានហេតុអ្វី?
- តើនិស្សិតត្រូវគេបង្វឹកយ៉ាងម៉េច?

**ប្រភពនៃភស្តុតាង/ឯកសារចាំបាច់**

- គំរូការវាយតម្លៃក្នុងពេលសិក្សា គម្រោងការងារ និក្ខេបបទ ការប្រឡងចុងក្រោយ
- បរិយាយនិទ្ទេសបទ(ជាឯកសារដែលបញ្ជាក់ច្បាស់ពីការរំពឹងសម្រាប់ការវាយតម្លៃដោយធ្វើបញ្ជីលក្ខខណ្ឌ ឬត្រូវរាប់បញ្ចូលអ្វី និងបរិយាយកម្រិតគុណភាពចាប់ពីវិសេស(ល្អបំផុត)ដល់ខ្សោយ។ ជារឿយគេប្រើដើម្បីផ្តល់ពិន្ទុលើការងារសិស្ស ប៉ុន្តែគេអាចប្រើក្នុងគោលបំណងផ្សេងហើយសំខាន់ជាងនេះ គឺកម្រិតតួនាទី៖ បរិយាយនិទ្ទេសបទអាចបង្រៀនពីវិធីឲ្យចេះវាយតម្លៃដែរ)
- ទម្រង់នៃការផ្តល់ពិន្ទុ
- វិធីកែសម្រួល
- នីតិវិធីបណ្តឹង
- ចំណុចលម្អិតនៃកម្មវិធី និងមុខវិជ្ជា
- បទប្បញ្ញត្តិសម្រាប់ការប្រឡង

**៣.ប្រភេទនៃការវាយតម្លៃនិស្សិត**

ការវាយតម្លៃក្នុងបរិបទអប់រំពាក់ព័ន្ធការសម្រេចចិត្ត ការប្រមូលព័ត៌មាននិងការវិនិច្ឆ័យនានាអំពីភស្តុតាងពាក់ព័ន្ធនឹងការសម្រេចលទ្ធផលសិក្សា។ ដូច្នេះការវាយតម្លៃនិស្សិតត្រូវស៊ីសង្វាក់គ្នាជាមួយការសម្រេចលទ្ធផលសិក្សាដូចបានបង្ហាញក្នុងរូបភាព៥.១



៥.វិធីសាស្ត្រវាយតម្លៃ

មានវិធីសាស្ត្រវាយតម្លៃខុសៗគ្នាជាច្រើននិងវិធីសាស្ត្រវាយតម្លៃអ្វីក៏ដោយដែលគេសម្រេចចិត្តប្រើ វាគួរតែច្បាស់លាស់ស្របជាមួយលទ្ធផលសិក្សានិងសកម្មភាពរៀននិងបង្រៀនដូចបានបង្ហាញក្នុងរូបភាព៥.២

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្ត្របង្រៀន** | **វិធីសាស្ត្រវាយតម្លៃ** |
| **កម្រិតចងចាំ**<br>ប្រមូល ឬរំលឹកឡើងវិញពីចំណេះដឹងពាក់ព័ន្ធពីការចងចាំ រយៈពេលវែងដែលបានរៀនពីមុន | កំណត់អត្តន័យ<br>ពិពណ៌នា<br>កំណត់អត្តសញ្ញាណ<br>ដាក់ស្លាកសម្គាល់<br>តម្រៀប<br>ផ្គូរផ្គង<br>ដាក់ឈ្មោះ<br>រៀបចំគ្រោង<br>រំឭក<br>ចំណាំ<br>បង្កើតឡើងវិញ<br>ជ្រើសរើស<br>បញ្ជាក់<br>កំណត់ទីតាំង | ការបង្រៀនដោយលើកឧទាហរណ៍<br>ពន្យល់<br>ការឧទ្ទេស<br>សំណួរតម្រង់ទិស<br>ការសម្តែងបង្ហាញ<br>ការហ្វឹកហាត់ និងអនុវត្តន៍<br>ការសម្តែងតួ<br>ការធ្វើជាគំរូ<br>ល្បែងជំនួយការចងចាំ<br>ល្បែងផ្គុំ/ស្រាយបញ្ហា<br>លប់ និងបំពេញឡើងវិញ | សំណួរពហុជ្រើសរើស<br>សំណួរ ចម្លើយខ្លីៗ<br>សំណួរសរសេរ<br>តេស្តការសម្តែង<br>ផ្គុំនិងផ្គូរផ្គង<br>ធ្វើបទបង្ហាញ<br>(ឧ. ការសូត្រ និងសង្ខេប)<br>ផ្គុំពាក្យ/រូបភាព/ខ្លឹមសារ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| កម្រិត | កិរិយាស័ព្ទសកម្ម | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
| **កម្រិតយល់ដឹង**<br>បង្កើតន័យតាមរយៈ ការបង្រៀនរួម ជាមួយលំហាត់ ផ្ទាល់មាត់ ការសរសេរ និងទំនាក់ទំនងក្រាហ្វិក | បង្ហាញ<br>ការពារ<br>ប្រៀបធៀប<br>ប៉ាន់ប្រមាណ<br>ពន្យល់<br>ធ្វើចំណាត់ថ្នាក់<br>សន្និដ្ឋាន<br>បកស្រាយ<br><br>ពន្យល់ន័យដើម<br>ព្យាករឬទាយ<br>ការសរសេរឡើង វិញ<br>សង្ខេប<br>បកប្រែ | ការឧទ្ទេស<br>ការបង្រៀនដោយ មានឧទាហរណ៍ បញ្ជាក់<br>ការសម្តែងតួឬ ការដើរតួ<br>ល្បែង<br>ការពិភាក្សា<br>ការបំផុសគំនិត,<br>ពង្រាងគំនិត<br>ការបង្កើតគំនិត<br>ដៅគំនិត ពង្រាយ មែកធាងគំនិត គំរូ, ម៉ូដែល | សំណួរពហុជ្រើសរើស<br>សំណួរចម្លើយខ្លីៗ<br>ការធ្វើបទបង្ហាញ<br>តេស្តការសម្តែង<br>តែងសេចក្តី<br><br>ការពន្យល់ន័យដើម<br>ការរៀបចំប័ណ្ណឬបដា |
| **កម្រិតអនុវត្តន៍**<br>អនុវត្ត ឬប្រើសេចក្តីណែនាំទៅតាមកាលៈទេសៈឬស្ថានភាពជាក់ស្តែងណាមួយ | អនុវត្ត<br><br>រៀបចំ ចាត់ចែង<br><br>សម្តែង ធ្វើវិនាដកម្ម<br>ដោះស្រាយបញ្ហា<br>បង្កើត<br>បង្ហាញ ឬសម្តែង<br>ស្វែងរក<br>កនាំ<br>កែសម្រួល | ការបង្ហាញ<br>ដំណោះស្រាយ បញ្ហា<br>ទស្សនកិច្ចសិក្សា<br><br>ការពិសោធន៍<br>ការបង្ហាញនិង អធិប្បាយ<br>ការផ្គុំនិងផ្គូរផ្គង<br>ការដើរតួរ ឬការស ម្តែងតួ | តម្រៀបឡើងវិញ<br>ផ្គុំនិងផ្គូរផ្គង<br>ផ្គូរផ្គង<br>គម្រោង<br>បទបង្ហាញ<br>បដាបង្ហាញ<br>កម្មសិក្សា/ការងារទីវាល<br>កិច្ចការអនុវត្តន៍<br>សិក្សាអង្គហេតុ |

| Revised Bloom's Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| **កម្រិត** | **កិរិយាស័ព្ទសកម្ម** | **វិធីសាស្រ្តបង្រៀន** | **វិធីសាស្រ្តវាយតម្លៃ** |
| | ប្រតិបត្តិ<br>ព្យាករឬទាយ<br>រៀបចំ ត្រៀម បម្រុង<br>ផលិត/បង្កើត<br>ភ្ជាប់ទំនាក់ទំនង/ និទាន<br>បង្ហាញ ដាក់តាំង<br>ជ្រើសរើស | ការសិក្សាអង្គហេតុ<br>ការរៀបគម្រោង<br>កិច្ចការអនុវត្តន៍ | |
| **កម្រិតវិភាគ**<br>បែងចែកចំណេះដឹងទៅតាមផ្នែកគោល និងកំណត់ទំនាក់ទំនងរចនាសម្ព័ន្ធ ឬគោលបំណងជារួម | វិភាគ<br>វាយលម្អិត ឬវិភាគលម្អិត<br>ប្រៀបធៀប<br>ជ្រើសរើស<br>បដិមតិ<br>បំបែក<br>ចំណាត់ថ្នាក់ | សិក្សាអង្គហេតុ<br>គម្រោងស្រាវជ្រាវជាក្រុម<br>កិច្ចការអនុវត្តន៍<br>ការពិសោធន៍<br>ការងារទីវាល<br>ការសិក្សាដោយផ្អែកលើបញ្ហា<br>ការពិភាក្សាដេញដោល<br>Researchការសិក្សាស្រាវជ្រាវ<br>Concept formation<br>ការបង្កើតទស្សនៈ | តែងសេចក្តី<br>ប័ណ្ណប្រកាសឬបដាបង្ហាញ<br>សំណេររបាយការណ៍<br>បទបង្ហាញ<br>កម្រងឯកសារ<br>គម្រោងស្រាវជ្រាវ<br>តេស្តអនុវត្តសម្តែង<br>ការសិក្សាស្រាវជ្រាវ<br>សិក្សាអង្គហេតុ<br>ការរិះគន់<br>ការវិភាគលើភាពខ្លាំងខ្សោយ កាលានុវត្តភាព និងហានិភ័យ (SWOT) |

| Revised Bloom’s Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| កម្រិត | កិរិយាស័ព្ទសកម្ម | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
| **កម្រិតវាយតម្លៃ**<br>ធ្វើការវាយតម្លៃដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យនិងនិយាមបទដ្ឋាន | ចាត់ថ្នាក់<br>វាយតម្លៃ<br>ពិនិត្យតាមដាន<br>ត្រួតពិនិត្យ<br>តេស្ត<br>វិនិច្ឆ័យ | វិធីសាស្ត្រស្រាវជ្រាវតាមបែបសាកសួរ ឬរុករកវិភាគបញ្ហា<br>ការពិភាក្សាដេញដោល<br>ការធ្វើពិសោធន៍<br>គម្រោងស្រាវជ្រាវ<br>កម្មសិក្សា<br>បង្រៀនដៃគូ<br>ការវិភាគលើភាពខ្លាំង ខ្សោយ កាលានុវត្តភាព និងហានិភ័យ (SWOT) | ការបង្ហាញស្រាវជ្រាវ និងសំណេររបាយការណ៍<br>តេស្តសំណេរ<br>ការពិភាក្សាដេញដោលកាត់ក្តីសាកល្បងឬសវនាការប្រឌិត<br>តែងសេចក្តី<br>លទ្ធផលពិសោធន៍<br>គម្រោងស្រាវជ្រាវ<br>តេស្តលើសមត្ថភាពការងារ |
| **កម្រិតបង្កើតនិងច្នៃ**<br>ដាក់បញ្ចូលសមាសភាពរួមគ្នាដើម្បីបង្កើតបណ្តាញឬតួនាទីទាំងមូល ឬ រៀបចំសមាសភាពឡើងវិញឲ្យទៅជាគំរូ ឬរចនាសម្ព័ន្ធថ្មី ។ | បង្កើត<br>ធ្វើផែនការ<br>និពន្ធ<br>អភិវឌ្ឍ<br>ច្នៃនិងបង្កើតថ្មី<br>ច្នៃប្រឌិត<br>រៀបចំ<br>ស្ថាបនា<br>ផលិត<br>ចងក្រង | -ដំណោះស្រាយបញ្ហា<br>សិក្សាអង្គហេតុ<br>គម្រោងស្រាវជ្រាវ<br>កម្មសិក្សាជាក់ស្តែង<br>ការសិក្សាតាមពិសោធន៍<br>ទស្សនកិច្ចសិក្សា<br>- បង្កើតគំរូ | ធ្វើបទបង្ហាញ<br>តែងសេចក្តី<br>ព្រឹត្តិប័ត្រ<br>ការសរសេរ របាយការណ៍ស្រាវជ្រាវ<br>បឋមរូប ឬការបង្កើតគំរូ<br>ការសម្តែង<br>ការតែងនិពន្ធ (រឿង ចម្រៀង កំណាព្យ...) |

| Revised Bloom’s Taxonomy and Constructive Alignment with Instructional Methods and Assessment Methods | | | |
|---|---|---|---|
| កម្រិត | កិរិយាស័ព្ទសកម្ម | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
| | ធ្វើគម្រោង, គូរគម្រោង<br>បង្កើតគំនិតថ្មី | | ការសិក្សាស្រាវជ្រាវ<br>គម្រោងស្រាវជ្រាវ |

*១. លក្ខណវិនិច្ឆ័យ៦៖ គុណភាពបុគ្គលិកសិក្សា*

*១. ការរៀបចំផែនការទាំងរយៈពេលខ្លី និងរយៈពេលវែងនៃការបង្កើតបុគ្គលិកសិក្សា និង តម្រូវការ (រួមបញ្ចូលទាំងគម្រោងនៃការស្វែងតំណែង ការដំឡើងឋានៈ ការប្រគល់ការងារធ្វើជាថ្មី ការបញ្ចប់ការងារ និងការចូលនិវត្តន៍) ត្រូវបានអនុវត្តដើម្បីធ្វើឲ្យប្រាកដថាគុណភាព និងបរិមាណនៃ បុគ្គលិកសិក្សាបំពេញតម្រូវការសម្រាប់ការអប់រំ ការស្រាវជ្រាវ និងសេវា។*

*២. អត្រាបុគ្គលិកធៀបនឹងនិស្សិត និងទំហំការងារត្រូវបានវាស់វែង និងពិនិត្យតាមដានដើម្បីធ្វើឲ្យប្រសើរឡើងគុណភាពនៃការអប់រំ ការស្រាវជ្រាវ និងសេវា។*

*៣. សមត្ថភាពរបស់បុគ្គលិកសិក្សាត្រូវបានបញ្ជាក់ និងវាយតម្លៃ។ បុគ្គលិកសិក្សាដែលមានសមត្ថភាពនឹងអាច៖*

- *បង្កើត និងចែករំលែកកម្មវិធី បង្រៀន និងរៀនតាមលំដាប់លំដោយ*
- *អនុវត្តនូវវិធីបង្រៀន និងរៀនបានច្រើនបែប និងជ្រើសរើសវិធីវាយតម្លៃសមស្របបំផុតដើម្បីសម្រេចបាននូវលទ្ធផលសិក្សារំពឹងទុក*
- *អភិវឌ្ឍ និងប្រើប្រាស់មធ្យោបាយបង្រៀនផ្សេងៗ*
- *ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តការបង្រៀនរបស់ខ្លួន និងវាយតម្លៃមុខវិជ្ជាដែលពួកគេបានបង្រៀន*
- *ឆ្លុះបញ្ចាំងទៅលើការអនុវត្តការបង្រៀន របស់ខ្លួន និង*
- *ស្រាវជ្រាវ និងផ្តល់សេវាដើម្បីផ្តល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធ*

*៤. ការជ្រើសរើស និងការដំឡើងឋានៈនៃបុគ្គលិកសិក្សាត្រូវផ្អែកតាមប្រព័ន្ធគុណសម្បត្តិដែលរួមបញ្ចូល ការបង្រៀន ការស្រាវជ្រាវ និងសេវា។*

*៥. តួនាទី និងទំនាក់ទំនងបុគ្គលិកសិក្សាត្រូវបានកំណត់ និងយល់ដឹងយ៉ាងច្បាស់លាស់។*

*៦. ភារកិច្ចត្រូវបានបែងចែកទៅឲ្យបុគ្គលិកសិក្សាសមស្របទៅនឹងលក្ខណសម្បត្តិ បទពិសោធន៍ និងឥរិយាបថ។*

*៧. គ្រប់បុគ្គលិកសិក្សាទាំងអស់ត្រូវមាន គណនេយ្យភាពចំពោះសាកលវិទ្យាល័យ និងភាគីពាក់ព័ន្ធដោយពិចារណាលើសេរីភាពសិក្សា និង ក្រមសីលធម៌វិជ្ជាជីវៈ។*

*៨. តម្រូវការនៃការបណ្តុះបណ្តាល និងការអភិវឌ្ឍសម្រាប់បុគ្គលិកសិក្សាត្រូវបានកំណត់ជាលក្ខណៈប្រព័ន្ធ ហើយសកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍសមស្របត្រូវបានអនុវត្តដើម្បីបំពេញនូវតម្រូវការដែលបានកំណត់។*

*៩. ការគ្រប់គ្រងការអនុវត្តដែលរួមបញ្ចូលការផ្តល់រង្វាន់ និងការទទួលស្គាល់ ត្រូវបានអនុវត្តដើម្បីជំរុញ និងគាំទ្រការអប់រំ ការស្រាវជ្រាវ និងសេវា។*

*១០. ប្រភេទ និងបរិមាណនៃសកម្មភាពស្រាវជ្រាវដោយបុគ្គលិកសិក្សាត្រូវបានបង្កើត ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ដោយមានការប្រៀបធៀបជាមួយរបស់អ្នកដទៃ សម្រាប់ការធ្វើឲ្យប្រសើរឡើង។*

២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៦

| No. | គុណភាពនៃបុគ្គលិកសិក្សា | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 6.1 | ការរៀបចំផែនការបុគ្គលិកសិក្សា (ពិចារណាទៅលើការស្នងតំណែង ការដំឡើងឋានៈ ការប្រគល់ការងារឲ្យធ្វើជាថ្មី ការបញ្ចប់ការងារ និងការចូលនិវត្ត) ត្រូវបានអនុវត្តដើម្បីបំពេញតម្រូវការសម្រាប់ការអប់រំ ការស្រាវជ្រាវ និងសេវា [1] | | | | | | | |
| 6.2 | អត្រាបុគ្គលិកនិងនិស្សិត និងទំហំការងារត្រូវបានវាស់ និង ពិនិត្យតាមដាន ដើម្បីធ្វើឲ្យប្រសើរឡើងគុណភាពនៃការអប់រំ ការស្រាវ ជ្រាវ និងសេវា [2] | | | | | | | |
| 6.3 | លក្ខណវិនិច្ឆ័យជ្រើសរើសរួមបញ្ចូលក្រមសីលធម៌ និងសេរីភាពនៃការសិក្សាសម្រាប់ការតែងតាំង ការបង្គាប់ការ និង ការដំឡើងឋានៈត្រូវបានកំណត់ និងធ្វើឲ្យមានទំនាក់ទំនង [4, 5, 6, 7] | | | | | | | |
| 6.4 | សមត្ថភាពបុគ្គលិកសិក្សាត្រូវបានបញ្ជាក់ និងវាយតម្លៃ [3] | | | | | | | |
| 6.5 | តម្រូវការនៃការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិកសិក្សា ត្រូវបានបញ្ជាក់ ហើយសកម្មភាពទាំងឡាយត្រូវបានអនុវត្តដើម្បីបំពេញតម្រូវការទាំងអស់នោះ | | | | | | | |
| 6.6 | ការគ្រប់គ្រងការអនុវត្ត ដែលរួមបញ្ចូលការផ្តល់រង្វាន់ និងការទទួលស្គាល់ត្រូវបាន អនុវត្តដើម្បីលើកជំរុញ និងគាំទ្រការអប់រំ ការស្រាវជ្រាវ និងសេវា [9] | | | | | | | |
| 6.7 | ប្រភេទ និងបរិមាណនៃសកម្មភាពស្រាវជ្រាវដោយបុគ្គលិកសិក្សាត្រូវបានបង្កើតឡើង ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ដោយយកករណីរបស់គេពិនិត្យ សម្រាប់ធ្វើឲ្យប្រសើរឡើង [10] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

បុគ្គលិកសិក្សាជាប្រភពនៃការសិក្សាដ៏សំខាន់បំផុតតែមួយសម្រាប់និស្សិតភាគច្រើនបំផុត។ ជាការសំខាន់ដែលថាបុគ្គលិកសិក្សាដែលបង្រៀនមានចំណេះ និងការយល់ដឹងពេញលេញអំពីមុខវិជ្ជាដែលពួកគេកំពុងបង្រៀន មានជំនាញ និងបទពិសោធន៍ចាំបាច់ដើម្បីធ្វើឲ្យមានទំនាក់ទំនងយ៉ាងមាន

ប្រសិទ្ធភាព ពីចំណេះ និងការយល់ដឹងរបស់ពួកគេទៅកាន់និស្សិត នៅក្នុងបរិបទបង្រៀនច្រើនបែប ហើយអាចទទួលបានយោបល់ត្រឡប់អំពីការងារបង្រៀនរបស់ពួកគេ។

គុណភាពនៃស្ថាប័នមិនគ្រាន់តែពឹងផ្អែកលើគុណភាពនៃកម្មវិធីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគុណភាពនៃបុគ្គលិកសិក្សាទៀតផង។ គុណភាពនៃបុគ្គលិកសិក្សារួមមានគុណវុឌ្ឍិ ជំនាញនៃមុខវិជ្ជា បទពិសោធន៍ ជំនាញបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈ។ បុគ្គលិកសិក្សារួមបញ្ចូលសាស្ត្រាចារ្យ គ្រូបង្រៀនទាំងពេញម៉ោង និងក្រៅម៉ោង និងបុគ្គលិកបង្រៀនដែលត្រូវបានអញ្ជើញ។ ក្រៅពីគុណភាពនៃបុគ្គលិកសិក្សា ស្ថាប័នត្រូវតែកំណត់បរិមាណរបស់បុគ្គលិកសិក្សាដែលត្រូវការដើម្បីបំពេញតម្រូវការរបស់និស្សិត និង ស្ថាប័ន។ ជារឿយៗ សមមូលពេញម៉ោង និងអត្រាធៀបរវាងបុគ្គលិកនិងនិស្សិតត្រូវបានប្រើប្រាស់ ដើម្បីកំណត់ទំហំនៃបុគ្គលិកសិក្សា។

### *៤.សមមូលពេញម៉ោង (សពម)*

ក្នុងការគណនា សពម របស់បុគ្គលិកសិក្សា ស្ថាប័នគួរកំណត់អំពីអ្វីដែលបង្កើតបានជាទំហំការងាររបស់និស្សិតពេញម៉ោង និងទំហំការងាររបស់បុគ្គលិកបង្រៀនដែលរួមបញ្ចូលនិស្សិតក្រៅម៉ោង និង បុគ្គលិកបង្រៀនក្រៅម៉ោង ធៀបនឹងទំហំការងារពេញម៉ោង។

មានរបៀបផ្សេងៗគ្នាការគណនា សពម ហើយស្ថាប័នគួរបញ្ជាក់អំពីវិធី ប៉ារ៉ាម៉ែត្រ និងការសន្មតដែលត្រូវបានប្រើប្រាស់។ វិធីមួយដើម្បីគណនា សពម គឺផ្អែកទៅលើការវិនិយោគនៃពេលវេលា។ ឧទាហរណ៍ ប្រសិនបើ ១ សពម ស្មើ៤០ម៉ោងក្នុងមួយសប្តាហ៍ (ការងារពេញម៉ោង) នោះ សពម របស់បុគ្គលិកបង្រៀនដែលត្រូវជា៨ម៉ោងក្នុងមួយសប្តាហ៍គឺស្មើ០,២ (៨/៤០)។ វិធីគណនានៃការ វិនិយោគពេលវេលាក៏អាចត្រូវបានប្រើផងដែរសម្រាប់ការគណនា សពម របស់និស្សិត។ ឧទាហរណ៍ ប្រសិនបើនិស្សិតពេញម៉ោងម្នាក់ត្រូវរៀនចំនួន២០ម៉ោងក្នុងមួយសប្តាហ៍ នោះ សពម របស់និស្សិត ក្រៅម៉ោងដែលត្រូវជា១០ម៉ោង ក្នុងមួយសប្តាហ៍គឺស្មើ០,៥ (១០/២០)។

វិធីមួយទៀតនៃការគណនា សពម គឺផ្អែកទៅលើទំហំការងារបង្រៀន។ ឧទាហរណ៍ ប្រសិនបើទំហំការងារបង្រៀនរបស់បុគ្គលិក សិក្សាស្មើនឹង៤ថ្នាក់ក្នុងមួយឆមាស នោះថ្នាក់នីមួយៗមាន សពម ចំនួន ០,២៥។ ប្រសិនបើបុគ្គលិក បង្រៀនត្រូវបានផ្តល់ជូន២ថ្នាក់ក្នុងមួយឆមាស នោះ សពម ស្មើ០,៥ (២ x ០,២៥)។ ដូចគ្នានេះដែរ ទំហំការងារសិក្សារបស់និស្សិតអាចត្រូវបានប្រើដើម្បីគណនា សពម របស់និស្សិត។ ឧទាហរណ៍ និស្សិត សពម ម្នាក់ត្រូវរៀន២៤ក្រេឌីតក្នុងមួយឆមាស នោះ សពម របស់និស្សិតដែលមាន១៨ក្រេឌីត ក្នុងមួយឆមាសគឺស្មើ០,៧៥ (១៨/២៤)។ ប្រើតារាង១ ដើម្បីបញ្ជាក់ពីចំនួនបុគ្គលិកសិក្សា និង សពម ម៉ោងរបស់ពួកគេ យ៉ាងហោចណាស់រយៈពេល៥ឆ្នាំសិក្សា។

**តារាង១៖ ចំនួនបុគ្គលិកបង្រៀន (បញ្ជាក់ពីកាលបរិច្ឆេទ និងវិធីគណនាដែលប្រើសម្រាប់ សមមូលពេញម៉ោងរបស់បុគ្គលិកសិក្សា)**

| ប្រភេទ | ប្រុស | ស្រី | សរុប | សរុប | | %នៃបណ្ឌិត |
|---|---|---|---|---|---|---|
| | | | | នាក់ | សពម* | |
| 1. សាស្ត្រាចារ្យ | | | | | | |
| 2. សាស្ត្រាចារ្យរង/ជំនួយ | | | | | | |
| 3. គ្រូបង្រៀនពេញម៉ោង | | | | | | |
| 4. គ្រូបង្រៀនក្រៅម៉ោង(វេលាការ) | | | | | | |
| 5. សាស្ត្រាចារ្យ/គ្រូបង្រៀនដែលត្រូវបានអញ្ជើញឲ្យបង្រៀនរយៈពេលខ្លី | | | | | | |
| សរុប | | | | | | |

*សពម តាងឲ្យ សមមូលពេញម៉ោង។ វាជាឯកតាដើម្បីគណនាការវិនិយោគនៃពេលវេលា។

### ៥.អត្រាបុគ្គលិក/និស្សិត និងអត្រាបុគ្គលិក/និស្សិតបញ្ចប់ការសិក្សា

សូចនាករនេះគឺជាអត្រាបុគ្គលិកសិក្សា ស.ព.ម. ដែលត្រូវបានប្រើប្រាស់ឆ្លើយតបទៅនឹងចំនួននិស្សិតពេញម៉ោងដែលបានចុះឈ្មោះចូលរៀន។ គោលបំណងគឺដើម្បីផ្តល់នូវគំនិតមួយនៃពេលវេលាទំនាក់ទំនងនិងការគាំទ្រដោយបុគ្គលិកសិក្សាដែលនិស្សិតនៅស្ថាប័នមួយអាចរំពឹងថានឹងបានទទួល។ បញ្ជាក់អត្រាធៀបរវាងបុគ្គលិកនិងនិស្សិតនៅក្នុងតារាងទី២យ៉ាងតិច៥ឆ្នាំសិក្សា។

**តារាង២៖ អត្រាបុគ្គលិក/និស្សិត និងអត្រាបុគ្គលិក/និស្សិតបញ្ចប់ការសិក្សា (សូមបញ្ជាក់ឆ្នាំ)**

| ឆ្នាំសិក្សា | ចំនួន សពម សរុប របស់បុគ្គលិកសិក្សា | ចំនួន សពម សរុប របស់និស្សិត | អត្រាធៀបបុគ្គលិក និង និស្សិត |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### សកម្មភាពស្រាវជ្រាវ

ការស្រាវជ្រាវគឺជាធាតុចេញដ៏សំខាន់មួយពីបុគ្គលិកសិក្សា។ ប្រភេទនៃសកម្មភាពស្រាវជ្រាវ (ដូចជាការបោះពុម្ពផ្សាយ ការងារពិគ្រោះយោបល់ គម្រោង ការផ្តល់មូលនិធិ។ល។) ដែលត្រូវបានអនុវត្ត

ដោយបុគ្គលិកសិក្សាគួរបំពេញតម្រូវការរបស់ភាគីពាក់ព័ន្ធ។ ផ្តល់ទិន្នន័យអំពីប្រភេទ និងចំនួននៃការបោះពុម្ពផ្សាយ ក្នុងរយៈពេលយ៉ាងតិច៥ឆ្នាំ នៅក្នុងតារាង៣។

**តារាង៣៖ ប្រភេទ និងចំនួននៃការបោះពុម្ពផ្សាយ (សូមបញ្ជាក់ឆ្នាំ)**

| ឆ្នាំសិក្សា | ប្រភេទនៃការបោះពុម្ពផ្សាយ | | | | | ចំនួននៃការបោះពុម្ពផ្សាយដោយបុគ្គលិកសិក្សា |
|---|---|---|---|---|---|---|
| | ផ្ទៃក្នុង | ថ្នាក់ជាតិ | ថ្នាក់អន្តរជាតិ | ថ្នាក់អន្តរជាតិ | សរុប | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**សំណួរវិនិច្ឆ័យ**

*បុគ្គលិកសិក្សា*

- តើបុគ្គលិកសិក្សាមាន សមត្ថភាព និងមានគុណវុឌ្ឍិសម្រាប់ការងាររបស់ពួកគេឬទេ?
- តើសមត្ថភាព និងជំនាញរបស់បុគ្គលិកសិក្សាគ្រប់គ្រាន់សម្រាប់ផ្តល់បើកកម្មវិធីដែរឬទេ?
- តើអ្វីជាបញ្ហាប្រឈមដែលស្ថាប័នជួបប្រទះពាក់ព័ន្ធនឹងធនធាន មនុស្ស ដូចជាការបែងចែកអាយុ ការលំបាកនៅក្នុងបំពេញកន្លែងទំនេរ ឬនៅក្នុងទាក់ទាញបុគ្គលិក សិក្សាដែលមានគុណវុឌ្ឍិ? តើស្ថាប័នដោះស្រាយបញ្ហាប្រឈមទាំងនេះយ៉ាងដូចម្តេច?
- តើបុគ្គលិក សិក្សាប៉ុន្មាននាក់ដែលមានបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតក្នុងចំណោមបុគ្គលិកសិក្សាទាំងអស់?
- តើគោលនយោបាយអ្វីដែលត្រូវបានបន្តប្រើទាក់ទងនឹងការប្រើប្រាស់បុគ្គលិកសិក្សា ទាំងក្នុងការបង្រៀន និងក្នុងការស្រាវជ្រាវ?
- តើកិច្ចខំប្រឹងប្រែងដ៏មានមនសិការត្រូវបានបង្កើតឡើងពាក់ព័ន្ធនឹងសាស្ត្រាចារ្យ នៅ ក្នុងការណែនាំ និង/ឬបណ្តុះបណ្តាលបុគ្គលិកសិក្សាថ្មីឬក្មេងៗដែលឬទេ?
- តើគោលនយោបាយត្រូវបានប្រើពាក់ព័ន្ធនឹងការចូលរួមនៅក្នុង សិក្ខាសាលា ការណែនាំសារណា ការងារអនុវត្ត ឬការចុះកម្មសិក្សាដែរឬទេ?
- តើបុគ្គលិកសិក្សាពេញចិត្តនឹង ទំហំការងារបង្រៀនដែរឬទេ?
- តើអត្រាធៀបរវាងបុគ្គលិកនិងនិស្សិតពេញចិត្តដែរឬទេ?
- តើអ្វីជាគណនេយ្យភាពរបស់បុគ្គលិកសិក្សាទាក់ទងនឹងតួនាទី ការទទួលខុសត្រូវ សេរីភាពសិក្សា និងក្រមសីលធម៌វិជ្ជាជីវៈ?

- តើប្រភេទនៃសកម្មភាពស្រាវជ្រាវអ្វីដែលត្រូវបានអនុវត្តដោយបុគ្គលិកសិក្សា? តើសកម្មភាពទាំងនេះស្របនឹងចក្ខុវិស័យ និងបេសកកម្មរបស់ សាកលវិទ្យាល័យ និងមហាវិទ្យាល័យដែរឬទេ?
- តើអ្វីជាកម្រិតនៃមូលធិនិស្រាវជ្រាវ ហើយវាត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច?
- តើអត្ថបទស្រាវជ្រាវដែលបានបោះពុម្ពបានចំនួន ប៉ុន្មាន? តើអត្ថបទស្រាវជ្រាវត្រូវបានបោះពុម្ពនៅក្នុងជើនណលថ្នាក់ជាតិ តំបន់ និងអន្តរជាតិដែរឬទេ?

*ការគ្រប់គ្រងបុគ្គលិក*

- តើការរៀបចំផែនការផ្គត់ផ្គង់កម្លាំង ពលកម្មរបស់បុគ្គលិកសិក្សាត្រូវបានអនុវត្តយ៉ាងដូចម្តេច?
- តើដេប៉ាតឺម៉ង់ត្រូវ បានបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងបុគ្គលិកច្បាស់លាស់ដែរឬទេ?
- តើលក្ខណវិនិច្ឆ័យជ្រើសរើស និងដំឡើងឋានៈរបស់បុគ្គលិកសិក្សាត្រូវបានបង្កើតឡើងដែរឬទេ?
- តើមានប្រព័ន្ធគ្រប់គ្រងការអនុវត្តដែរឬទេ?
- តើផែនការស្នងតំណែងអ្វីសម្រាប់អ្នក តែងតាំង?
- ផែនការអភិវឌ្ឍអាជីពអ្វីសម្រាប់ បុគ្គលិកសិក្សា?
- តើបុគ្គលិកសិក្សាត្រូវបានបំពេញចិត្ត ជាមួយនឹងគោលនយោបាយធនធានមនុស្សដែរឬទេ?
- តើអ្វីជាការអភិវឌ្ឍអនាគតនៃ គោលនយោបាយសម្រាប់បុគ្គលិកសិក្សា?
- តើបុគ្គលិកសិក្សាត្រូវបាន រៀបចំយ៉ាងដូចម្តេចសម្រាប់ការងារបង្រៀន?
- តើការបង្រៀនត្រូវបាន ផ្តល់ដោយបុគ្គលិកសិក្សាដែលត្រូវបានណែនាំ និងវាយតម្លៃឬទេ?

*ការបណ្តុះបណ្តាល និងការអភិវឌ្ឍ*

- អ្នកណា ទទួលខុសត្រូវសម្រាប់សកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍ?
- តើអ្វីជាដំណើរការបណ្តុះបណ្តាលនិងអភិវឌ្ឍ និងគម្រោង?តើតម្រូវការនៃការបណ្តុះបណ្តាលត្រូវ បានបញ្ជាក់យ៉ាងដូចម្តេច?
- តើគម្រោងបណ្តុះបណ្តាល និងអភិវឌ្ឍឆ្លុះបញ្ចាំងអំពីបេសកកម្មរបស់សាកលវិទ្យាល័យ និងមហាវិទ្យាល័យដែរឬទេ?
- តើមាន ប្រព័ន្ធដើម្បីអភិវឌ្ឍសមត្ថភាពបច្ចេកទេស និងយុទ្ធសាស្ត្ររបស់បុគ្គលិកសិក្សាឬទេ?
- តើចំនួន ម៉ោងបណ្តុះបណ្តាល និងចំនួនកន្លែងបណ្តុះបណ្តាលមានប៉ុន្មានសម្រាប់បុគ្គលិកសិក្សាក្នុង១ឆ្នាំ?
- តើភាគរយនៃ ប្រាក់ខែ ឬថវិកាត្រូវបានបែងចែកសម្រាប់ការបណ្តុះបណ្តាលរបស់បុគ្គលិកសិក្សាដែរឬទេ?

**ប្រភពនៃភស្តុតាង/ឯកសារចាំបាច់**

- ផែនការផ្គត់ផ្គង់កម្លាំងពលកម្ម
- ការបែងចែកសាស្ត្រាចារ្យពាក់ព័ន្ធនឹងអាយុ ភេទ ជំនាញ។ល។
- ផែនការអាជីព និងផែនការស្នងតំណែង
- លក្ខខណ្ឌជ្រើសរើស
- គុណវុឌ្ឍិបុគ្គលិក
- ការវិភាគតម្រូវការបណ្តុះបណ្តាល
- ផែនការ និងថវិកាបណ្តុះបណ្តាល និងអភិវឌ្ឍ
- ប្រព័ន្ធត្រួតពិនិត្យឡើងវិញដោយដៃគូ និងប្រព័ន្ធវាយតម្លៃ
- យោបល់ត្រឡប់ពីនិស្សិត
- គម្រោងផ្តល់រង្វាន់ និងការទទួលស្គាល់
- ទំហំការងារបុគ្គលិក
- អង្គការលេខ
- គោលនយោបាយធនធានមនុស្ស
- សៀវភៅបុគ្គលិក
- ការពិពណ៌នាអំពីតួនាទី
- កិច្ចសន្យាការងារ
- ទិន្នន័យស្រាវជ្រាវ និងបោះពុម្ពផ្សាយ
- វិញ្ញាបនបត្រ/អាជ្ញាប័ណ្ណជាតិ និង/ឬវិជ្ជាជីវៈ

*១. លក្ខណវិនិច្ឆ័យ៧៖ គុណភាពបុគ្គលិកគាំទ្រ*

*១. ផែនការកម្មទាំងរយៈពេលខ្លី និងវែងនៃការបង្កើតបុគ្គលិកគាំទ្រ ឬតម្រូវការនៃបណ្ណាល័យ បន្ទប់ពិសោធ សម្ភារៈបរិក្ខាបច្ចេកវិទ្យា ព័ត៌មានវិទ្យា និងសេវានិស្សិតត្រូវបានអនុវត្តដើម្បីធ្វើឲ្យប្រាកដថា គុណភាព និងបរិមាណរបស់បុគ្គលិក បំពេញតម្រូវការសម្រាប់ការអប់រំ ការស្រាវជ្រាវ និងសេវា។*

*២. លក្ខខណ្ឌជ្រើសរើសសម្រាប់ការតែង តាំង ការបង្គាប់ការ និងការដំឡើងឋានៈរបស់បុគ្គលិកគាំទ្រត្រូវបានកំណត់ច្បាស់លាស់ ហើយភារកិច្ច ត្រូវបានបែងចែកដោយផ្អែកលើគុណសម្បត្តិ គុណវុឌ្ឍិ និងបទពិសោធន៍។*

*៣. សមត្ថភាពរបស់បុគ្គលិកគាំទ្រត្រូវបានកំណត់ និងវាយតម្លៃដើម្បីធ្វើឲ្យប្រាកដថា សមត្ថភាពនោះនៅពាក់ព័ន្ធ ហើយសេវាដែលត្រូវបានផ្តល់ឲ្យដោយពួកគេ ធ្វើឲ្យពេញចិត្តនូវសេចក្តីត្រូវការរបស់ភាគីពាក់ព័ន្ធ។*

*៤. សេចក្តីត្រូវការនៃការបណ្តុះបណ្តាល និងអភិវឌ្ឍសម្រាប់បុគ្គលិកគាំទ្រត្រូវបានកំណត់ជាប្រព័ន្ធ ហើយ សកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍត្រូវបានអនុវត្តដើម្បីបំពេញនូវសេចក្តីត្រូវការដែលបានកំណត់។*

*៥. ការគ្រប់គ្រងការអនុវត្តដែលរួមបញ្ចូលការផ្តល់រង្វាន់ និង ការទទួលស្គាល់ត្រូវបានអនុវត្តដើម្បីជំរុញ និងគាំទ្រការអប់រំ ការស្រាវជ្រាវ និងសេវា។*

**ការពន្យល់**

គុណភាពនៃកម្មវិធីអាស្រ័យយ៉ាងខ្លាំងលើអន្តរកម្មរវាងបុគ្គលិក និងនិស្សិត។ ប៉ុន្តែ បុគ្គលិកសិក្សាមិនអាចបំពេញតួនាទីបានល្អដោយគ្មានគុណភាពនៃសេវាដែលផ្តល់ឲ្យដោយបុគ្គលិកគាំទ្រ។ ទាំងនេះជាបុគ្គលិកគាំទ្រដែលគ្រប់គ្រងបណ្ណាល័យ បន្ទប់ពិសោធ សម្ភារៈបរិក្ខាកុំព្យូទ័រ និងសេវានិស្សិត។

| បុគ្គលិកគាំទ្រ | សញ្ញាបត្រខ្ពស់បំផុតដែលទទួលបាន | | | | |
|---|---|---|---|---|---|
| | វិទ្យាល័យ | បរិញ្ញាបត្ររង | បរិញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | បណ្ឌិត |
| 1. បុគ្គលិកបណ្ណាល័យ | | | | | |
| 2. បុគ្គលិកបន្ទប់ពិសោធ | | | | | |
| 3. បុគ្គលិកបច្ចេកវិទ្យាព័ត៌មាន | | | | | |
| 4. បុគ្គលិករដ្ឋបាល | | | | | |
| 5. បុគ្គលិកសេវានិស្សិត | | | | | |
| | | | | | |
| | | | | | |

២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៧

| No. | គុណភាពបុគ្គលិកគាំទ្រ | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 7.1 | បង្កើតផែនការសម្រាប់បុគ្គលិកគាំទ្រ(នៅតាមបណ្ណាល័យ បន្ទប់ពិសោធន៍ សម្ភារៈបរិក្ខាព័ត៌មានវិទ្យានិងសេវានិស្សិត) ដើម្បីបំពេញឲ្យតម្រូវការសម្រាប់ការអប់រំ ការស្រាវជ្រាវនិងសេវានានា[1] | | | | | | | |
| 7.2 | លក្ខខណ្ឌជ្រើសរើសសម្រាប់ការតែងតាំង ការប្រគល់ការងារ និងការតម្លើងឋានៈត្រូវមានការកំណត់និងចរចារ[2] | | | | | | | |
| 7.3 | សមត្ថភាពរបស់បុគ្គលិកគាំទ្រត្រូវបាបញ្ជាក់និងវាយតម្លៃ[3] | | | | | | | |
| 7.4 | តម្រូវការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍របស់បុគ្គលិកគាំទ្រត្រូវបានបញ្ជាក់និងសកម្មភាពនានាត្រូវបានអនុវត្តដើម្បីបំពេញតម្រូវការទាំងនោះ[4] | | | | | | | |
| 7.5 | ស្នាដៃគ្រប់គ្រងរួមមានរង្វាន់និងការទទួលស្គាល់ត្រូវបានអនុវត្តដើម្បីលើកទឹកចិត្តនិងគាំទ្រការអប់រំ ការស្រាវជ្រាវ និងសេវានានា | | | | | | | |
| **យោបល់រួម** | | | | | | | | |

**សំណួរវិនិច្ឆ័យ**

*បុគ្គលិកគាំទ្រ*

- តើបុគ្គលិកគាំទ្រមាន សមត្ថភាព និងមានគុណវុឌ្ឍិសម្រាប់ការងាររបស់ពួកគេដែរឬទេ?
- តើសមត្ថភាព និងជំនាញ របស់បុគ្គលិកគាំទ្រគ្រប់គ្រាន់ដែរឬទេ?
- តើមានឧបសគ្គអ្វីខ្លះក្នុងការ ទាក់ទាញបុគ្គលិកគាំទ្រដែលមានគុណវុឌ្ឍិ?
- តើគោលនយោបាយអ្វី ត្រូវបានបន្តប្រើទាក់ទងនឹងការងាររបស់បុគ្គលិកគាំទ្រ?
- តើបុគ្គលិកគាំទ្រពេញចិត្តនឹងតួនាទីរបស់ ខ្លួនដែរឬទេ?

*ការគ្រប់គ្រងបុគ្គលិក*

- តើផែនការកម្មផ្គត់ផ្គង់កម្លាំងពលកម្ម របស់បុគ្គលិកគាំទ្រត្រូវបានអនុវត្តដែរឬទេ?
- តើលក្ខខណ្ឌជ្រើសរើស និង ដំឡើងឋានៈរបស់បុគ្គលិកគាំទ្រត្រូវបានបង្កើតដែរឬទេ?
- តើមានប្រព័ន្ធគ្រប់គ្រងការអនុវត្តដែរឬទេ?
- តើអ្វីជាផែនការអភិវឌ្ឍអាជីពសម្រាប់ បុគ្គលិកគាំទ្រ?

### *ការបណ្តុះបណ្តាល និងការអភិវឌ្ឍ*

- តើអ្នកណាទទួលខុស ត្រូវសម្រាប់សកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍបុគ្គលិកគាំទ្រ?
- តើអ្វីជាដំណើរការ និងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍ? តើសេចក្តីត្រូវការនៃការបណ្តុះបណ្តាល ត្រូវបានកំណត់ដែរឬទេ?
- តើមានប្រព័ន្ធអភិវឌ្ឍ សមត្ថភាពបច្ចេកទេសរបស់បុគ្គលិកគាំទ្រដែរឬទេ?
- តើចំនួន ម៉ោង និងចំនួនកន្លែងបណ្តុះបណ្តាលសម្រាប់បុគ្គលិកគាំទ្រក្នុងមួយឆ្នាំមានប៉ុន្មាន?
- តើភាគរយនៃ ប្រាក់ខែ និងថវិកាត្រូវបានបែងចែកសម្រាប់ការបណ្តុះបណ្តាលបុគ្គលិកគាំទ្រមានប៉ុន្មាន?

### ប្រភពនៃភស្តុតាង/ឯកសារចាំបាច់

- ផែនការផ្គត់ផ្គង់កម្លាំងពលកម្ម
- ផែនការអាជីព
- លក្ខខណ្ឌជ្រើសរើស
- គុណវុឌ្ឍិរបស់បុគ្គលិក
- ការវិភាគពីសេចក្តីត្រូវការនៃការបណ្តុះបណ្តាល
- ថវិកា និងផែនការអភិវឌ្ឍ និងបណ្តុះបណ្តាល
- ប្រព័ន្ធវាយតម្លៃការអនុវត្ត
- យោបល់ត្រឡប់ពីនិស្សិត
- ទម្រង់ផ្តល់រង្វាន់ និងការទទួលស្គាល់
- អង្គការលេខ
- គោលនយោបាយធនធានមនុស្ស
- សៀវភៅណែនាំបុគ្គលិក
- ការពិពណ៌នាអំពីការងារ
- កិច្ចសន្យាការងារ

### *១. លក្ខណវិនិច្ឆ័យ៨៖ ការគាំទ្រ និងគុណភាពនិស្សិត*

*១. គោលនយោបាយនិស្សិតចូលរៀន និងលក្ខខណ្ឌចុះឈ្មោះចូលរៀនក្នុងកម្មវិធីត្រូវបានកំណត់ច្បាស់ លាស់ ធ្វើឲ្យមានទំនាក់ទំនង បោះពុម្ពផ្សាយ និងទាន់សម័យ។*
*២. វិធី និងលក្ខខណ្ឌជ្រើសរើសនិស្សិតត្រូវបានកំណត់ និងវាយតម្លៃ។*
*៣. មានប្រព័ន្ធពិនិត្យតាមដានគ្រប់គ្រាន់សម្រាប់ការរីកចម្រើន ការអនុវត្តការងារសិក្សា និងទំហំការងាររបស់និស្សិត។ ការរីកចម្រើន ការអនុវត្តការងារសិក្សា និងទំហំការងាររបស់និស្សិត ត្រូវបានកត់ត្រា និងពិនិត្យតាមដានជាប្រព័ន្ធ យោបល់ត្រឡប់ទៅកាន់និស្សិត និងសកម្មភាពត្រូវបានធ្វើឡើងនៅពេលដែលមានករណីចាំបាច់។*
*៤. ដំបូន្មានសិក្សា សកម្មភាពអំពីកម្មវិធីសិក្សារួមគ្នា ការប្រកួតប្រជែងរបស់និស្សិត និងសេវាកម្មគាំទ្រនិស្សិតផ្សេងៗទៀតត្រូវអាចរកបានដើម្បីធ្វើឲ្យប្រសើរឡើងការរៀន និងភាពមានការងារធ្វើ។*
*៥.នៅក្នុងការបង្កើតបរិស្ថានសិក្សាដើម្បីគាំទ្រការសម្រេចបានការរៀនរបស់និស្សិតដែលមានគុណភាពស្ថាប័នគួរផ្តល់បរិស្ថានរូបវន្ត សង្គម និងចិត្តសាស្ត្រដែលអំណោយផលចំពោះការអប់រំ និងការស្រាវជ្រាវ ព្រមទាំងសុខុមាលភាពផ្ទាល់ខ្លួន។*

២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៨

| No. | គុណភាព និងការគាំទ្រនិស្សិត | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 8.1 | គោលនយោបាយជំនាន់និស្សិត និងលក្ខខណ្ឌចូលរៀនត្រូវបានកំណត់ ធ្វើឲ្យមានទំនាក់ទំនង បោះពុម្ពផ្សាយ និងទាន់សម័យ [1] | | | | | | | |
| 8.2 | វិធី និងលក្ខខណ្ឌជ្រើសរើសនិស្សិតត្រូវបានកំណត់ និងវាយតម្លៃ [2] | | | | | | | |
| 8.3 | មានប្រព័ន្ធពិនិត្យតាមដានគ្រប់គ្រាន់សម្រាប់ការរីកចម្រើនរបស់និស្សិត ការអនុវត្តការសិក្សា និងទំហំការងារ [3] | | | | | | | |
| 8.4 | ដំបូន្មានសិក្សា សកម្មភាពកម្មវិធីសិក្សារួមគ្នា ការប្រកួតប្រជែងនិស្សិត និងសេវាគាំទ្រនិស្សិតផ្សេងទៀត អាចមានដើម្បីធ្វើឲ្យប្រសើរឡើងការរៀន និងភាពមានការងារធ្វើ [4] | | | | | | | |
| 8.5 | បរិស្ថានរូបវន្ត សង្គម និងចិត្តសាស្ត្រគឺអំណោយផលចំពោះការអប់រំ និងការស្រាវជ្រាវ ព្រមទាំងសុខុមាលភាពផ្ទាល់ខ្លួន [5] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

គុណភាពនៃធាតុចេញអាស្រ័យយ៉ាងច្រើនទៅលើគុណភាពនៃធាតុចូល។ នេះមានន័យថា គុណភាពនៃនិស្សិតចូលរៀនមានសារៈសំខាន់។

### ៣.ជំនាន់និស្សិត៖

- ចូរសង្ខេបចំនួនសរុបនៃនិស្សិតទាំងពេញម៉ោង និងក្រៅម៉ោង ដោយប្រើតារាងទី១។
- ចូរសង្ខេបជំនាន់នៃ និស្សិតឆ្នាំទី២ ដោយប្រើតារាងទី១។
- ចូរសង្ខេបចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធី ដោយប្រើតារាងទី៣។

**តារាង១៖ ជំនាន់នៃនិស្សិតឆ្នាំទី១ ដោយភេទ (រយៈពេល៥ឆ្នាំសិក្សាចុងក្រោយ)**

| ឆ្នាំសិក្សា | ពេញម៉ោង | | | ក្រៅម៉ោង | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**តារាង២៖ សេចក្តីលម្អិតជំនាន់នៃនិស្សិតឆ្នាំទី១ (៥ឆ្នាំសិក្សាចុងក្រោយ)**

| ឆ្នាំសិក្សា | បេក្ខជន | | |
|---|---|---|---|
| | ចំនួននិស្សិតដាក់ពាក្យ | ចំនួននិស្សិតជាប់ | ចំនួននិស្សិតចុះឈ្មោះ |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**តារាង៣៖ ចំនួនសរុបនៃនិស្សិតដែលបានចុះឈ្មោះចូលរៀនតាមជំនាន់ (៥ឆ្នាំសិក្សាចុងក្រោយ)**

| ឆ្នាំសិក្សា | ចំនួននិស្សិតចុះឈ្មោះចូលរៀន | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | > ឆ្នាំទី៤ | សរុប |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## សំណួរវិនិច្ឆ័យ

### *គុណភាពនិស្សិត*

- តើជំនាន់និស្សិតត្រូវបានពិនិត្យតាមដាន និង វិភាគយ៉ាងដូចម្តេច?
- តើនិស្សិតត្រូវបានជ្រើសរើសយ៉ាងដូចម្តេច?
- តើគោលនយោបាយអ្វីដែលត្រូវបានបន្តប្រើពាក់ព័ន្ធនឹងជំនាន់របស់និស្សិត?
- តើវិធានការអ្វីដែលត្រូវបានប្រើដើម្បីជះឥទ្ធិពលដល់គុណភាព និងទំហំនៃ ជំនាន់? តើផលអ្វីដែលវិធានការទាំងនោះមាន?
- តើកម្មវិធីពិចារណាទៅលើកម្រិតនៃសមិទ្ធផលរបស់និស្សិតចូលរៀនយ៉ាងដូចម្តេច?

### *ការអនុវត្ត និងទំហំសិក្សារបស់និស្សិត*

- តើដេប៉ាតឺម៉ង់ មានប្រព័ន្ធពិន្ទុក្រេឌីតដែរឬទេ?
- តើទំហំសិក្សាត្រូវបានបែង ចែកស្មើគ្នាតាមឆ្នាំសិក្សាដែរឬទេ?
- តើនិស្សិតជាមធ្យមបញ្ចប់ កម្មវិធីនៅក្នុងរយៈពេលគ្រោងទុកដែរឬទេ?
- តើសូចនាករអ្វី ដែលត្រូវបានប្រើដើម្បីពិនិត្យតាមដានការរីកចម្រើន និងការអនុវត្ត?

### *ការគាំទ្រនិស្សិត*

- តើដេប៉ាតឺម៉ង់មានប្រព័ន្ធពិនិត្យតាមដានសម្រាប់កត់ត្រា ការរីកចម្រើនការសិក្សា និងតាមដាននិស្សិតដែលបានបញ្ចប់ការសិក្សា (ឧទាហរណ៍ ការអង្កេតពីមាន មានការងារធ្វើរបស់និស្សិត)?
- តើទិន្នន័យសម្រាប់ប្រព័ន្ធពិនិត្យតាមដានត្រូវបាន ប្រើយ៉ាងដូចម្តេច?
- តើបុគ្គលិកសិក្សាដើរតួនាទីអ្វីក្នុងការផ្តល់ព័ត៌មាន និងណែនាំនិស្សិត ព្រមទាំងបញ្ចូលនិស្សិតនិស្សិតទាំងនោះទៅក្នុងកម្មវិធី?
- តើនិស្សិតត្រូវបានផ្តល់ព័ត៌មានយ៉ាងដូចម្តេច អំពីផែនការសិក្សារបស់ពួកគេ?
- តើមានការយកចិត្តទុកដាក់ជាពិសេសចំពោះការណែនាំនិស្សិតឆ្នាំទី១ និងនិស្សិត ដែលមិនអនុវត្តបានល្អដែរឬទេ? ប្រសិនបើមាន តើការយកចិត្តទុកដាក់នោះដំណើរការយ៉ាងដូចម្តេច?
- តើការគាំទ្រជាក់ លាក់ត្រូវបានផ្តល់ឲ្យនិស្សិតនូវជំនាញសិក្សាសម្រាប់ដោះស្រាយបញ្ហាដែរឬទេ?
- តើការយកចិត្តទុកដាក់ដាច់ដោយ ឡែកដើម្បីណែនាំនិស្សិតកម្រិតខ្ពស់ដែរឬទេ?
- តើជំនួយត្រូវបានផ្តល់នៅក្នុងការបំពេញគម្រោង បញ្ចប់ដែរឬទេ? តើនៅកន្លែងណាដែលអាចជួយនិស្សិតជួបឧបសគ្គនឹងការអនុវត្ត ឬគម្រោងបញ្ចប់ បាន?
- តើនិស្សិតត្រូវបានផ្តល់ដំបូន្មានចំពោះបញ្ហាដែលទាក់ទងនឹង ការជ្រើសរើសមុខវិជ្ជា ការផ្លាស់ប្តូរនៃការជ្រើសរើស ការរំខាន ឬការបញ្ចប់ការសិក្សា?

- តើព័ត៌មានត្រូវបានផ្តល់ទៅឲ្យ និស្សិតចំពោះការរំពឹងទុកនៃអាជីពយ៉ាងដូចម្តេច?
- តើមូលហេតុត្រូវបានពិនិត្យចំពោះនិស្សិតដែលរៀនយូរជាងការរំពឹងទុកក្នុងការបញ្ចប់កម្មវិធីដែរឬទេ?
- តើនិស្សិតពេញចិត្តនឹងសេវាគាំទ្រ ដែលមានឬទេ?

## ប្រភពនៃស្តុតាង/ឯកសារចាំបាច់

- ដំណើរការ និងលក្ខខណ្ឌជ្រើសរើសនិស្សិត
- និន្នាការនៃជំនាន់និស្សិត
- ប្រព័ន្ធក្រេឌីត
- ទំហំការងារនិស្សិត
- របាយការណ៍អំពីការអនុវត្តរបស់និស្សិត
- ការចូលរួមនៅក្នុងសកម្មភាពសិក្សា និងសកម្មភាពផ្សេងពីការសិក្សា សកម្មភាពក្រៅកម្មវិធីសិក្សា ការប្រកួតប្រជែង។ល។
- យន្តការរាយការណ៍ និងយោបល់ត្រឡប់ ចំពោះការរីកចម្រើនរបស់និស្សិត
- បទប្បញ្ញត្តិនៃសេវាគាំទ្រ និស្សិតនៅកម្រិតសាកលវិទ្យាល័យ និងកម្រិតមហាវិទ្យាល័យ
- ទម្រង់ហ្វឹកហាត់ ណែនាំ និងប្រឹក្សាយោបល់
- យោបល់ត្រឡប់ពីនិស្សិត និងការវាយតម្លៃមុខវិជ្ជា

*១. លក្ខណវិនិច្ឆ័យ៩៖ សម្ភារៈបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធ*

*១. ធនធានរូបវន្តដើម្បីផ្តល់ឲ្យកម្មវិធីសិក្សាដែលរួមមានឧបករណ៍ សម្ភារៈ និងបច្ចេកវិទ្យាព័ត៌មានគឺគ្រប់គ្រាន់។*

*២. ឧបករណ៍ទាន់សម័យ អាច ងាយស្រួលរកបាន និងប្រើប្រាស់មានប្រសិទ្ធភាព។*

*៣. ធនធានសិក្សាត្រូវបានគេជ្រើសរើស ចម្រាញ់ និងបញ្ចូលជាមួយនឹងគោលបំណងនៃកម្មវិធីបណ្តុះបណ្តាល។*

*៤. បណ្ណាល័យអេឡិចត្រូនិកត្រូវបង្កើតឡើងដើម្បីរក្សានូវការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។*

*៥. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់បុគ្គលិក និងនិស្សិត។*

*៦. វិទ្យាស្ថានផ្តល់កុំព្យូទ័រដែលអាចប្រើបាន និងហេដ្ឋារចនាសម្ព័ន្ធបណ្តាញដែល ធ្វើឲ្យសហគមន៍នៃសាកលវិទ្យាល័យទទួលបានបច្ចេកវិទ្យាព័ត៌មានសម្រាប់ការបង្រៀន ការស្រាវជ្រាវ សេវា និងរដ្ឋបាល។*

*៧. ស្តង់ដាបរិស្ថាន សុខភាព និងសុវត្ថិភាព និងការទាក់ទងទៅនឹងមនុស្ស ដែលមានសេចក្តីត្រូវការពិសេសត្រូវបានកំណត់ និងអនុវត្ត។*

២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ៩

| No. | សម្ភារៈបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធ | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 9.1 | ឧបករណ៍ និងសម្ភារៈបរិក្ខាបង្រៀន និងរៀន (សបាសាលសិក្សា បន្ទប់សិក្សា បន្ទប់រៀបចំគម្រោង។ល។) គ្រប់គ្រាន់ និងត្រូវបានធ្វើទំនើបកម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [1] | | | | | | | |
| 9.2 | បណ្ណាល័យ និងធនធានរបស់វាគ្រប់គ្រាន់ និងត្រូវបានធ្វើទំនើបកម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [3, 4] | | | | | | | |
| 9.3 | បន្ទប់ពិសោធន៍ និងឧបករណ៍គ្រប់គ្រាន់ និងត្រូវបានធ្វើទំនើបកម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [1. 2] | | | | | | | |
| 9.4 | សម្ភារៈបរិក្ខាបច្ចេកវិទ្យាព័ត៌មានដែលរួមមានហេដ្ឋារចនា សម្ព័ន្ធសិក្សាអេឡិចត្រូនិកគ្រប់គ្រាន់ និងត្រូវបានធ្វើទំនើប កម្មដើម្បីគាំទ្រការអប់រំ និងការស្រាវជ្រាវ [1, 5, 6] | | | | | | | |
| 9.5 | ស្តង់ដាបរិស្ថាន សុខភាព និងសុវត្ថិភាព ព្រមទាំងការអាចទទួលបានពីស្តង់ដាទាំងនេះសម្រាប់អ្នកដែលមានតម្រូវការពិសេសត្រូវបានកំណត់ និងអនុវត្ត [7] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

បទប្បញ្ញត្តិនៃសម្ភារៈបរិក្ខានិងហេដ្ឋារចនាសម្ព័ន្ធគួរត្រូវស្របគ្នាជាមួយនឹងវត្ថុបំណងនៃកម្មវិធី។សម្ភារៈបរិក្ខាក៏ត្រូវបានភ្ជាប់ជាមួយ យុទ្ធវិធីបង្រៀន និងរៀន។ ឧទាហរណ៍ ប្រសិនបើយុទ្ធវិធីត្រូវបានប្រើដើម្បីបង្រៀននៅក្នុងក្រុមការងារតូចៗ នោះការគ្រប់គ្រងថ្នាក់រៀនដែលអាចបត់បែនបានគួរអាចមាន។ ធនធានសិក្សាដូចជាកុំព្យូទ័រ ប្រដាប់សិក្សាអេឡិចត្រូនិកយួរដៃ ធនធានបណ្ណាល័យ។ល។ គួរត្រូវបានផ្តល់គ្រប់គ្រាន់ដើម្បីបំពេញ សេចក្តីត្រូវការរបស់និស្សិត និងបុគ្គលិក។

## សំណួរវិនិច្ឆ័យ

- តើមានសបាសាលសិក្សា បន្ទប់ សិក្ខាសាលា បន្ទប់ពិសោធ បន្ទប់អាន និងបន្ទប់កុំព្យូទ័រគ្រប់គ្រាន់ដែរឬទេ? តើបន្ទប់ទាំងនោះបំពេញ តម្រូវការរបស់និស្សិត និងបុគ្គលិកដែរឬទេ?
- តើបណ្ណាល័យត្រូវបានបំពាក់ សម្ភារៈគ្រប់គ្រាន់សម្រាប់ការអប់រំ និងការស្រាវជ្រាវដែរឬទេ?
- តើបណ្ណាល័យអាច ងាយរកឃើញ និងទៅដល់ដែរឬទេ (ទីតាំង ម៉ោងធ្វើការ)?
- តើសម្ភារៈបរិក្ខាបន្ទប់ពិសោធ រួមបញ្ចូលនឹងបុគ្គលិកគាំទ្រគ្រប់គ្រាន់ដែរឬទេ?
- តើបន្ទប់ពិសោធបំពេញលក្ខខណ្ឌពាក់ព័ន្ធ ដែរឬទេ?
- តើឧបករណ៍ជំនួយការ បង្រៀនអាចមានចំពោះនិស្សិត និងបុគ្គលិកដែរទេ?
- តើសម្ភារៈរឹង និងទន់អាចរកបានដើម្បីបំពេញសេចក្តីត្រូវការនៃការអប់រំ និងការស្រាវជ្រាវដែរឬទេ?
- តើសម្ភារៈបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធលើកកម្ពស់ ឬរារាំងដល់ការបណ្តុះបណ្តាល នៃកម្មវិធីកម្រិតណា?
- តើថវិកាសរុបមានសម្រាប់ឧបករណ៍ ជំនួយការបង្រៀនគ្រប់គ្រាន់ដែរឬទេ?
- តើសម្ភារៈបរិក្ខា និងហេដ្ឋារចនា សម្ព័ន្ធត្រូវបានរក្សារបៀបណា?

## ប្រភពនៃភស្តុតាង/ឯកសារចាំបាច់

- បញ្ជីសម្ភារៈបរិក្ខា ឧបករណ៍ ផ្នែករឹង និងទន់នៃកុំព្យូទ័រ។ល។
- ការកក់សម្ភារៈបរិក្ខា សម្រាប់ប្រើប្រាស់ អត្រាប្រើប្រាស់ ពេលចាប់ផ្តើម/ពេលបញ្ចប់ដំណើរការ ចំនួនម៉ោងប្រតិបត្តិការ
- ផែនការថែរក្សា
- ផែនការទិញសម្ភារៈបរិក្ខាថ្មីៗ និងគម្រោងទំនើបកម្ម
- គោលនយោបាយសុវត្ថិភាព សុខភាព និងបរិស្ថាន
- ផែនការសង្គ្រោះបន្ទាន់

- យោបល់ត្រឡប់ពីនិស្សិត និងបុគ្គលិក
- ថវិកាសម្រាប់សម្ភារៈបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធ

*១. លក្ខណវិនិច្ឆ័យ១០៖ ការបង្កើនគុណភាព*

*១. កម្មវិធីសិក្សាត្រូវបានអភិវឌ្ឍជាមួយនឹងធាតុចូល និងយោបល់ត្រឡប់ពីបុគ្គលិកសិក្សា និស្សិត អតីតនិស្សិត និងភាគីពាក់ព័ន្ធមកពីវិស័យឧស្សាហកម្ម រដ្ឋាភិបាល និងអង្គការវិជ្ជាជីវៈផ្សេងៗ*

*២. ដំណើរការកំណត់កម្មវិធីសិក្សា និងអភិវឌ្ឍកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងត្រូវបានកែសម្រួល និងវាយតម្លៃជាទៀងទាត់។ ការលើកកម្ពស់ត្រូវបានធ្វើឡើងដើម្បីអភិវឌ្ឍប្រសិទ្ធផល និងប្រសិទ្ធភាពរបស់វា។*

*៣. ដំណើរការបង្រៀន និងរៀន និងការវាយតម្លៃនិស្សិតត្រូវបានពិនិត្យឡើងវិញ និងវាយតម្លៃបន្តបន្ទាប់ ដើម្បីធានាថាសារៈសំខាន់ និងការតម្រង់របស់ដំណើរការនោះទៅកេលទ្ធផលសិក្សារំពឹងទុក។*

*៤. ធាតុចូលនៃការស្រាវជ្រាវត្រូវបានប្រើប្រាស់ដើម្បីបង្កើនការបង្រៀន និងការរៀន។*

*៥. គុណភាពនៃសេវាគាំទ្រ និងសម្ភារៈបរិក្ខា (នៅ បណ្ណាល័យ មន្ទីរពិសោធ សម្ភារៈបរិក្ខាព័ត៌មានវិទ្យា និងសេវានិស្សិត) ជាកម្មវត្ថុនៃការវាយតម្លៃ និង ការបង្កើនគុណភាព។*

*៦. យន្តការផ្តល់យោបល់ ត្រឡប់ដើម្បីប្រមូលធាតុចូល និងយោបល់ត្រឡប់ពីបុគ្គលិក និស្សិត អតីតនិស្សិត និងនិយោជក មានជាប្រព័ន្ធ និងជាកម្មវត្ថុនៃការវាយតម្លៃ និងការបង្កើនគុណភាព។*

**២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ១០**

| No. | ការបង្កើនគុណភាព | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 10.1 | យោបល់ត្រឡប់ និងតម្រូវការរបស់ភាគីពាក់ព័ន្ធបម្រើជាធាតុចូល ចំពោះការអភិវឌ្ឍ និងការបង្កើតកម្មវិធីសិក្សា [1] | | | | | | | |
| 10.2 | ដំណើរការអភិវឌ្ឍ និងបង្កើតកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងជាកម្មវត្ថុនៃការវាយតម្លៃ និងបង្កើនគុណភាព [2] | | | | | | | |
| 10.3 | ដំណើរការនៃការបង្រៀន និងរៀន និងការវាយតម្លៃនិស្សិតត្រូវបានពិនិត្យឡើងវិញ និងវាយតម្លៃជាបន្តដើម្បីធានាភាពស្របគ្នា និងភាពសំខាន់របស់វា [3] | | | | | | | |
| 10.4 | ធាតុចូលនៃការស្រាវជ្រាវត្រូវបានប្រើដើម្បីបង្កើនការបង្រៀន និងការរៀន [4] | | | | | | | |
| 10.5 | គុណភាពនៃសម្ភារៈបរិក្ខា និងសេវាគាំទ្រ (នៅបណ្ណាល័យ មន្ទីរពិសោធ សម្ភារៈបរិក្ខាព័ត៌មានវិទ្យា និងសេវានិស្សិត) ត្រូវជាកម្មវត្ថុនៃការវាយតម្លៃ និងការបង្កើនគុណភាព [5] | | | | | | | |
| 10.6 | យន្តការទទួលយោបល់ត្រឡប់របស់ភាគីពាក់ព័ន្ធមានជាប្រព័ន្ធ និងជាកម្មវត្ថុនៃការវាយតម្លៃ និងការបង្កើនគុណភាព [6] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

ការបង្កើនគុណភាពនៅ ក្នុងឧត្តមសិក្សាសំដៅលើការអភិវឌ្ឍនេះ

- ចំណេះដឹង ជំនាញ និងអាកប្បកិរិយា ឬ សមត្ថភាពរបស់និស្សិត
- បរិស្ថាន និងឱកាសសិក្សារបស់និស្សិត
- គុណភាពនៃវិទ្យាស្ថាន ឬកម្មវិធី។

ការបង្កើនគុណភាពគឺជាការផ្តួចផ្តើមដែលបានគ្រោងទុកដែលត្រូវបានអនុវត្តសម្រាប់គោលបំណង នៃការអភិវឌ្ឍ និងការធានាគុណភាព។ វាជាការស្វែងរកបន្តសម្រាប់ការធ្វើឲ្យប្រសើរឡើង និងជាគំរូ។

ទំនុកចិត្ត និងការជឿជាក់របស់និស្សិត និងភាគីពាក់ព័ន្ធនៅក្នុងឧត្តមសិក្សាត្រូវបានបង្កើត និងរក្សា តាមរយៈសកម្មភាពបង្កើន និងធានាគុណភាពដ៏មានប្រសិទ្ធភាព និងប្រសិទ្ធផល ដែលធ្វើឲ្យប្រាកដថា កម្មវិធីត្រូវបានបង្កើតឡើងយ៉ាងល្អ ពិនិត្យតាមដានយ៉ាងទៀងទាត់ និងពិនិត្យឡើងវិញទៅតាមបរិច្ឆេទកំណត់ទៀងទាត់ ដែលធ្វើឲ្យធានានូវភាពសំខាន់ជាប់គ្នារបស់កម្មវិធីទាំងនោះ។

ការបង្កើន និងការ ធានាគុណភាពនៃកម្មវិធីត្រូវបានរំពឹងថានឹងរួមបញ្ចូលៈ

- ការបង្កើតលទ្ធផលសិក្សារំពឹងទុក
- ដំណើរការបង្កើត និងអភិវឌ្ឍកម្មវិធីសិក្សា
- យុទ្ធវិធីបង្រៀន និងរៀន និងការវាយតម្លៃ និស្សិត
- សេវា សម្ភារៈបរិក្ខា និងធនធានគាំទ្រ
- ការដាក់ពាក្យសុំស្រាវជ្រាវ និង
- យន្តការទទួលយោបល់ត្រឡប់ពីភាគីពាក់ព័ន្ធ

## សំណួរវិនិច្ឆ័យ

***ការវាយតម្លៃ និងការបង្កើតកម្មវិធីសិក្សា***

- អ្នកណាទទួលខុសត្រូវសម្រាប់ការបង្កើនកម្មវិធី សិក្សា?
- តើបុគ្គលិកសិក្សា និង និស្សិតចូលរួមនឹងការបង្កើតកម្មវិធីសិក្សាយ៉ាងដូចម្តេច?
- តើអ្វីជា តួនាទីនៃភាគីពាក់ព័ន្ធ នៅក្នុងការកំណត់ និងការពិនិត្យឡើងវិញនៃកម្មវិធីសិក្សា?
- តើការរកគំនិតថ្មីនៃកម្មវិធីសិក្សាកើតឡើងយ៉ាងដូចម្តេច?
- តើអ្នកណាទទួលខុសត្រូវក្នុងការអនុវត្តកម្ម វិធីសិក្សា?
- តើនៅពេលបង្កើត កម្មវិធីសិក្សា តើត្រូវបានផ្ទៀងផ្ទាត់ដោយយកស្ថាប័នផ្សេងមកពិនិត្យដែរឬទេ?
- តើនៅក្នុងបណ្តាញអន្តរជាតិ មួយណាដែលដេប៉ាតឺម៉ង់ចូលរួម?
- តើជាមួយនឹងស្ថាប័នអន្តរជាតិ មួយណាដែលនិស្សិតផ្លាស់ប្តូរចូលរួម?

- តើកម្មវិធីត្រូវបានទទួលស្គាល់ជាអន្តរជាតិដែរឬទេ?
- តើមានការធានាគុណភាពដែលបានរៀបចំជារចនាសម្ព័ន្ធដែរឬទេ?
- តើអ្នកណាត្រូវបានឲ្យចូលរួមក្នុង ការធានាគុណភាពផ្ទៃក្នុង និងពីខាងក្រៅ?
- តើមានគណៈកម្មាធិការកម្មវិធីសិក្សាដែរឬទេ? តើតួនាទីវាជាអ្វី?
- តើមានគណៈកម្មាធិការប្រឡងដែរឬទេ? តើតួនាទីវាជាអ្វី?
- តើកម្មវិធី និងមុខវិជ្ជាត្រូវបានវាយតម្លៃយ៉ាងដូចម្តេច?
- តើការវាយតម្លៃត្រូវបានធ្វើជាប្រព័ន្ធដែរឬទេ?
- តើធាតុចេញនៃការស្រាវជ្រាវត្រូវបាន អនុវត្តចំពោះការបង្រៀន និងការរៀនដែរឬទេ?
- តើនិស្សិតត្រូវបានឲ្យចូល រួមក្នុងការវាយតម្លៃកម្មវិធីសិក្សា និងមុខវិជ្ជាដែរឬទេ?
- តើលទ្ធផលនៃការវាយតម្លៃត្រូវបាន ផ្សព្វផ្សាយយ៉ាងដូចម្តេច និងទៅកាន់អ្នកណា?
- តើទង្វើអ្វីដែលត្រូវ បានអនុវត្តដើម្បីបង្កើនកម្មវិធីសិក្សា និងដំណើរការបង្កើតរបស់វា?

### *យន្តការទទួលយោបល់ត្រឡប់*

យន្តការទទួលយោបល់ ត្រឡប់ដូចជា ការអង្កេត កម្រងសំណួរ ការស្រាវជ្រាវពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការ សិក្សា ការពិភាក្សារបស់ក្រុមគោលដៅ កិច្ចពិភាក្សាជាដើម ជារឿយៗត្រូវបានប្រើដើម្បីប្រមូលធាតុចូល និងយោបល់ត្រឡប់ពីភាគីពាក់ព័ន្ធ។

- តើយន្តការទទួលយោបល់ត្រឡប់ត្រូវបានប្រើដើម្បីប្រមូលធាតុចូល និងយោបល់ ត្រឡប់ពីបុគ្គលិក និស្សិត អតីតនិស្សិត និងនិយោជកដែរឬទេ?
- តើវិធីប្រមូលយោបល់ ត្រឡប់ពីភាគីពាក់ព័ន្ធត្រូវបានរៀបចំជារចនាសម្ព័ន្ធ និងផ្លូវការដែរឬទេ?
- តើគុណភាពនៃសម្ភារៈបរិក្ខា និងសេវាគាំទ្រត្រូវបានវាយតម្លៃដែរឬទេ?
- តើយោបល់ត្រឡប់ត្រូវបានវិភាគ និងប្រើប្រាស់សម្រាប់ការបង្កើនគុណភាពដែរឬទេ?

### ប្រភពភស្តុតាង/ឯកសារចាំបាច់

- កំណត់ហេតុ និងដំណើរការនៃការ បង្កើត ពិនិត្យឡើងវិញ និងឯកភាព
- ធាតុចូលរបស់ភាគីពាក់ព័ន្ធ
- ការធានាគុណភាពនៃការវាយតម្លៃ និងការប្រឡង
- អ្នកត្រួតពិនិត្យពីខាងក្រៅ
- គោលធៀបជាតិ និងអន្តរជាតិ
- យោបល់ត្រឡប់សម្រាប់កម្មវិធី និងមុខវិជ្ជា
- ការប្រើប្រាស់នៃយោបល់ត្រឡប់សម្រាប់ការបង្កើនគុណភាព
- ភាគសំណាកនៃកម្រងសំណួរអំពីយោបល់ត្រឡប់

- របាយការណ៍ពីការអង្កេត ក្រុមគោលដៅ កិច្ចពិភាក្សា ការស្រាវជ្រាវភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា។ល។

*១. លក្ខណវិនិច្ឆ័យ១១៖ ធាតុចេញ*

*១. គុណភាពរបស់និស្សិតបញ្ចប់ការសិក្សា (ដូចជាអត្រាប្រឡងជាប់ អត្រាបោះបង់ការសិក្សា ពេលវេលាមធ្យមក្នុងការបញ្ចប់ការសិក្សា ភាពមានការងារធ្វើ។ល។) ត្រូវបានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោល ហើយកម្មវិធីគួរសម្រេចលទ្ធផលសិក្សារំពឹងទុក និងបំពេញតម្រូវការរបស់ភាគីពាក់ព័ន្ធ។*

*២. សកម្មភាពស្រាវជ្រាវដែលនិស្សិតអនុវត្តត្រូវបានបង្កើតឡើង ពិនិត្យតាមដាន និងប្រៀបធៀបគោល ហើយសកម្មភាពទាំងនោះគួរបំពេញតម្រូវការភាគីពាក់ព័ន្ធ។*

*៣. កម្រិតពេញចិត្តរបស់បុគ្គលិក និស្សិត អតីតនិស្សិត និយោជក។ល។ ត្រូវបានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោល ហើយថាកម្រិតទាំងនោះពេញចិត្តនឹងគុណភាពនៃកម្មវិធី និងនិស្សិតបញ្ចប់ការសិក្សា។*

២.បញ្ជីផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យ១១

| No. | ធាតុចេញ | 1 | 2 | 3 | 4 | 5 | 6 | 7 |
|---|---|---|---|---|---|---|---|---|
| 11.1 | អត្រាប្រឡងជាប់ និងអត្រាបោះបង់ចោលការសិក្សាត្រូវ បានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ ការធ្វើឲ្យប្រសើរឡើង [1] | | | | | | | |
| 11.2 | ពេលវេលាជាមធ្យមក្នុងការបញ្ចប់ការសិក្សាត្រូវបានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ការធ្វើឲ្យប្រសើរឡើង [1] | | | | | | | |
| 11.3 | ភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សាត្រូវបានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ការធ្វើឲ្យប្រសើរឡើង [1] | | | | | | | |
| 11.4 | ប្រភេទ និងបរិមាណសកម្មភាពស្រាវជ្រាវដោយនិស្សិតត្រូវបានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ការធ្វើឲ្យប្រសើរឡើង [2] | | | | | | | |
| 11.5 | កម្រិតពេញចិត្តរបស់ភាគីពាក់ព័ន្ធត្រូវបានបង្កើត ពិនិត្យតាមដាន និងប្រៀបធៀបជាគោលសម្រាប់ការធ្វើឲ្យប្រសើរឡើង [3] | | | | | | | |
| **យោបល់រួម** | | | | | | | | |

## ការពន្យល់

នៅក្នុងការវាយតម្លៃប្រព័ន្ធធានាគុណភាព ស្ថាប័នមិនមែនវាយតម្លៃតែគុណភាពនៃដំណើរការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគុណភាពនៃធាតុចេញ និងនិស្សិតបញ្ចប់ការសិក្សាទៀតផង។ នៅក្នុងការវាយតម្លៃគុណភាពនៃនិស្សិតបញ្ចប់ការសិក្សា ស្ថាប័នត្រូវតែពិនិត្យតាមដានការសម្រេចបាននៃលទ្ធផលសិក្សារំពឹងទុក អត្រាប្រឡងជាប់និងអត្រាបោះបង់ការសិក្សា រយៈពេលជាមធ្យមសម្រាប់ការបញ្ចប់ការសិក្សា និងភាពមានការងារធ្វើរបស់និស្សិត។ ការស្រាវជ្រាវជាធាតុចេញដ៏សំខាន់មួយទៀតពីដំណើរការនៃការធានាគុណភាព។ ប្រភេទនៃសកម្មភាពសិក្សាស្រាវជ្រាវត្រូវបានអនុវត្តដោយនិស្សិតត្រូវបំពេញនូវតម្រូវការរបស់ភាគីពាក់ព័ន្ធ។

បន្ទាប់ពីវិភាគអំពីធាតុចូល ដំណើរការ និងធាតុចេញ ស្ថាប័នត្រូវវិភាគអំពីការពេញចិត្តរបស់ភាគីពាក់ព័ន្ធ។ គួរតែមានប្រព័ន្ធនៃការប្រមូល និងវាស់វែងការពេញចិត្តរបស់ភាគីពាក់ព័ន្ធ។ ព័ត៌មានដែលប្រមូលបានគួរត្រូវបានវិភាគ និងប្រៀបធៀបជាគោលសម្រាប់ធ្វើឲ្យប្រសើរឡើងនូវកម្មវិធី ការអនុវត្តដែលមានគុណភាព និងប្រព័ន្ធធានាគុណភាព។

## ៣.អត្រាប្រឡងជាប់ និងអត្រាបោះបង់ចោលការសិក្សា

ផ្តល់ព័ត៌មាននៅលើអត្រាប្រឡងជាប់ និងអត្រាបោះបង់ចោលការសិក្សានៃជំនាន់ចុងក្រោយ៥ នៅក្នុងតារាង១។

**តារាង១៖ អត្រាប្រឡងជាប់ និងអត្រាបោះបង់ចោលការសិក្សានៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយ**

| ឆ្នាំសិក្សា | ចំនួននិស្សិត | % និស្សិតបញ្ចប់សញ្ញាបត្រដំបូង | | % អត្រាបោះបង់ចោលការសិក្សាក្នុង | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ៤ឆ្នាំ | > ៤ឆ្នាំ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## សំណួរវិនិច្ឆ័យ

### *អត្រាប្រឡងជាប់ និងអត្រាបោះបង់ចោលការសិក្សា*

- តើស្ថាប័នមានប្រព័ន្ធដ៏មានប្រសិទ្ធភាពដើម្បីពិនិត្យតាមដានអត្រាប្រឡងជាប់ និងអត្រា បោះបង់ចោលការសិក្សារបស់និស្សិតដែរឬទេ?

- តើអ្វីដែលដេប៉ាតឺម៉ង់គិតអំពីអត្រាប្រឡងជាប់? ប្រសិបបើមិនពេញ ចិត្ត តើវិធានការអ្វីត្រូវបាន ប្រើដើម្បីធ្វើឲ្យប្រសើរឡើងនូវអត្រាប្រឡងជាប់?
- តើអត្រាបោះបង់ ចោលការសិក្សាខ្ពស់កម្រិតណា? តើមានការពន្យល់ចំពោះអត្រាបោះបង់ ចោលការសិក្សាដែរឬទេ?
- តើដេប៉ាតឺម៉ង់ដឹងថាតើនិស្សិត ដែលបោះបង់ចោលការសិក្សាទៅណាទេ?

### *រយៈពេលមធ្យមក្នុងការបញ្ចប់ការសិក្សា*

- តើដេប៉ាតឺម៉ង់គិតអំពីរយៈពេល មធ្យមដើម្បីបញ្ចប់ការសិក្សាដែរឬទេ?
- តើវិធានការអ្វីត្រូវបានអនុវត្តដើម្បីលើកកម្ពស់ការបញ្ចប់ការសិក្សា និងដើម្បីបង្រួម រយៈពេល មធ្យមឲ្យខ្លីក្នុងការបញ្ចប់ការសិក្សាដែរឬទេ?
- តើវិធានការនេះមានផលប៉ះពាល់អ្វីកើតឡើង?

### *គុណភាពរបស់និស្សិតបញ្ចប់ការសិក្សា*

- តើគុណភាពរបស់និស្សិតបញ្ចប់ការសិក្សាពេញចិត្តដែរ ឬទេ?
- តើស្តង់ដាដែលសម្រេចបានត្រូវគ្នានឹង ស្តង់ដារំពឹងទុកឬទេ?
- តើនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារងាយស្រួលដែរឬទេ?តើអ្វីជាការរំពឹងទុកនៃអាជីព របស់និស្សិតបញ្ចប់ការសិក្សារយៈពេលពីរបីឆ្នាំចុងក្រោយ?

### *ភាពមានការធ្វើរបស់និស្សិតបញ្ចប់ការសិក្សា*

- តើនិស្សិតបញ្ចប់ការសិក្សាបានរកការងារធ្វើក្នុងរយៈពេល៦ខែក្រោយពេលបញ្ចប់ការសិក្សា មានប៉ុន្មានភាគរយ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ? តើនិស្សិតបញ្ចប់ការសិក្សាបានរកការងារ ធ្វើក្នុងរយៈពេល១ឆ្នាំមានប៉ុន្មានភាគរយ?
- តើនិស្សិតបញ្ចប់ការសិក្សាមិនមានការងារធ្វើមានប៉ុន្មានភាគរយ រយៈពេល១ឆ្នាំបន្ទាប់ពីការ បញ្ចប់ការសិក្សា?

### *ការស្រាវជ្រាវ*

- តើប្រភេទ នៃសកម្មភាពស្រាវជ្រាវអ្វីដែលត្រូវបានអនុវត្តចំពោះនិស្សិត? តើសកម្មភាព ទាំងនេះ ស្របគ្នានឹងលទ្ធផលសិក្សារំពឹងទុក និងចក្ខុវិស័យនិងបេសកកម្មនៃសាកលវិទ្យាល័យ និង មហាវិទ្យាល័យដែរឬទេ?

## *ការពេញចិត្តរបស់ភាគីពាក់ព័ន្ធ*

**(i) បុគ្គលិក**

- តើយន្តការអ្វីដែលអាចមានចំពោះបុគ្គលិក ក្នុងការបញ្ជាក់នូវការពេញចិត្ត ឬការមិនពេញចិត្តរបស់ពួកគេអំពីកម្មវិធី ធនធាន សម្ភារៈបរិក្ខា ដំណើរការ គោលនយោបាយ។ល។?
- តើសូចនាករ អ្វីដែលត្រូវបានប្រើ និងពិនិត្យតាមដានកម្រិតពេញចិត្តរបស់បុគ្គលិក?
- តើការ ជួចផ្តើមអ្វីត្រូវបានអនុវត្តដើម្បីបង្កើនកម្រិតពេញចិត្តរបស់បុគ្គលិក? តើការជួចផ្តើមទាំងនោះមានប្រសិទ្ធភាពដែរឬទេ?

**(ii) និស្សិត**

- តើដេប៉ាតឺម៉ង់ដឹងថានិស្សិតគិតអំពីអ្វីអំពីមុខវិជ្ជា កម្មវិធី ការបង្រៀន និងការ ប្រឡង។ល។?
- តើដេប៉ាតឺម៉ង់ ដោះស្រាយយោបល់ត្រឡប់ និងការតវ៉ារបស់និស្សិតយ៉ាងដូចម្តេច?

***(iii) អតីតនិស្សិត***

- តើអ្វីជាគំនិត និងយោបល់ត្រឡប់របស់និស្សិតបញ្ចប់ការសិក្សាអំពីសមត្ថភាពដែលគេទទួលបាន?
- តើយោបល់ត្រឡប់ពីអតីត និស្សិតត្រូវបានប្រើដើម្បីធ្វើឲ្យប្រសើរឡើងកម្មវិធីសិក្សាដែរឬទេ?

***(iv) ទីផ្សារការងារ***

- តើនិយោជកពេញចិត្តនឹងគុណភាព របស់និស្សិតបញ្ចប់ការសិក្សាដែរឬទេ?
- តើមានការតវ៉ាជាក់លាក់ណាមួយទេអំពី និស្សិតបញ្ចប់ការសិក្សា។
- តើចំណុចខ្លាំងណារបស់ និស្សិតបញ្ចប់ការសិក្សា ត្រូវបានសរសើរដោយនិយោជក?

**ប្រភពភស្តុតាង/ឯកសារចាំបាច់**

- ដំណើរការ និងសូចនាករសម្រាប់ វាស់ការពេញចិត្តរបស់ភាគីពាក់ព័ន្ធ
- និន្នាការការពេញចិត្តរបស់ភាគីពាក់ព័ន្ធ
- ការអង្កេតនិស្សិតបញ្ចប់ការសិក្សា អតីតនិស្សិត និង និយោជក
- របាយការណ៍ស្តីពីការរីកចម្រើន
- ការអង្កេតពីការងារ
- ស្ថិតិការងារ
- យោបល់ត្រឡប់ពីនិយោជក